**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង**
**វិទ្យាសាស្ត្រសេដ្ឋកិច្ច**


# សារណាបញ្ចប់ការសិក្សា

# ដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រ

ស្រាវជ្រាវពីថ្ងៃទី ០៣ មេសា ២០១៧ ដល់ថ្ងៃទី ៣១ ឧសភា ២០១៧


តាក់តែងឡើងដោយ
និស្សិតឈ្មោះ៖ **ម៉ក់ សុវិចិត្រា**
**វង្ស សុភា**

សាស្ត្រាចារ្យណែនាំ
លោក **ឈាង ហ៊ុយ**


ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច
ជំនាញ គ្រប់គ្រងធុរកិច្ច ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ម៉ក់ សុវិចិត្រា និង វង្ស សុភា ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី១៦ ឆ្នាំសិក្សា២០១៣-២០១៧ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសរសេររបាយការណ៍សារណាបញ្ចប់ការសិក្សាជាមួយនឹងប្រធានបទស្តីពី "**ដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រ**"។

ជាកិច្ចចាប់ផ្តើមយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមាតាបិតា ដែលជាអ្នកមានគុណធ្ងន់ពេកក្រៃ ដោយលោកទាំងពីរបានផ្តល់នូវជីវិត ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីកើតរហូតមកដល់បច្ចុប្បន្ននេះ។ លោកទាំងពីរតែងតែប្រៀនប្រដៅ ដាស់តឿន និងផ្តល់កម្លាំងចិត្តដល់កូនជាប់ជានិច្ច មិនថាពេលដែលកូនមានឧបសគ្គ ឬពេលកូនមានក្តីសុខ ។លោកទាំងពីរបានបញ្ជូនកូនទៅសិក្សាដើម្បីទទួលយកចំនេះវិជ្ជា សម្រាប់ជាស្ពានឆ្លងនៅអនាគតកាល។

ក្រៅពីនេះ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោក-លោកស្រីព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក- លោកស្រីប្រធាន និងអនុប្រធានការិយាល័យ និងដេប៉ាតឺម៉ង់ លោក-លោកស្រីសាស្ត្រាចារ្យ បុគ្គលិក និងក្រុមការងារគ្រប់ផ្នែកទាំងអស់ ដែលបានយកចិត្តទុកដាក់ និងចំណាយពេលវេលា ព្រមទាំងកំលាំងកាយចិត្ត ក្នុងការពន្យល់បង្ហាញ និងជួយតម្រង់ទិសដល់និស្សិតគ្រប់គ្នា ដែលរួមមានពួកយើងខ្ញុំទាំងពីរនាក់។

ទន្ទឹមនឹងនេះ យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណដល់ លោកសាស្ត្រាចារ្យ **ឈាង ហ៊ុយ** ដែលជាសាស្ត្រាចារ្យណែនាំ ដែលបានចំនាយពេលវេលាដ៏មានតម្លៃ ដើម្បីជួយណែនាំ ផ្តល់យោបល់ និងកែសម្រួលនូវរាល់កំហុសឆ្គង ដែលកើតមានក្នុងកំឡុងពេលនៃការរៀបរៀងរបាយសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំទាំងពីរ។

ទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យសិរីវិបុលសុខ សុភមង្គល មហាប្រសើរ រួមទាំងពុទ្ធពរទាំងបួនប្រការ អោយកើតមានចំពោះលោកអ្នកមានគុណទាំងអស់កុំបីឃ្លាងឃ្លៀត។

# អារម្ភកថា

ការសរសេររបាយការណ៍សារណាបញ្ចប់ឆ្នាំសិក្សា គឺជាការផ្តល់ឱកាសដ៏ប្រពៃមួយដល់និស្សិតដើម្បីស្វែងរកបទពិសោធន៍ជាក់ស្តែងនៅក្នុងការងារ ព្រមទាំងអាចអោយនិស្សិតមានលទ្ធភាពក្នុងការស្វែងយល់ និងប្រៀបធៀបពីភាពដូច និងខុសគ្នារវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែងផងដែរ។

ដោយមើលឃើញពីការរីកចម្រើនថ្មីនៃវិស័យមូលបត្រកម្ពុជា យើងខ្ញុំមានភាពសោមនស្សរីករាយជាខ្លាំងក្នុងការជ្រើសរើសប្រធានបទមួយស្តីពី **"ដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រ"** មកធ្វើការស្រាវជ្រាវ និងពង្រីកចំណេះដឹងបន្ថែមដល់អ្នកអានអោយកាន់តែមានភាពស៊ីជម្រៅក្នុងវិស័យនេះ។

ជាការពិត របាយការណ៍កម្មសិក្សាមួយនេះ ប្រាកដជា មាននូវកំហុសឆ្គងមួយចំនួន ដែលកើតឡើងដោយអចេតនា ដូចជាកំហុសអក្ខរាវិរុទ្ធ និងការខ្វះចន្លោះនៅក្នុងផ្នែកអត្ថន័យ ជាអាទិ៍។ ហេតុនេះ យើងខ្ញុំលំឱនទាំងចិត្តកាយសូមអភ័យទោសទុកជាមុនចំពោះរាល់កំហុសឆ្គងដែលកើតមាននេះ ហើយនឹងស្វាគមន៍ដោយក្តីរីករាយនូវរាល់មតិរិះគន់ និងការកែតម្រូវ ពីសំណាក់ លោក-លោកស្រីសាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ដែលមានចំនេះដឹងខ្ពង់ខ្ពស់ ក្នុងវិស័យនេះ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថា របាយការណ៍សារណានេះ នឹងអាចជាជំនួយ និងការរួមចំនែកក្នុងការចែករំលែកនូវចំនេះដឹង និងបទពិសោធន៍ខ្លះៗទាក់ទងនឹងផ្នែកមូលបត្រ អោយកាន់តែមានភាពច្បាស់លាស់មួយកម្រិតទៀត។

# មាតិកា


តារាងអក្សរកាត់ .......... v

បញ្ជីរូប .......... vi


## សេចក្តីផ្តើម


១. លំនាំបញ្ហា .......... ១

២. ចំណោទបញ្ហា .......... ២

៣. គោលបំណងនៃការស្រាវជ្រាវ .......... ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .......... ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ .......... ២

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ .......... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......... ៣


## ជំពូកទី១
## រំលឹកទ្រឹស្តី


១.១ និយមន័យនៃមូលបត្រ .......... ៤

១.២ ប្រភេទមូលបត្រ .......... ៤

១.២.១ មូលបត្រកម្មសិទ្ធិ .......... ៤

១.២.១.១ ភាគហ៊ុនធម្មតា .......... ៥

១.២.១.២ ភាគហ៊ុនបុរិមា .......... ៨

១.២.២ មូលបត្របំណុល .......... ៩

១.២.២.១ សញ្ញាណរបស់មូលបត្របំណុល .......... ៩

១.២.២.២ ទិន្នផលនៃមូលបត្របំណុល .......... ១០

១.៣ ទីផ្សារមូលបត្រ .......... ១០

១.៣.១ ប្រភេទនៃទីផ្សារមូលបត្រ .......... ១១

១.៣.២ ស្ថាប័នប្តូរមូលបត្រ .......... ១២

១.៣.៣ ទីផ្សារ OTC .......... ១២

១.៤ ប្រភេទនៃប្រតិបត្តិការមូលបត្រ .......... ១២

១.៤.១ Long Purchase .......... ១២

១.៤.២ ការជួញដូរមានកម្រិតកំណត់ .......... ១២
១.៤.៣ ការលក់មូលបត្ររយៈពេលខ្លី .......... ១៣
១.៥ ការផាត់ទាត់ និងការទូទាត់ .......... ១៣
១.៥.១ ការផាត់ទាត់ .......... ១៣
១.៥.២ ការទូទាត់ .......... ១៤

## ជំពូកទី២

## ទីផ្សារមូលបត្រកម្ពុជា

២.១ ប្រវត្តិសង្ខេបនៃទីផ្សារមូលបត្រកម្ពុជា .......... ១៦
២.២ ប្រតិបត្តិការរបស់ផ្សារមូលបត្រកម្ពុជា .......... ១៧
២.២.១ ម៉ោងជួញដូរមូលបត្រ .......... ១៧
២.២.២ ថ្ងៃជួញដូរ .......... ១៨
២.២.៣ ប្រភេទនៃបញ្ជា .......... ១៨
២.២.៤ ថ្លៃមូលដ្ឋាន .......... ១៨
២.២.៥ ឯកតាជួញដូរ និងឯកតាគម្លាតថ្លៃ .......... ១៩
២.២.៦ ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃ .......... ១៩
២.២.៧ សុពលភាពនៃបញ្ជា .......... ២០
២.២.៨ ការកែប្រែ និងការលុបចោលបញ្ជាដែលបានបញ្ជូន .......... ២១
២.២.៩ គោលការណ៍ដេញថ្លៃ .......... ២១
២.២.១០ វិធីសាស្ត្រ និងយន្តការនៃការអនុវត្តការជួញដូរ .......... ២១
២.២.១១ ការផ្សាយជាសាធារណៈនូវពត៌មានទីផ្សារ .......... ២២
២.២.១២ ការត្រួតពិនិត្យ និងឃ្លាំមើលទីផ្សារ .......... ២៣
២.២.១៣ នីតិវិធីនៃការជួញដូរមូលបត្រ .......... ២៣
២.២.១៣.១ ការបើកគណនី និងការដាក់បញ្ជា .......... ២៣
២.២.១៣.២ ការអនុវត្តន៍ការជួញដូរ និងការជូនដំណឹង .......... ២៣

## ជំពូកទី៣

## ស្ថានភាពទូទៅរបស់ធនាគារកាណាឌីយ៉ា

៣.១ ប្រវត្តិនៃធនាគារកាណាឌីយ៉ា .......... ២៦

៣.១.១ ស្លាកសញ្ញា....................................................................................................២៦
៣.១.២ ទស្សនៈវិស័យ .................................................................................................២៧
៣.១.៣ បេសកកម្ម ......................................................................................................២៧
៣.១.៤ ថ្នាក់ដឹកនាំរបស់ធនាគារកាណាឌីយ៉ា ..........................................................................២៧
៣.១.៥ ធនាគារដៃគូរ ...................................................................................................២៧
៣.២ ផលិតផល និងសេវាកម្ម ...........................................................................................៣១
៣.២.១ សេវាកម្មបញ្ញើ សន្សំ ...........................................................................................៣២
៣.២.២ សេវាកម្មឥណទាន.............................................................................................. ៣៣

## ជំពូកទី៤

## ដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រ

៤.១ និយមន័យនៃប្រព័ន្ធផាត់ទាត់ និងទូទាត់............................................................................ ៣៥
៤.២ តួអង្គសំខាន់ៗ និងតួនាទីរបស់តួអង្គក្នុងដំណើរការផាត់ទាត់ និងទូទាត់ .......................... ៣៥
៤.២.១ ប្រតិបត្តិករទីផ្សារមូលបត្រ.................................................................................... ៣៦
៤.២.២ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ............................................................ ៣៦
៤.២.៣ ប្រតិបត្តិកររក្សាទុកមូលបត្រ....................................................................................៣៧
៤.២.៤ ក្រុមហ៊ុនមូលបត្រ ................................................................................................៣៧
៤.២.៥ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ................................................................៣៧
៤.៣ គោលការណ៍ក្នុងការបើកគណនីសម្រាប់ការផាត់ទាត់ និងទូទាត់................................................ ៣៩
៤.៣.១ ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់សាច់ប្រាក់..................................................៤០
៤.៣.២ ការបើកគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ........................................................៤០
៤.៤ កាលបរិច្ឆេទផាត់ទាត់ និងទូទាត់ ...........................................................................................៤១
៤.៥ អ្នកតំណាងទូទាត់ ..................................................................................................................៤២
៤.៦ យន្តការនៃការផាត់ទាត់ និងទូទាត់មូលបត្រ ...........................................................................៤២
៤.៦.១ រូបិយប័ណ្ណទូទាត់ ............................................................................................... ៤៣
៤.៦.២ ដំណើរការនៃការផាត់ទាត់និងទូទាត់ ...........................................................................៤៤
៤.៦.៣ ការបន្សុទ្ធ ឬការកាត់កង ......................................................................................៤៥
៤.៦.៣.១ និយមន័យ...............................................................................................៤៥

៤.៦.៣.២ វិធីសាស្ត្រគណនា ........................................ ៤៥
៤.៦.៤ លក្ខណៈនៃការទូទាត់ ........................................ ៤៦
៤.៦.៥ ការទូទាត់សាច់ប្រាក់ ........................................ ៤៧
៤.៦.៥.១ ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ ........................................ ៤៧
៤.៦.៥.២ ការទូទាត់សាច់ប្រាក់ក្នុងអន្តរធនាគារ ........................................ ៤៩
៤.៦.៦ ការទូទាត់មូលបត្រ ........................................ ៥២
៤.៧ ការប្រគល់ឯកសារទូទាត់មូលបត្រ ........................................ ៥៣
៤.៨ វិធានការបរាជ័យនៃការផាត់ទាត់ និងទូទាត់ ........................................ ៥៣
៤.៩ កម្រៃសេវាផាត់ទាត់ និងទូទាត់ ........................................ ៥៤
៤.១០ ដំណើរការនៃការដាក់ និងដកសាច់ប្រាក់ជួញដូរមូលបត្រ ........................................ ៥៥
៤.១០.១ ការដាក់សាច់ប្រាក់សម្រាប់ការជួញដូរ ........................................ ៥៥
៤.១០.២ ការដកសាច់ប្រាក់សម្រាប់ការជួញដូរ ........................................ ៥៩

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................ ៦៤
២. អនុសាសន៍ ........................................ ៦៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# តារាងអក្សរកាត់

ផ.ម.ក ៖ ផ្សារមូលបត្រកម្ពុជា

គ.ម.ក ៖ គណៈកម្មការមូលបត្រកម្ពុជា

SF ៖ ក្រុមហ៊ុនមូលបត្រ

CSA ៖ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

CSO ៖ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ

CSD ៖ ប្រតិបត្តិកររក្សាទុកមូលបត្រ

NBC ៖ ធនាគារជាតិនៃកម្ពុជា

# បញ្ជីរូប


រូបទី១ ៖ ដំណើរការនៃការផាត់ទាត់ និងទូទាត់ ............................................................ ៤៤

រូបទី២ ៖ ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ ........................................................ ៤៧

រូបទី៣ ៖ ការទូទាត់សាច់ប្រាក់ក្នុងអន្តរធនាគារ ............................................................ ៥០

រូបទី៤ ៖ ការទូទាត់មូលបត្រ........................................................................................ ៥២

រូបទី៥ ៖ ការដាក់សាច់ប្រាក់ជួញដូរមូលបត្រនៅCNB .................................................... ៥៧

រូបទី៦ ៖ ការដកសាច់ប្រាក់ជួញដូរមូលបត្រនៅCNB ...................................................... ៦២

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការលើកស្ទួយជីវភាពប្រជាជន ក៏ដូចជាការអភិវឌ្ឍ សេដ្ឋកិច្ចជាតិមានការរីកចម្រើនជាលំដាប់។ ជារួម ពោលគឺមានការអភិវឌ្ឍស្ទើរតែគ្រប់ វិស័យដែលមានដូចជា វិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម ទេសចរណ៍.... សុទ្ធតែមានការរីកចម្រើនលូតលាស់គួរអោយកត់សម្គាល់។ ដោយអនុវត្តតាមគោលនយោបាយ សេដ្ឋកិច្ចទីផ្សារសេរីបានបើកទ្វារទទួលអោយមានអ្នកវិនិយោគគ្រប់ប្រភេទមកបណ្ដាក់ទុនស្ទើរតែគ្រប់វិស័យទាំងអស់។ដោយសារតែការវិនិយោគចេះតែបន្តកើនឡើង វិស័យថ្មីមួយក៏ត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើងនៅក្នុងកំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ គឺវិស័យជួញដូរមូលបត្រ។យើងសង្កេតឃើញថា បន្ទាប់ពីវិស័យធនាគារមក វិស័យមួយនេះក៏បានរួមចំណែកក្នុងការធ្វើអោយប្រព័ន្ធហិរញ្ញវត្ថុកាន់តែមានភាពជឿនលឿនមួយកម្រិតទៀត ដោយអាចប្រមូលបាននូវប្រភពហិរញ្ញវត្ថុពីវិនិយោគិនក្នុង និងក្រៅប្រទេស ។

ជាការពិតណាស់វិស័យមូលបត្រគឺជាវិស័យមួយដ៏ថ្មីស្រឡាងសម្រាប់ប្រជាជានកម្ពុជា ដូច្នេះចំពោះប្រតិបត្តិការជួញដូរអាចនិយាយបានថា នៅមានកម្រិតមួយនៅឡើយ។ផ្ទុយទៅវិញការចូលខ្លួនក្នុងទីផ្សារនៃវិស័យមូលបត្រ បែរជាក្លាយជាដៃគូទំនាក់ទំនងដ៏សំខាន់ជាមួយធនាគារទៅវិញ។ ក្នុងប្រតិបត្តិការនៃការជួញដូរមូលបត្រ តែងតែត្រូវការធនាគារក្នុងការជួញអន្តរាគមន៍ជានិច្ច ដូចជាការបើកគណនីសាច់ប្រាក់ជួញដូរមូលបត្រ និង ការទូទាត់ និងផាត់ទាត់មូលបត្រជាដើម។ ប្រតិបត្តិការបំពេញអោយគ្នានៃវិស័យទាំងពីរបានធ្វើអោយ ប្រតិបត្តិការហិរញ្ញវត្ថុក្នុងទីផ្សារកាន់តែមានភាពរលូនបន្ថែមទៀត។

ដោយហេតុថាការជួញដូរមូលបត្រជាវិស័យមួយថ្មី ដូច្នេះចំណេះដឹងដែលទាក់ទងនឹងវិស័យនេះដូចជារបៀបនៃការជួញដូរ ការពិនិត្យលើសន្ទស្សន៍ថ្លៃ ការផាត់ទាត់ និងទូទាត់មូលបត្របន្ទាប់ពីជួញដូររួចរាល់ គឺមានចំណុចខ្វះខាតនៅឡើយដែលធ្វើអោយប្រជាជនកម្ពុជាហាក់ពុំសូវហ៊ានប្រថុយក្នុងការជួញដូរមូលបត្រ ព្រោះពួកគាត់ខ្លាចខាតបង់នូវធនធានដែលគាត់មាន។ ដោយសារកង្វះខាតចំណុចទាំងអស់នេះបានធ្វើអោយក្រុមយើងខ្ញុំជ្រើសរើសប្រធានបទ **"ដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រ"** យកមកសិក្សាស្រាវជ្រាវ ដើម្បីពង្រីកចំណេះដឹងបន្ថែមដល់និស្សិតជំនាន់ក្រោយសិក្សាស្វែងយល់អោយកាន់តែច្បាស់នៅក្នុងវិស័យមូលបត្រនេះ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

- តើការជួញដូរមូលបត្រប្រព្រឹត្តទៅដោយរបៀបណា?
- តើអ្វីទៅជាប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ?
- តើដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រមានលក្ខណៈដូចម្តេចខ្លះ?
- តើការផាត់ទាត់ និងទូទាត់មូលបត្រជាមួយវិស័យធនាគារមានលក្ខណៈដូចម្តេចដែរ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះ គឺចង់បង្ហាញពីដំណើរការផាត់ទាត់ និងទូទាត់មូលបត្រក្រោយពេលទិញ និងលក់មូលបត្រ។ក្នុងនោះនៅមានគោលបំណងជាក់លាក់មួយចំនួនដូចជា៖

-ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ

-ការទូទាត់សាច់ប្រាក់ក្នុងអន្តរធនាគារ

-ស្ថានភាពទូទៅរបស់ធនាគារកាណាឌីយ៉ា

-ការទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រនៅធនាគារកាណាឌីយ៉ា។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងសារណាបញ្ចប់ការសិក្សានេះ ផ្តោតសំខាន់តែលើដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រ ដោយប្រព័ន្ធប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រត្រូវបានគេធ្វើវិសោធនៈកម្មលើកទី៧កាល់ពីថ្ងៃទី០៩ មករាឆ្នាំ ២០១៧ និងការស្វែងរកទិន្នន័យបន្ថែមដោយសិក្សានៅក្នុងឆ្នាំ២០១៦ ប៉ុណ្ណោះ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ បានផ្តល់អត្ថប្រយោជន៍ជាច្រើនដូចជា៖

**ចំពោះខ្លួនឯង**

ធ្វើអោយខ្លួនឯងកាន់តែយល់ច្បាស់ ពីដំណើរការនៃការជួញដូរមូលបត្រ ការផាត់ទាត់ និងទូទាត់មូលបត្រ ក៏ដូចជាការអនុវត្តន៍ការផាត់ទាត់ទូទាត់ក្នុងធនាគារផ្ទាល់។

**ចំពោះមិត្តនិស្សិត**

សារណាបញ្ចប់មួយនេះក៏ធ្វើជាគ្រឿងជំនួយស្មារតីដល់មិត្តៗនិស្សិតដើម្បីសិក្សាស្វែងយល់បន្ថែម និងទុកជាចំណេះដឹងថ្មីក្នុងវិស័យមូលបត្រ។

**ចំពោះប្រជាជនកម្ពុជា និងវិនិយោគិន**

ការកាន់តែមានភាពយល់ច្បាស់ក្នុងវិស័យមូលបត្រ ធ្វើអោយប្រជាជនកម្ពុជាមានភាពងាយស្រួលក្នុងការចូលប្រឡូកក្នុងវិស័យមូលបត្រ ហើយជាពិសេសវិនិយោគិនអាចមានដំណោះស្រាយក្នុងការកាត់បន្ថយហានីភ័យផ្សេងៗដែលពួកគេបានជួបក្នុងវិស័យមូលបត្រកន្លងមក។

**ចំពោះសេដ្ឋកិច្ចជាតិ**

កាលណាការវិនិយោគលើវិស័យមូលបត្រកាន់តែច្រើននោះនឹងធ្វើអោយកំណើនសេដ្ឋកិច្ចកើនឡើង ដោយវិនិយោគិនកាន់តែបណ្តាក់ទុនវិនិយោគក្នុងប្រទេសកាន់តែច្រើន។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះពឹងផ្អែកលើប្រភពទិន្នន័យសំខាន់ពីរ គឺ៖

- ទិន្នន័យចម្បង (Primary Data)៖ ក្នុងវិធីសាស្ត្រនេះក្រុមយើងខ្ញុំបានស្វែងរកឯកសាទាំងឡាយដែលទាក់ទងនឹងប្រធាននេះតាមរយៈ ច្បាប់ អនុក្រឹត្យ ប្រកាសក្នុងទីផ្សារមូលបត្រកម្ពុជា និងការសម្ភាសន៍ផ្ទាល់ជាមួយជាមួយបុគ្គលិកជំនាញផ្នែកផាត់ទាត់របស់ធនាគារកាណាឌីយ៉ា។
- ទិន្នន័យបន្ទាប់បន្សំ (Secondary Data)៖តាមប្រព័ន្ធអ៊ីនធឺណេត ការណែនាំរបស់សាស្ត្រាចារ្យ និក្ខេបបទរបស់និស្សិតរៀមច្បង និងឯកសាក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យនានា មេរៀនទ្រឹស្តី និងពាក់ព័ន្ធដែលសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានផ្តល់អោយ និងចំណេះដឹងពីការសិក្សារយៈពេល ៤ឆ្នាំ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃប្រធានបទនេះមានដូចជា៖

- សេចក្តីផ្តើម
- ជំពូកទី១ រំលឹកទ្រឹស្តី
- ជំពូកទី២ ទីផ្សារមូលបត្រកម្ពុជា
- ជំពូកទី៣ ស្ថានភាពទូទៅរបស់ធនាគារកាណាឌីយ៉ា
- ជំពូកទី៤ ដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រ
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី១
# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. និយមន័យនៃមូលបត្រ

[1]មូលបត្រ គឺជាអំណះអំណាងនៃភាពជាម្ចាស់ ឬបំណុលដែលត្រូវបានគេកំណត់នូវតម្លៃមួយ ហើយត្រូវបានគេដាក់លក់។ សម្រាប់អ្នកជាម្ចាស់ មូលបត្រមួយតំណាងអោយ ការវិនិយោគនៃម្ចាស់ម្នាក់ ម្ចាស់បំណុល ឬសិទ្ធិនៃភាពជាម្ចាស់ ដែលបុគ្គលម្នាក់យល់ថាពួកគេនឹងអាចរកប្រាក់ចំណេញបានពីការវិនិយោគលើមូលបត្រនេះត្រឡប់មកវិញ។

[2]មូលបត្រ គឺជាការវិនិយោគដែលត្រូវបានគេជួញដូរនៅលើទីផ្សារមូលធន។ឧទាហរណ៍ ភាគហ៊ុន និងសញ្ញាប័ណ្ណជាដើម។ មូលបត្រអនុញ្ញាតិអោយអ្នកវិនិយោគក្លាយជាម្ចាស់កម្មសិទ្ធិទៅលើទ្រព្យសម្ភារៈជាមូលដ្ឋានដោយមិនចាំបាច់ប្រើប្រាស់ការកាន់កាប់។
ដោយសារតែហេតុផលនេះហើយទើបគេឃើញមូលបត្រត្រូវបានគេជួញដូរជាញឹកញាប់នៅលើទីផ្សារមូលធន។ វាមានន័យថា មូលបត្រងាយស្រួលក្នុងការកំណត់តម្លៃ ហើយក៏ងាយស្រួលប្រែប្រួលនៃតម្លៃរបស់វា ហើយជាពិសេសវាក៏ជាទ្រនិចមួយក្នុងការចង្អុលបង្ហាញនូវតម្លៃនៃទ្រព្យសម្ភារៈជាមូលដ្ឋានទាំងនោះដែរ។ អ្នកជួញដូរមូលបត្រ ត្រូវតែមានអាជ្ញាប័ណ្ណច្បាស់លាស់ទើបអាចធ្វើការជួញដូរលើទីផ្សារបាន ពីព្រោះអ្នកទាំងអស់នោះត្រូវតែគោរពតាមបែបបទ និងច្បាប់ដែលដាក់ចេញក្នុងការជួញដូរមូលបត្រ។

## ១.២. ប្រភេទមូលបត្រ

ជាទូទៅមូលបត្រចែកចេញជាពីរប្រភេទគឺ មូលបត្រកម្មសិទ្ធ(ភាគហ៊ុន) និងមូលបត្របំណុល(សញ្ញាប័ណ្ណ) ដែលត្រូវបានជួញដូរក្នុងចំណោមឧបករណ៍ដទៃទៀតក្នុងទីផ្សារមូលធន។

### ១.២.១ មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធ គឺជាសន្លឹកភាគហ៊ុនដែលតំណាងអោយភាពជាម្ចាស់កម្មសិទ្ធនៃចំណែករបស់ក្រុមហ៊ុនមួយដែលបានកាន់។ហើយមូលបត្រកម្មសិទ្ធនេះមានពីរប្រភេទទៀតគឺ ភាគហ៊ុនធម្មតា(Common Stock) និងភាគហ៊ុនបរិមា (Preferred Stock)។

[1] www.thestreet.com/topic/47042/securities.html, ចូលដកស្រង់ថ្ងៃទី ២៦ មេសា ឆ្នាំ ២០១៧

[2] www.thebalance.com/securities-definition-and-effect-on-the-u-s-economy-3305961,ចូលដកស្រង់ថ្ងៃទី ២៦ មេសា ឆ្នាំ ២០១៧

### ១.២.១.១ ភាគហ៊ុនធម្មតា (Common Stock)[3]

#### ក. សញ្ញាណភាគហ៊ុនធម្មតា

ភាគហ៊ុនធម្មតាដែលជាទូទៅគេហៅថាភាគហ៊ុន គឺជាមូលបត្រដែលតំណាងអោយចំណែកនៃទុនរបស់ភ្នាក់ងារសេដ្ឋកិច្ចដែលបានដាក់ទុនវិនិយោគ និងជាចំណែកនៃកម្មសិទ្ធនៅក្នុងក្រុមហ៊ុន។ម្ចាស់កាន់កាប់ភាគហ៊ុនទាំងអស់ មានសិទ្ធចូលរួមទទួលចំណូលតាមរយៈការបែងចែកភាគលាភ (Dividends) ឬចំណេញមូលធននៅក្នុងតម្លៃដែលបានកាន់ភាគហ៊ុននោះ (Capital Gain or Loss និង Increase in Value)។

ភាគហ៊ុនមិនដូចនឹងមូលបត្រចំណូលថេរ (Fixed Income Securities) នោះទេ។បើសិនជាក្រុមហ៊ុនទទួលបានជោគជ័យលើអាជីវកម្មរបស់ខ្លួន (អត្រាប្រាក់ចំណេញខ្ពស់ និងមានគោលនយោបាយបែងចែកភាគលាភបានល្អ) នោះថ្លៃរបស់ភាគហ៊ុននឹងកើនឡើង។ប្រសិនបើក្រុមហ៊ុនមិនបានជោគជ័យលើអាជីវកម្មរបស់ខ្លួននោះទេ នោះវានឹងធ្វើអោយថ្លៃភាគហ៊ុនរបស់ក្រុមហ៊ុនធ្លាក់ចុះ។សរុបមក ការវិនិយោគលើភាគហ៊ុន គឺមានហានិភ័យច្រើនជាងការវិនិយោគលើមូលបត្រចំណូលថេរ (Fixed Income Securities)។

#### ខ.ផលចំនេញពីភាគហ៊ុនធម្មតា

នៅពេលដែលវិនិយោគិនវិនិយោគទៅលើមូលបត្រ មានន័យថាវិនិយោគិនបានទិញចំណែកភាគហ៊ុននៃក្រុមហ៊ុននោះ ការវិនិយោគបែបនេះត្រូវបានគេស្គាល់ថា៖ Equity Shares។ ប្រសិនជាក្រុមហ៊ុនមានប្រតិបត្តិការល្អ នោះវិនិយោគិននឹងអាចទទួលបានផលចំណេញពីការវិនិយោគនោះ។ក្នុងការវិនិយោគលើមូលបត្រវិនិយោគិនអាចទទួលបានប្រាក់ចំណេញបានពីររបៀបគឺ៖ ភាគលាភ (Dividends) និងប្រាក់ចំណេញមូលធន (Capital Gains)។

**+ ភាគលាភ (Dividends)[4]**

ភាគលាភ គឺជាចំណែកនៃប្រាក់ចំណេញទទួលបានដោយក្រុមហ៊ុនហើយត្រូវបែងចែកទៅម្ចាស់ភាគហ៊ុនម្នាក់ៗសមាមាត្រនឹងទឹកប្រាក់ ដែលគាត់បានធ្វើវិនិយោគលើភាគហ៊ុននៃក្រុមហ៊ុននោះ។នៅពេលដែលសាធារណៈជនមានភាគហ៊ុននៅក្នុងក្រុមហ៊ុនមួយគេអាចរកចំណូលបានពីការវិនិយោគនោះតាមរយៈការផ្តល់ភាគលាភ។វិនិយោគិនអាចទទួលប្រាក់ពីភាគលាភ និងការវិនិយោ

---

[3] http://www.investopedia.com/terms/c/commonstock.asp ដកស្រង់ថ្ងៃទី ៣០ មេសា ២០១៧

[4] https://www.mtholyoke.edu/courses/sgabriel/securities1/stock/stockprofits.htm ដកស្រង់ថ្ងៃទី ០២ ឧសភា ២០១៧

គទៅលើមូលបត្រកម្មសិទ្ធនៃក្រុមហ៊ុនដទៃ។វិនិយោគិនដែលដល់អាយុចូលនិវត្តន៍ជាទូទៅសុខចិត្ត ទទួលភាគលាភពីភាគហ៊ុនដើម្បីជំនួសនូវប្រាក់ខែរបស់គេ។ភាគលាភដែលបានមកពីការវិនិយោគ ឫផលដែលទទួលបានពីការដាក់ទុន គឺអាស្រ័យទៅលើប្រតិបត្តិការល្អ និងអាក្រក់របស់ក្រុមហ៊ុន។

**+ចំណេញមូលធន (Capital Gains)**

មូលធនកម្មសិទ្ធត្រូវបានគេយកទៅជួញដូរក្នុងប្រតិបត្តិការប្រចាំថ្ងៃនៃទីផ្សារមូល បត្រ ដែលថ្លៃប្រែប្រួលគ្រប់ពេលគ្រប់វេលា។នៅពេលដែលតម្លៃនៃភាគហ៊ុនមានការកើនឡើងជាតម្លៃ ដែលវិនិយោគិនបានចំណាយនៅពេលដែលគេទិញភាគហ៊ុន នោះវិនិយោគិននឹងទទួលបានផល ចំណេញពីការលក់ភាគហ៊ុននោះ។ចំណូលបែបនេះត្រូវបានគេស្គាល់ថាជាចំណេញមូលធន។ផ្ទុយ ទៅវិញនៅពេលដែលតម្លៃភាគហ៊ុនទាបជាងចំណាយដែលវិនិយោគិនបានចំណាយទៅលើភាគ ហ៊ុននោះវិនិយោគិននឹងជួបនូវ ការខាតបង់មូលធន(Capital Loss)។

ភាគលាភ និងចំណេញមូលធនគឺអាស្រ័យទៅលើសកម្មភាពនិងកេរ្តិ៍ឈ្មោះរបសើក្រុមហ៊ុន តម្រូវការនៃភាគហ៊ុន។ជាទូទៅតម្រូវការគឺមានឥទ្ធិពលទៅលើប្រតិបត្តិការនាថ្ងៃអនាគតរបស់ក្រុម ហ៊ុន។នៅពេលដែលមានតម្រូវការខ្ពស់ជាសញ្ញាណថាមានវិនិយោគិនជាច្រើនរង់ចាំទិញភាគហ៊ុន នោះដែលវាជាកត្តាមួយដ៏សំខាន់ដែលអាចធ្វើអោយតម្លៃភាគហ៊ុនមានការកើនឡើង។ផ្ទុយទៅវិញ ប្រសិនបើក្រុមហ៊ុនរកចំណូលមិនសូវបាន ឫក៏វិនិយោគិនលក់ភាគហ៊ុនរបស់ខ្លួនជាជាងទិញភាគ ហ៊ុននោះ តម្លៃនៃភាគហ៊ុននឹងមានភាពធ្លាក់ចុះពីព្រោះពុំសូវមានតម្រូវការ។

ជាទូទៅសកម្មភាពប្រតិបត្តិការរបស់ភាគហ៊ុន គឺអាចជះឥទ្ធិពលដល់ទីផ្សារមូលបត្របាន ហើយក៏អាចប៉ះពាល់ដល់សេដ្ឋកិច្ចទាំងមូលផងដែរ។ឧទាហរណ៍៖ ប្រសិនជាអត្រាការប្រាក់មាន ការកើនឡើងវិនិយោគិននឹងរំពឹងថាគេនឹងទទួលបានផលលាភពីមូលបត្របំណុលជាជាងមូលបត្រ កម្មសិទ្ធ(ភាគហ៊ុន) វិនិយោគិនអាចលក់ភាគហ៊ុនរបស់ខ្លួនទាំងអស់រួចយកកម្រៃពីការលក់នោះទៅ វិនិយោគលើមូលបត្របំណុលវិញ។ប្រសិនជាវិនិយោគិនទាំងអស់មានគំនិតដូចគ្នានោះទីផ្សារភាគ ហ៊ុនទាំងមូលនឹងជួបនូវបញ្ហាភាគហ៊ុនធ្លាក់ថ្លៃ ដែលវាបានជះឥទ្ធិពលអាក្រក់ដល់វិនិយោគិនដែល កំពុងកាន់ភាគហ៊ុនក្នុងដៃ។កត្តាដទៃទៀតដូចជា កត្តាអស្ថេរភាពនយោបាយក្នុងស្រុកឫបរទេសស កត្តាការផ្គត់ផ្គង់ថាមពល កត្តាអាកាសធាតុ និងកត្តាសហគ្រាសធំៗ សុទ្ធសឹងតែអាចជះឥទ្ធិពល ដល់ប្រតិបត្តិការទីផ្សារភាគហ៊ុន។

ផ្ទុយទៅវិញ វាក៏ជាកត្តាគន្លឹះក្នុងការវិនិយោគផងដែរ ព្រោះនៅពេលដែលតម្លៃភាគហ៊ុនធ្លាក់ ចុះ វានឹងទាក់ទាញវិនិយោគិនអោយធ្វើការវិនិយោគវិញដោយសារតែតម្លៃភាគហ៊ុននាពេលនេះ

មានតម្លៃទាប។ប្រសិនវិនិយោគិនចាប់ផ្តើមវិនិយោគទៅលើភាគហ៊ុនវិញនោះតម្លៃភាគហ៊ុនក៏មានងើបឡើងវិញដែរ សកម្មភាពបែបនេះបានធ្វើអោយមានចរាចរណ៍ភាគហ៊ុនសម្រាប់វិនិយោគិនសារជាថ្មី។

ភាពកើនឡើង និងភាពថយចុះនៃទីផ្សាភាគហ៊ុន ក៏ដូចជាការជួញដូរភាគហ៊ុនក្នុងផ្សារភាគហ៊ុនគឺមិនអាចប៉ាន់ស្មានបានទេ។ជួនកាលការប្រែប្រួលនៃសកម្មភាពទីផ្សារពីការកើនឡើងទៅការថយចុះ និងការថយចុះទៅការកើនឡើងគឺកើតឡើងតែក្នុងកំឡុងពេល១ ទៅ ២ខែប៉ុណ្ណោះ។ផ្ទុយទៅវិញ ពេលខ្លះសកម្មភាពនេះត្រូវចំណាយពេលរាប់ឆ្នាំក្នុងការប្រែប្រួលដែលសកម្មភាពនេះត្រូវបានគេស្គាល់ថា វដ្តនៃទីផ្សារ។

សកម្មភាពកើនឡើង និងថយចុះនៃទីផ្សារភាគហ៊ុនក៏បានធ្វើអោយទីផ្សារសញ្ញាបណ្ណមានការប្រែប្រួលផងដែរ ព្រោះភាគហ៊ុននឹងសញ្ញាបណ្ណជាប្រភេទផលបត្រ (Portfolio) ដែលវិនិយោគិនប្រើប្រាស់ដើម្បីកាត់បន្ថយហានីភ័យ។ក្នុងករណីច្រើនបានបង្ហាញថានៅពេលដែលទីផ្សារសញ្ញាបណ្ណមានការកើនឡើង នោះទីផ្សារភាគហ៊ុននឹងទទួលរងការធ្លាក់ចុះ។ដូច្នេះក្នុងនាមជាវិនិយោគិនការវិនិយោគផលបត្រទៅលើប្រភេទផ្សេងៗគ្នាជាប្រការល្អក្នុងការទប់ស្កាត់ហានីភ័យនៅពេលដែលការវិនិយោគមួយក្នុងចំណោមការវិនិយោគផ្សេងៗមានការធ្លាក់ចុះ។

### គ. មូលធនីយកម្មទីផ្សារ[5]

វិនិយោគិនស្គាល់ថាក្រុមហ៊ុនខ្លះជា Large-Cap mid-cap និង small-cap។ ការរៀបរាប់បែបនេះគឺសំដៅទៅលើ Market Capitalization ឬក៏ត្រូវបានស្គាល់ថា Market cap និងជួនកាលគេហៅយ៉ាងខ្លីថាមូលធនរូបនីយកម្មទីផ្សារ (Capitalization)។ Market Cap ក៏ជាឧបករណ៍មួយដ៏សំខាន់ក្នុងការវាស់ស្ទង់ពីទំហំក្រុមហ៊ុន។ជាពិសេស វាគឺបានបង្ហាញពីតម្លៃ និងដើមទុនសរុបរបស់ក្រុមហ៊ុនគិតជាដុល្លា ដោយប្រើប្រាស់ការគុណនឹង Outstanding Shares[6] ជាមួយតម្លៃភាគហ៊ុនបច្ចុប្បន្ននៅលើទីផ្សារ។

មិនមានការកំណត់ជាក់លាក់ថេរណាមួយអំពីការកំនត់ទៅលើទំហំក្រុមហ៊ុនដែលមាន Large cap និង mid cap ហើយនិង Small Cap នោះទេ តែនៅក្រុមហ៊ុនដែលជាប្រភេទ Small Cap ជាទូទៅគឺមានដើមទុនចន្លោះពី ៥០០លានដុល្លា ទៅ ២ពាន់លានដុល្លា ចំណែកក្រុមហ៊ុនដែលជា

[5] http://www.investopedia.com/terms/m/marketcapitalization.asp ដកស្រង់ថ្ងៃទី ០២ ឧសភា ២០១៧

[6] Outstanding share គឺជាភាគហ៊ុនដែលចរាចរណ៍នៅលើទីផ្សារ ដកស្រង់ពី https://www.accountingcoach.com/stockholders-equity/explanation/2 ថ្ងៃទី ០២ ឧសភា ២០១៧

ប្រភេទ Mid Cap ជាទូទៅមានដើមទុនប្រមាណពី ២ ពាន់លាន ទៅ ១០ ពាន់លានដុល្លា និងក្រុមហ៊ុនដែលជាប្រភេទ Large Cap ជាទូទៅគឺមានដើមទុនចាប់ពី ១០ពាន់លានដុល្លាឡើងទៅ។វិនិយោគិនក៏ប្រហែលជាធ្លាប់ស្គាល់ផងដែរនូវក្រុមហ៊ុនដែលមាន Micro cap ដែលជាទូទៅក្រុមហ៊ុនប្រភេទនេះមានដើមទុនតិចជាងក្រុមហ៊ុនដែលមាន Small Cap។

## ឃ. ការពុះចំណែកបង្កើនចំនួនភាគហ៊ុន[7]

នៅពេលដែលតម្លៃភាគហ៊ុនមានការកើនឡើងខ្លាំង ក្រុមហ៊ុនត្រូវសម្រេចចិត្តធ្វើការពុះចំណែកបង្កើនចំនួនភាគហ៊ុន (Stock Splits) ដើម្បីកាត់បន្ថយតម្លៃភាគហ៊ុន។ការធ្វើបែបនេះគឺដោយសារនៅពេលដែលតម្លៃភាគហ៊ុនកើនឡើងខ្ពស់ពេក អាចធ្វើអោយវិនិយោគិនមិនសូវហ៊ានវិនិយោគទៅលើភាគហ៊ុននោះ ព្រោះវិនិយោគបានសន្និដ្ឋានថាកម្រិតនៃការកើនឡើងនៅមានកម្រិត។

ឧទាហរណ៍៖ ក្នុងករណីភាគហ៊ុនមានតម្លៃ ១៥០ ដុល្លាក្នុងមួយហ៊ុន ដោយយកមួយហ៊ុនបែងចែកជាបី នាំអោយតម្លៃបន្ទាប់ពីការបែងចែករួចស្មើ ៥០ដុល្លា។ ប្រសិនបើការវិនិយោគដោយមានភាគហ៊ុនចំនួន ១០០ហ៊ុន ស្មើនឹង ១,៥០០ដុល្លាមុនពេលកាបែងចែកហើយបន្ទាប់ពីការបែងចែកវិនិយោគិននឹងទទួលបានភាគហ៊ុនចំនួន ៣០០ ហ៊ុន ដែលក្នុងមួយហ៊ុនមានតម្លៃ ៥០វិញដោយរក្សានូវតម្លៃភាគហ៊ុនដែលវិនិយោគិនមានក្នុងដៃដដែលគឺ ១,៥០០ដុល្លា។ ក្នុងករណីភាគហ៊ុនមានតម្លៃទាប វាបានទាក់ទាញវិនិយោគអោយមកធ្វើការវិនិយោគលើភាគហ៊ុននោះ តម្លៃហ៊ុនដែលបានធ្វើការបែងចែករួចហើយ ក៏អាចមានការកើនឡើងទៅលើកត្តាថ្លៃសារជាថ្មីផងដែរ ប្រសិនជាមានតម្រូវការខ្ពស់ទៅលើភាគហ៊ុននោះ។ផ្ទុយទៅវិញវាក៏អាចរួមបញ្ចូលនូវភាគហ៊ុនវិញ (Stock Merge) ផងដែរប្រសិនបើក្នុងករណីតម្លៃភាគហ៊ុនមានការថយចុះខ្លាំងពេក។

### ១.២.១.២ ភាគហ៊ុនបុរិមា (Preferred Stock)[8]

ភាគហ៊ុនបុរិមា គឺជាភាគហ៊ុនដែលមានលក្ខណៈដូចគ្នានឹងភាគហ៊ុនធម្មតាដែរ តែអ្នកកាន់ភាគហ៊ុនបុរិមាពេលបែងចែកភាគលាភគឺទទួលបានមុនគេ ហើយត្រូវកំណត់ជាដំបូងគឺថេរ (Fixed) លើទឹកប្រាក់កំណត់មួយ។បន្ថែមពីនេះអ្នកកាន់ភាគហ៊ុនអាទិភាពពុំមានសិទ្ធបោះឆ្នោតផ្សេងៗក្នុងក្រុមហ៊ុនទេ។

ការធ្វើវិនិយោគដោយទិញភាគហ៊ុនអាទិភាព គឺទទួលបានភាគលាភថេរ (Fixed Dividend)

[7] http://www.investopedia.com/terms/s/stocksplit.asp ដកស្រង់ថ្ងៃទី ០២ ឧសភា ២០១៧

[8] https://www.accountingcoach.com/blog/what-is-preferred-stock ដកស្រង់ថ្ងៃទី ០៣ ឧសភា ២០១៧

ហើយនឹងអាចទទួលបាន Capital Gain ក្នុងករណីតម្លៃទីផ្សាររបស់ភាគហ៊ុននោះឡើងថ្លៃនៅពេលគេលក់។

### ១.២.២ មូលបត្របំណុល[9]

#### ១.២.២.១ សញ្ញាណរបស់មូលបត្របំណុល

មូលបត្របំណុល (សញ្ញាប័ណ្ណ ឬ Bond) គឺជាប័ណ្ណបំណុលមួយ ដែលអ្នកវិនិយោគផ្តល់កម្ចីទៅក្រុមហ៊ុនសាជីវកម្ម និងរដ្ឋាភិបាល ឬម៉្យាងទៀត ជាមូលបត្រដែលតំណាងអោយបំណុលរបស់អ្នកបោះផ្សាយជំពាក់អ្នកវិនិយោគដែលទិញមូលបត្រនេះ។ក្រុមហ៊ុន ឬរដ្ឋាភិបាលសន្យាថានឹងបង់ការប្រាក់ថេរ ដែលទូទាត់រៀងរាល់ឆមាស ឬរាល់ឆ្នាំ និងប្រាក់ដើមត្រឡប់មកវិញនៅចុងកាលកំណត់ (Maturity) ដែលបានចារលើប័ណ្ណនេះដែលហៅថា Coupon Payment អោយអ្នកវិនិយោគ ហើយអត្រាការប្រាក់លើប័ណ្ណនេះហៅថា Coupon Rate ហើយនឹងទឹកប្រាក់ដែលដែលក្រុមហ៊ុនត្រូវទូទាត់ទៅម្ចាស់ ឬអ្នកកាន់សញ្ញាប័ណ្ណនៅចុងការិយបរិច្ឆេត ហៅថា Face Value ឬ par Value ។ ដូច្នេះការវិនិយោគលើមូលបត្របំណុលជាការវិនិយោគទទួលបានចំណូលថេរ។ មូលបត្របំណុលមានពីរគឺ មូលបត្របំណុលរយៈពេលវែង និងមូលបត្របំណុលរយៈពេលខ្លី ។មូលបត្របំណុលរយៈពេលខ្លី មានប័ណ្ណរតនាគារ (T Bill) ដែលការជួញដូរជាទូទៅមានរយៈពេលក្រោមមួយឆ្នាំនៅក្នុងទីផ្សារហិរញ្ញវត្ថុ។មូលបត្របំណុលរយៈពេលវែងមានដូចជា Long term government note និង Bonds Municipal Bonds សញ្ញាប័ណ្ណអាជីវកម្មដែលការជួញដូរចាប់ពី១ឆ្នាំឡើងទៅនៅក្នុងទីផ្សារមូលធន។

+រូបមន្តសម្រាប់គណនា Coupon Rate

Coupon Rate = Annual Coupon/Face Value

+រូបមន្តសម្រាប់គណនា Current Yield

Current Yield = Annual Coupon / Bond Price or Market Price

+រូបមន្តសម្រាប់គណនា Bond Value

$$\text{Bond Value} = \sum_{i=1}^{n} \frac{C}{(1+YTM)^n} + \frac{FV}{(1+YTM)^n}$$

[9] http://www.investopedia.com/terms/b/bond.asp ដកស្រង់ថ្ងៃទី ០៣ ឧសភា ២០១៧

ដែល

C: Coupon ដែលគេទូទាត់អោយក្នុងមួយពេល

FV: Face Value នៅ maturity

n: ពេលវេលាដល់ Maturity

YTM: Yield to Maturity ដែលអត្រាមានទៅតាមទីផ្សារលើសញ្ញាប័ណ្ណ ឫគេអាចសរសេររូបមន្ត

$$\text{Bond Value} = \frac{C}{YTM}\left[1 - \frac{1}{(1+YTM)^n}\right] + \frac{FV}{(1+YTM)^n}$$

តាមទំនាក់ទំនងរវាងសញ្ញាប័ណ្ណ និងអត្រាការប្រាក់ ពេលដែលអត្រាការប្រាក់កើនឡើង តម្លៃសញ្ញាប័ណ្ណជាទូទៅធ្លាក់ចុះ ហើយពេលអត្រាការប្រាក់ធ្លាក់ចុះ តម្លៃសញ្ញាប័ណ្ណជាទូទៅកើនឡើង។

**១.២.២.២ ទិន្នផលនៃមូលបត្របំណុល**

ទិន្នផល (Yield) គឺជាន័យមួយដែលទាក់ទងនឹងផលត្រលប់លើមូលធនដែលអ្នកវិនិយោគក្នុងសញ្ញាប័ណ្ណទទួលបាន។ នៅក្នុងការវិនិយោគលើសញ្ញាប័ណ្ណអ្វីដែលយើងត្រូវដឹងនោះគឺ៖

+Coupon Yield គឺអត្រាការប្រាក់ ដែលត្រូវបានផ្តល់ឡើងពេលសញ្ញាប័ណ្ណបោះផ្សាយ។វាមានលក្ខណៈដូចនឹង Coupon Rate ហើយគឺជាចំនួននៃប្រាក់ចំណូលដែលទទួលបានពីសញ្ញាប័ណ្ណដោយបង្ហាញជាភាគរយ។ ឧទាហរណ៍ បើអ្នកទិញសញ្ញាប័ណ្ណមួយដែលមានតម្លៃ ១០០០ ដុល្លា និងទទួលបានការទូទាត់ការប្រាក់ប្រចាំឆ្នាំ ៩៥ដុល្លា ដូចនេះ Coupon yield គឺ៩.៥%។

+Current Yield គឺ Coupon Yield របស់សញ្ញាប័ណ្ណចែកនឹងតម្លៃទីផ្សាររបស់សញ្ញាប័ណ្ណ។

+Yield to Maturity (YTM) គឺជាអត្រាការប្រាក់សរុបដែលរកបានដោយអ្នកវិនិយោគម្នាក់ទិញសញ្ញាប័ណ្ណនៅតម្លៃទីផ្សារ និងកាន់សញ្ញប័ណ្ណរហូតដល់ចុងកាលកំណត់ដែលត្រូវសង។

ដូចនេះថ្លៃសញ្ញាប័ណ្ណ និង Yield គឺមានទំនាក់ទំនងផ្ទុយគ្នា បើថ្លៃរបស់សញ្ញាប័ណ្ណកើនឡើងនោះ Yield គឺធ្លាក់ចុះ និងផ្ទុយមកវិញ។

## ១.៣ ទីផ្សារមូលបត្រ[10]

ទីផ្សារមូលបត្រ គឺជាតំបន់ដែលអនុញ្ញាតអោយអ្នកផ្គត់ផ្គង់ និងអ្នកមានតម្រូវការនៃមូលបត្រដើម្បីធ្វើប្រតិបត្តិការហិរញ្ញវត្ថុ។ ពួកគេធ្វើអោយប្រតិបត្តិការគឺមានភាពឆាប់រហ័សជាមួយនឹងថ្លៃ

[10] Fundamentals of Investing, LAWRENCE J. GITMAN and MICHAEL JOEHNK, 9th Edition ទំព័រ ៣៦ ដល់ ៤៣

ត្រឹមត្រូវមួយ។នៅក្នុងវិស័យនេះយើងនឹងសង្កេតឃើញមានប្រភេទផ្សេងៗគ្នានៃទីផ្សារ ស្ថាប័ន និងបុគ្គលិកលក្ខណៈទូទៅរបស់ពួកគេ។

### ១.៣.១ ប្រភេទនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រជាទូទៅត្រូវបានគេកត់សម្គាល់ថាជាទីផ្សារសាច់ប្រាក់ ឬទីផ្សារមូលធន។ ទីផ្សារសាច់ប្រាក់ គឺជាទីផ្សារដែលមូលបត្ររយៈពេលខ្លី (មានរយៈពេលតិចជាងមួយឆ្នាំ)ត្រូវបានជួញដូរ។ អ្នកវិនិយោគភាគច្រើនងាកមករកការវិនិយោគក្នុងទីផ្សារមូលធនដើម្បីបង្កើតប្រតិបត្តិការទាក់ទងនឹងមូលបត្ររយៈពេលវែង (មានរយៈពេលច្រើនជាងមួយឆ្នាំ)ដូចជាភាគហ៊ុន និងសញ្ញាប័ណ្ណជាដើម។

ដោយសារតែការវិនិយោគភាគច្រើនវិនិយោគិនជ្រើសរើសការវិនិយោគក្នុងទីផ្សារមូលធន ទើបគេឃើញមានការបែងចែកទីផ្សារនេះជាពីរទៀតគឺ ទីផ្សារមូលធនបឋម (Primary Market) និងទីផ្សារមូលធនបន្ទាប់ (Secondary Market)។

ទីផ្សារមូលធនបឋម (Primary Market) គឺជាទីផ្សារដែលការបោះផ្សាយថ្មីនៃមូលបត្រត្រូវបានដាក់លក់ជាសាធារណៈ។ នៅក្នុងទីផ្សារមូលធនបឋម អ្នកបោះផ្សាយមូលបត្រទ្រព្យ និងបំណុលភាគច្រើនគឺទទួលបានភាពជោគជ័យក្នុងការលក់។នៅក្នុងឆ្នាំ ២០០៣ មានតែក្រុមហ៊ុន៧៩ ប៉ុណ្ណោះដែលបោះផ្សាយភាគហ៊ុនលក់ក្នុងទីផ្សារមូលធនបឋម។ចំនួននេះត្រូវបានប្រៀបធៀបជាមួយក្រុមហ៊ុនចំនួន ៥៥២ ដែលបើកដំណើរការជាសាធារណៈ។

ទីផ្សារមូលធនបន្ទាប់ (Secondary Market) គឺជាទីផ្សារដែលមូលបត្រត្រូវបានគេជួញដូរបន្ទាប់ពីពួកគេបានបោះផ្សាយលក់។ ទីផ្សារមូលធនបន្ទាប់ ផ្តល់ជាមាគ៌ាមួយសម្រាប់ម្ចាស់នៃមូលបត្រដែលបានបោះផ្សាយហើយ ដើម្បីលក់ពួកវាទៅកាន់អ្នកផ្សេងទៀត។ នៅក្នុងទីផ្សារមូលធនបន្ទាប់ វាមិនដូចនឹងទីផ្សារមូលធនបឋមទេ ដោយសារតែប្រតិបត្តិការរបស់វាមិនពាក់ព័ន្ធជាមួយក្រុមហ៊ុនសាជីវកម្មដែលបោះផ្សាយមូលបត្រ។ផ្ទុយទៅវិញ លុយ និងមូលបត្រត្រូវបានប្តូររវាងវិនិយោគិន មានន័យថាអ្នកលក់ដូរមូលបត្រជាមួយលុយដែលទូទាត់ដោយអ្នកទិញ។ទីផ្សារមូលធនបន្ទាប់ក៏ផ្តល់ជាយន្តការសម្រាប់ការបន្តនៃថ្លៃ (កើនឡើង ឬថយចុះ) នៃមូលបត្រដែលបង្ហាញពីតម្លៃរបស់វានៅចំណុចនីមួយៗដោយផ្អែកលើមូលដ្ឋាននៃពត៌មានដ៏ល្អបំផុត បន្ទាប់មកវានឹងត្រូវបានគេជួញដូរ។

ទីផ្សារមូលធនបន្ទាប់បានរួមបញ្ចូលនូវប្រភេទនៃស្ថាប័នប្តូរមូលបត្រ និងទីផ្សារ OTC (Over the counter market) ។

### ១.៣.២ ស្ថាប័នប្តូរមូលបត្រ (Organized security Exchanges)

ស្ថាប័នប្តូរមូលបត្រ គឺជាស្ថាប័នកណ្តាលមួយដែលជម្រុញការផ្គត់ផ្គង់ និងតម្រូវការនៃមូលបត្រដែលត្រូវបានជួញដូរច្រើនក្នុងទីផ្សារ។ស្ថាប័នទាំងអស់នេះគឺជាទីផ្សារដេញថ្លៃ ដែលលំហូរនៃការទិញ និងលក់បញ្ជាត្រូវត្រួតពិនិត្យដោយថ្លៃ។

### ១.៣.៣ ទីផ្សារ OTC (Over the counter market)

ទីផ្សារ OTC គឺជាទីផ្សារមួយនៃប្រព័ន្ធទំនាក់ទំនងដែលគ្រប់ប្រតិបត្តិការត្រូវបានបង្កើតឡើងទាំងក្នុងការជួញដូរ IPO[11] និង មូលបត្រដែលត្រូវបានគេជួញដូរច្រើនក្នុងទីផ្សារ។ទីផ្សារ OTC គឺជាទីផ្សារចែកចាយប្រើប្រាស់ប្រព័ន្ធកំណត់តម្លៃ ដែលការចរចា និងតម្លៃចែកចាយ ត្រួតពិនិត្យទៅលើថ្លៃ។

## ១.៤ ប្រភេទនៃប្រតិបត្តិការមូលបត្រ

### ១.៤.១ Long Purchase

Long Purchase គឺជាប្រតិបត្តិការដែលវិនិយោគិនទិញមូលបត្រដែលពួកគេសង្ឃឹមថាថ្លៃមូលបត្រនឹងកើនឡើង ហើយអាចលក់នៅថ្ងៃក្រោយដើម្បីទទួលបានប្រាក់ចំណេញ។ គោលបំណងជារួមគឺ ទិញថោក លក់ថ្លៃ។ Long Purchase គឺជាប្រតិបត្តិការដែលគេប្រើប្រាស់ច្រើនជាងគេ ពីព្រោះវិនិយោគិនជាទូទៅរំពឹងថាថ្លៃនៃមូលបត្រ នឹងបន្តកើនឡើងនៅក្នុងកំឡុងពេលដែលពួកគេកាន់កាប់វា។ជាទូទៅប្រាក់ចំណេញរបស់ពួកគេទទួលបានពីភាគលាភ ឬការប្រាក់ដែលទទួលក្នុងកំឡុងពេលជាម្ចាស់កម្មសិទ្ធរបស់ពួកគេ បន្ថែមពីនេះក៏មានការខាត ឬចំណេញនៅចន្លោះថ្លៃដែលពួកគេលក់មូលបត្រ និងថ្លៃដែលពួកគេចំណាយសម្រាប់ទិញវា។

### ១.៤.២ ការជួញដូរមានកម្រិតកំណត់ (Margin Trading)

ការទិញមូលបត្រជាទូទៅមិនផ្តោតតែលើការមានសាច់ប្រាក់សុទ្ធនោះទេ វិនិយោគិនអាចខ្ចីទុនបន្ថែមបាន។សកម្មភាពនេះសំដៅដល់ការជួញដូរមានកម្រិតកំណត់ ។វាក៏ត្រូវបានប្រើប្រាស់ក្នុងហេតុផលមួយគឺ ការពង្រីកប្រាក់ចំណេញ។ដែលទឹកប្រាក់ពិតរបស់អ្នកវិនិយោគ (Margin) ត្រូវគិតជាភាគរយ។ឧទាហរណ៍ បើសិនជាវិនិយោគិនមាន ៧៥%នៃទឹកប្រាក់ពិតរបស់ពួកគេគឺមានន័យថា ៧៥%នៃការវិនិយោគគឺជាទុនដែលវិនិយោគិនមានស្រាប់ ហើយ ២៥%ទៀតគឺសមតុល្យនៃប្រាក់ដែលពួកគេបានខ្ចី។ ភ្នាក់ងារកម្រៃជើងសារត្រូវតែអនុម័តទៅលើការបញ្ជាទិញមានកម្រិតកំណត់។ក្រុមហ៊ុនកម្រៃជើងសារអោយវិនិយោគិនខ្ចីនូវទុនដែលពួកគេខ្វះខាត ហើយរក្សាទុកនូវ

---

[11] IPO (Initial Public Offering) គឺជាការលក់ជាសាធារណៈលើកដំបូងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។ ដកស្រង់ចេញពីសៀវភៅ Fundamentals of Investing, LAWRENCE J. GITMAN and MICHAEL JOEHNK, 9th Edition ទំព័រ ៣៦

មូលបត្រដែលបានបញ្ចាទិញជាវត្ថុតំកល់។វាមានសារៈសំខាន់ណាស់ក្នុងការកំណត់ចំនាំថាវិនិយោគិនត្រូវតែទូទាត់នូវអត្រាការប្រាក់ជាក់លាក់នៃទឹកប្រាក់ដែលពួកគេបានខ្ចី។

### ១.៤.៣ ការលក់មូលបត្ររយៈពេលខ្លី (Short Selling)[12]

អ្នកវិនិយោគដែលទិញភាគហ៊ុនរក្សាទុកក្នុងគោលបំណងទទួលបានភាគលាភត្រូវបានគេចាត់ទុកថាជាភាគហ៊ុនរយៈពេលវែង ឬស្ថានភាពវែង។ផ្ទុយទៅវិញបើអ្នកវិនិយោគគេអាចឆ្លៀតយកចំណេញតាមរយៈការទិញភាគហ៊ុនហើយលក់ចេញទៅវិញក្នុងរយៈពេលដ៏ខ្លី។គេចាត់ទុកប្រតិបត្តិការលក់នេះថា ស្ថានភាពខ្លី (Short Position)។អ្នកវិនិយោគលើភាគហ៊ុនរយៈពេលវែងនឹងទទួលបានប្រាក់ចំណេញប្រសិនបើតម្លៃរបស់ភាគហ៊ុននោះកើនឡើង ហើយគាត់នឹងមានការខាតបង់នៅពេលថ្លៃភាគហ៊ុនធ្លាក់ចុះ។

- មូលដ្ឋាននៃការលក់មូលបត្ររយៈពេលខ្លី
  - •អ្នកអាចលក់ប័ណ្ណភាគហ៊ុនដែលមិនមែនជារបស់អ្នកបាន
  - •អ្នកអាចខ្ចីប័ណ្ណភាគហ៊ុនពីក្រុមហ៊ុនជើងសាររបស់អ្នកហើយអ្នកលក់ប័ណ្ណភាគហ៊ុននោះ
  - •អ្នកអាចរកទិញប័ណ្ណភាគហ៊ុនដូចគ្នានឹងភាគហ៊ុនដែលបានខ្ចី សងត្រលប់ទៅក្រុមហ៊ុនជើងសាររបស់អ្នកវិញតាមកាលបរិច្ឆេទកំណត់។

## ១.៥ ការផាត់ទាត់ និងការទូទាត់[13]

### ១.៥.១ ការផាត់ទាត់

ការផាត់ទាត់គឺជាដំណើរការនៃការធ្វើបច្ចុប្បន្នភាពនៃគណនីរបស់ភាគីពាណិជ្ជកម្មនិងរៀបចំសម្រាប់ការផ្ទេរប្រាក់និងមូលបត្រ។ ការផាត់ទាត់មានពីរប្រភេទ គឺ ការផាត់ទាត់ទ្វេភាគីនិងមជ្ឈិមផាត់ទាត់។ ការផាត់ទាត់ទ្វេភាគីភាគីនានានៃប្រតិបត្តិការ ត្រូវឆ្លងកាត់ជំហានដែលចាំបាច់ស្របច្បាប់ដើម្បីផាត់ទាត់ប្រតិបត្តិការនេះ។ មជ្ឈិមផាត់ទាត់ត្រូវការភាគីទីបី និងជាធម្មតាត្រូវការភ្នាក់ងារផាត់ទាត់មួយ ដើម្បីផាត់ទាត់ការជួញដូរ។ ភ្នាក់ងារផាត់ទាត់ត្រូវបានប្រើប្រាស់ជាទូទៅដោយសមាជិកដែលមានភាគហ៊ុននៅក្នុងស្ថាប័ននោះ។ សមាជិកជាទូទៅគឺឈ្មួញកណ្តាល។ មានតែសមាជិកទេដែលអាចប្រើប្រាស់សេវាកម្មផាត់ទាត់ប្រាក់ដោយផ្ទាល់។ អតិថិជនលក់រាយនិងឈ្មួញជើងសារផ្សេងទៀតទទួលបានការចូលប្រើប្រាស់ដោយមានគណនីជាមួយក្រុមហ៊ុនជាសមាជិក។ ក្រុមហ៊ុនជាសមាជិកត្រូវមានការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុចំពោះភ្នាក់ងារផាត់ទាត់សម្រាប់ប្រតិបត្តិការដែលត្រូវបានទូទាត់។ វាជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនជាសមាជិកដើម្បី

[12] មូលដ្ឋានគ្រឹះនៃការវិនិយោគ, លោកសាស្ត្រាចារ្យ ឈាង ហ៊ុយ (2015-2016), ទំព័រទី២៩

[13] http://thismatter.com/money/stocks/settlement-and-clearing.htm ចូលដកស្រង់ថ្ងៃទី ២០ មិថុនា ឆ្នាំ ២០១៧។

ធានាថាមូលបត្រអាចរកបានសម្រាប់ការផ្ទេរប្រាក់ហើយប្រាក់ចំណេញគ្រប់គ្រាន់ត្រូវបានប្រកាស ឬការទូទាត់ត្រូវបានធ្វើឡើងដោយអតិថិជនរបស់ក្រុមហ៊ុន។ បើមិនដូច្នេះទេក្រុមហ៊ុនជាសមាជិកនឹងត្រូវប្រឈមមុខនឹងកង្វះខាតណាមួយ។ ប្រសិនបើក្រុមហ៊ុនជាសមាជិកមិនអាចក្លាយជាអ្នកដែលមិនអាចសងបំណុលផ្នែកហិរញ្ញវត្ថុបាននោះមានតែភតិសន្យាទេដែលអាចទូទាត់សងនូវកំហុសឆ្គងណាមួយនៅក្នុងប្រតិបត្តិការ។

ចំពោះមូលបត្រដែលអាចផ្ទេរបាន ភ្នាក់ងារផាត់ទាត់ប្រមូលសរុបការជួញដូរពីសមាជិកនីមួយៗរបស់ខ្លួននិងបណ្តាញប្រតិបត្តិការសម្រាប់ថ្ងៃជួញដូរ។ នៅចុងបញ្ចប់នៃថ្ងៃជួញដូរមានតែការទូទាត់សុទ្ធនិងមូលបត្រប៉ុណ្ណោះដែលត្រូវបានផ្លាស់ប្តូររវាងសមាជិកនៃការិយាល័យទូទាត់។ សម្រាប់ជម្រើសនិងអនាគតនិងប្រភេទផ្សេងទៀតនៃឧបករណ៍ហិរញ្ញវត្ថុ ភ្នាក់ងារផាត់ទាត់នឹងធ្វើជាដៃគូជាមួយទាំងអ្នកទិញនិងអ្នកលក់ដូច្នេះប្រតិបត្តិការអាចត្រូវបានធានាដោយស្មើរតែលុបបំបាត់ហានិភ័យនៃដៃគូ។ លើសពីនេះទៀតការិយាល័យទូទាត់កត់ត្រារាល់ប្រតិបត្តិការទាំងអស់ដោយសមាជិករបស់ខ្លួនដោយផ្តល់នូវស្ថិតិមានប្រសិទ្ធភាពក៏ដូចជាអនុញ្ញាតឱ្យមានការត្រួតពិនិត្យនិយ័តកម្មនៃប្រតិបត្តិការផងដែរ។

**១.៥.២ ការទូទាត់**

ការទូទាត់គឺជាការផ្លាស់ប្តូរជាក់ស្តែងនៃប្រាក់និងមូលបត្ររវាងភាគីនៃការដោះដូរពាណិជ្ជកម្មនៅកាលបរិច្ឆេទទូទាត់បន្ទាប់ពីបានឯកភាពលើពាណិជ្ជកម្ម។ ការទូទាត់ភាគច្រើនបំផុតនៃការជួញដូរមូលបត្រសព្វថ្ងៃត្រូវបានធ្វើដោយប្រព័ន្ធអេឡិចត្រូនិច។ ការជួញដូរភាគហ៊ុនត្រូវបានទូទាត់ក្នុងរយៈពេល 3 ថ្ងៃនៃថ្ងៃធ្វើការ (T + 3) ខណៈពេលដែលសញ្ញាប័ណ្ណរបស់រដ្ឋាភិបាលត្រូវបានទូទាត់នៅថ្ងៃធ្វើការបន្ទាប់ (T + 1) ។ ប្រតិបត្តិការ Forex ដែលរូបិយប័ណ្ណមកពីបណ្តាប្រទេសអាមេរិកខាងជើងមានកាលបរិច្ឆេទទូទាត់ T + 1 ខណៈពេលដែលការជួញដូរដែលទាក់ទងនឹងរូបិយប័ណ្ណនៅក្រៅអាមេរិកខាងជើងមានកាលបរិច្ឆេទទូទាត់ T + 2 ។ ក្នុងពេលអនាគតការទូទាត់សំដៅទៅលើការកត់សំគាល់ចំពោះទីផ្សារនៃគណនីដោយប្រើតម្លៃបិទចុងក្រោយនៃថ្ងៃ។ ការទូទាត់នៅពេលអនាគតអាចនាំឱ្យមានលទ្ធផលនៃ Margin Call[14] បើសិនជាមិនមានថវិកាគ្រប់គ្រាន់សម្រាប់ត្រៀមទូទាត់នូវថ្លៃបិទចុងក្រោយថ្មី។

[14] Margin Call កើតឡើងក្នុងករណីដែលទឹកប្រាក់ Margin ថយចុះក្រោមឬទាបជាង ៣០%នៃតម្លៃទីផ្សាររបស់ភាគហ៊ុន។ ដកស្រង់ពី មូលដ្ឋានគ្រឹះនៃការវិនិយោគ, លោកសាស្ត្រាចារ្យ ឈាង ហ៊ុយ (2015-2016), ទំព័រទី២៧

ការទូទាត់ និងការផាត់ទាត់នាពេលបច្ចុប្បន្នបានវិវត្តទៅជាវិបត្តិក្រដាសនៃការជួញដូរមូលបត្រខណៈដែលប័ណ្ណភាគហ៊ុននិងប័ណ្ណបំណុលកាន់តែច្រើនត្រូវបានគេជួញដូរនៅក្នុងឆ្នាំ ១៩៦០ និង ១៩៧០ ហើយការទូទាត់ត្រូវបានធ្វើឡើងដោយការត្រួតពិនិត្យក្រដាស។ ឈ្មួញកណ្តាលនិងឈ្មួញត្រូវប្រើអ្នកនាំសារឬសំបុត្រដើម្បីផ្ញើវិញ្ញាបនប័ត្រនិងការត្រួតពិនិត្យដើម្បីដោះស្រាយការជួញដូរដែលបង្កហានិភ័យដ៏ធំមួយនិងបានចំណាយថ្លៃប្រតិបត្តិការខ្ពស់បំផុត។

ដំណោះស្រាយទីមួយ ចំពោះបញ្ហានេះគឺត្រូវរក្សាទុកវិញ្ញាបនប័ត្រនៅឯមជ្ឈមណ្ឌលរក្សាទុកមូលបត្រ ជូនកាលសំដៅទៅលើការរក្សាទុកវិញ្ញាបនប័ត្រនិងការផ្លាស់ប្តូរកម្មសិទ្ធិជាមួយប្រព័ន្ធគណនេយ្យចុះនិន្នានុប្បវត្តន៍ដែលត្រូវបានធ្វើជាអេឡិចត្រូនិច។ ផ្សារភាគហ៊ុនញូវយ៉កគឺជាទីផ្សារទីមួយ ដែលប្រើប្រាស់វិធីសាស្ត្រនេះ ដែលក្រោយមកក្លាយជាក្រុមហ៊ុន Depository Trust បន្ទាប់មកក្លាយជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Depository Trust និង Clearing Corporation (DTCC) ។

# ជំពូកទី២
# ទីផ្សារមូលបត្រកម្ពុជា

# ជំពូកទី២

# ទីផ្សារមូលបត្រកម្ពុជា

## ២.១ ប្រវត្តិសង្ខេបនៃទីផ្សារមូលបត្រកម្ពុជា[15]

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជាដោយឈរលើគោលដៅក្នុងការជំរុញកំនើនសេដ្ឋកិច្ច តាមរយៈលំហូរមូលធន ការវិនិយោគ និង ការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែ វិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះ ហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកអោយដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅ ខែកញ្ញា ឆ្នាំ ២០០៧។ នៅឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារ មូលបត្រកូរ៉េ។ នៅខែ មីនា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ )Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ ) "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" )ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១០។ ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនចម្រុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់កាប់ភាគហ៊ុនចំនួន៥៥ភាគរយនៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន៤៥ភាគរយនៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាប័ណ្ណជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក)ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន។

- **ចក្ខុវិស័យ និងបេសកកម្ម**

[15] ប្រវត្តិទីផ្សារមូលបត្រកម្ពុជា http://csx.com.kh/kh/about/profile.jsp?MNCD=10301 ចូលដកស្រង់ថ្ងៃទី ០១ ឧសភា ឆ្នាំ ២០១៧។

**ក. ចក្ខុវិស័យ**

ទីផ្សារមូលបត្រកម្ពុជាមានចក្ខុវិស័យជាក់លាក់មួយ គឺដើម្បីកសាងនូវមហាវិថីហិរញ្ញវត្ថុសម្រាប់កម្ពុជា។

**ខ. បេសកកម្ម**

ទីផ្សារមូលបត្រកម្ពុជាមានបេសកម្មសម្រាប់ដំណើរការទីផ្សាររបស់ខ្លួនដូចជា៖

+ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា

+ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់អ្នកវិនិយោគិនទាំងក្នុង និងក្រៅប្រទេស

+ដើម្បីបង្កើតផលិតផលនិងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់

+ដើម្បីដាក់អោយដំណើរការនូវសហគ្រាសសាធារណៈមួយដែលមានស្វ័យចិរភាពក្រោមមគ្គុទេសក៏ដឹកនាំរបស់រដ្ឋាភិបាលកម្ពុជា។

**+ស្លាកសញ្ញា**

## ២.២ ប្រតិបត្តិការរបស់ផ្សារមូលបត្រកម្ពុជា[16]

### ២.២.១ ម៉ោងជួញដូរមូលបត្រ

ផ្សារហ៊ុនចាប់បើកទទួលបញ្ជាទិញ/លក់ពីវិនិយោគិនពីម៉ោង ០៨:០០ ព្រឹក និងបិទនៅម៉ោង ១១:៣០ ព្រឹក។ ប៉ុន្តែ ការជួញដូរចាប់ធ្វើឡើងពីម៉ោង ០៩:០០ ដល់ម៉ោង ១១:០០ ព្រឹក និងនៅម៉ោង ១១:៣០ ព្រឹក ម្តងទៀតមុនពេលបិទផ្សារ។

[16] ប្រតិបត្តិការទីផ្សារមូលបត្រ http://csx.com.kh/operation/market/listPosts.do?MNCD=3020 ចូលដកស្រង់ថ្ងៃទី ១២ ឧសភា ឆ្នាំ ២០១៧។




### ២.២.២ ថ្ងៃជួញដូរ

ថ្ងៃជួញដូរចាប់ផ្ដើមពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ។

### ២.២.៣ ប្រភេទនៃបញ្ជា

បច្ចុប្បន្ន មានបញ្ជាតែមួយប្រភេទប៉ុណ្ណោះនៅផ.ម.ក. គឺ "បញ្ជាមានកំណត់"។

**បញ្ជាមានកំណត់៖** បញ្ជាដែលថ្លៃទិញគឺជាថ្លៃហ៊ានទិញខ្ពស់បំផុត ឬបញ្ជាដែលថ្លៃលក់គឺជាថ្លៃហ៊ានលក់ទាបបំផុត។

ឧទាហរណ៍៖ បញ្ជាទិញមានកំណត់មួយដែលមានថ្លៃ៥០,០០០រៀល អាចនឹងត្រូវបានជួញដូរនៅថ្លៃ៥០,០០០រៀលឬថោកជាងនេះ ហើយចំណែកឯបញ្ជាលក់មានកំណត់ដែលមានថ្លៃ៥០,០០០រៀល អាចនឹងត្រូវបានជួញដូរនៅថ្លៃ ៥០,០០០រៀលឬខ្ពស់ជាងនេះ។

### ២.២.៤ ថ្លៃមូលដ្ឋាន

ជាទូទៅថ្លៃមូលដ្ឋានគឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។

ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ដំបូងត្រូវស្ថិតនៅចន្លោះ៥០% និង១៥០% នៃថ្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ជាលើកដំបូង (ថ្លៃ IPO ដែលបានកំណត់នៅក្នុងឯកសារផ្ដល់ព័ត៌មានដែលបានចុះបញ្ជីនៅ គ.ម.ក.)។

ក្នុងករណីដែលមានសិទ្ធិកម្មសិទ្ធិករមូលបត្រដូចជា ការបង្កើនឬបន្ថយមូលធន ការបែងចែកភាគលាភជាភាគហ៊ុន ការបំបែកភាគហ៊ុន ។ល ។ នោះថ្លៃមូលដ្ឋាននឹងត្រូវបានគណនាដោយស្វ័យប្រវត្តិ ដោយប្រព័ន្ធរបស់ ផ.ម.ក.តាមរយៈការប្រើប្រាស់នូវរូបមន្តមួយជាក់លាក់។ក្នុងករណីថ្លៃមូលបត្រដែលបានគណនា ទាបជាងឯកតាគម្លាតថ្លៃ នោះថ្លៃមូលដ្ឋានត្រូវបង្គត់ឡើងឲ្យស្មើនឹងឯកតាគម្លាតថ្លៃ។

### ២.២.៥ ឯកតាជួញដូរ និងឯកតាគម្លាតថ្លៃ

ឯកតាបញ្ជាមូលបត្រកម្មសិទ្ធិនៅផ.ម.ក. គឺ ០១ (មួយ)ឯកតាមូលបត្រ។

បរិមាណជួញដូរមូលបត្រកម្មសិទ្ធិអប្បបរមាក្នុងមួយប្រតិបត្តិការ នៅផ.ម.ក. គឺ ០១(មួយ) ឯកតាមូលបត្រ។

ថ្លៃប្រែប្រួលទៅតាមឯកតាថ្លៃ (ឯកតាគម្លាតថ្លៃ) ដែលត្រូវបានកំណត់ដូចខាងក្រោម(ទឹកប្រាក់ទាំងអស់គិតជារៀល)៖

| ថ្លៃ (P) | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាដែលខុស | ឧទាហរណ៍ថ្លៃបញ្ជាដែលត្រឹមត្រូវ |
|---|---|---|---|
| ]០ – ៤.០០០[ | ១០ | ២.៥៥៥; ៣.០១២; ៣.៩៩៩ | ២.៥៥០; ២.៥៦០; ៣.០១០; ៣.០២០; ៣.៩៩០ |
| [៤.០០០ – ២០.០០០[ | ២០ | ៤.២១០; ១៩.៥២៥ | ៤.២០០; ៤.២២០; ១៩.៥២០; ១៩.៥៤០ |
| [២០.០០០ – ៤០.០០០[ | ៥០ | ២០.១១០; ៣៥.៥៣០ | ២០.១០០; ២០.១៥០; ៣៥.៥០០; ៣៥.៥៥០ |
| [៤០.០០០ – ១០០,០០០[ | ១០០ | ៥០.៧២០; ៦០.៨៥០ | ៥០.៧០០; ៥០.៨០០; ៦០.៨០០; ៦០.៥០០ |
| [១០០.០០០ – ២០០.០០០[ | ២០០ | ១៥០.៥០០; ១២៥.៣០០ | ១៥០.៨០០; ១៥០.៦០០; ១២៥.២០០; ១២៥.៨០០ |
| [២០០.០០០ – ៤០០.០០០[ | ៥០០ | ៣០០.១០០; ៣៥០.២០០ | ៣០០.០០០; ៣០០.៥០០; ៣៥០.០០០; ៣៥០.៥០០ |
| [៤០០.០០០ – [ | ១.០០០ | ៦២០.៥០០; ៨៥២.១០០ | ៦២០.០០០; ៦២១.០០០; ៨៥២.០០០; ៨៥៣.០០០ |

### ២.២.៦ ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃ

ដែនកំណត់នៃបម្រែបម្រួលថ្លៃប្រចាំថ្ងៃត្រូវស្មើនឹង ±៥% (បូក/ដកប្រាំភាគរយ)នៃថ្លៃមូលដ្ឋាន។

+ករណីទី១ ថ្លៃមូលដ្ឋាន = ១២,០០០៛



១២,០០០៛ x ៥% = ៦០០

១២,០០០៛ + ៦០០= ១២,៦០០៛ ដែនកំណត់ថ្លៃខាងលើ

១២,០០០៛ - ៦០០ = ១១,៤០០៛ ដែនកំណត់ថ្លៃខាងក្រោម

+ករណីទី២ ថ្លៃមូលដ្ឋាន = ៤,០០០៛

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| ដែនកំណត់ថ្លៃខាងលើ (+៥%) | ៤.២០០ | |
| | ៤.១៨០ | |
| | : | ឯកតាគម្លាតថ្លៃ ២០៛ |
| | ៤.០២០ | |
| ថ្លៃមូលដ្ឋាន | ៤.០០០ | |
| | ៣.៩៩០ | |
| | : | ឯកតាគម្លាតថ្លៃ ១០៛ |
| | ៣.៨១០ | |
| ដែនកំណត់ថ្លៃខាងក្រោម (-៥%) | ៣.៨០០ | |

៤,០០០៛ x ៥% = ២០០

៤,០០០៛ + ២០០= ៤,២០០៛ ដែនកំណត់ថ្លៃខាងលើ

៤,០០០៛ - ២០០ = ៣,៨០០៛ ដែនកំណត់ថ្លៃខាងក្រោម

+ករណីទី៣ ថ្លៃមូលដ្ឋានទាបជាង ២០០៛

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| ដែនកំណត់ថ្លៃខាងលើ (+៥%) | ១៦០ | |
| ថ្លៃមូលដ្ឋាន | ១៥០ | ឯកតាគម្លាតថ្លៃ ១០៛ |
| ដែនកំណត់ថ្លៃខាងក្រោម (-៥%) | ១៤០ | |

១៥០៛ x ៥% = ៧.៥៛ => ១០៛

១៥០៛ + ១០= ១៦០៛ ដែនកំណត់ថ្លៃខាងលើ

១៥០៛ - ១០ = ១៤០៛ ដែនកំណត់ថ្លៃខាងក្រោម

### ២.២.៧ សុពលភាពនៃបញ្ជា

បញ្ជានីមួយៗមានសុពលភាពចាប់ពីពេលដែលទទួលបាននៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. រហូតដល់ពេលដែលបញ្ជានោះត្រូវបានអនុវត្តនៅអំឡុងវគ្គជួញដូរនៃថ្ងៃតែមួយ។

### ២.២.៨ ការកែប្រែ និងការលុបចោលបញ្ជាដែលបានបញ្ជូន

ការកែប្រែឬការលុបចោលបញ្ជាអាចធ្វើទៅបាន ដរាបណាបញ្ជានោះមិនទាន់ត្រូវបានអនុវត្ត។ ពេលវេលាបញ្ជាក់ពីការទទួលបញ្ជានៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ត្រូវកំណត់សាជាថ្មី នៅពេលដែលមានការកែប្រែថ្លៃឬ ការបង្កើនបរិមាណនៃបញ្ជា។

### ២.២.៩ គោលការណ៍ដេញថ្លៃ

រាល់ការជួញដូរទាំងអស់ត្រូវបានអនុវត្តតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃ ដោយយកថ្លៃតែមួយ។

- **អាទិភាពនៃបញ្ជាទិញ និងបញ្ជាលក់**

**១. ថ្លៃ**

បញ្ជាលក់ដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង។

បញ្ជាទិញដែលមានថ្លៃខ្ពស់ជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

**២. ពេលវេលា**

ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | : | |
| | ៦.៥២០ | ៥០០① |
| | ៦.៥០០ | ១០០② ២០០③ |
| : | ៦.៤៨០ | : |
| : | ៦.៤៦០ | : |
| ៣០០③ ២០០② | ៦.៤២០ | |
| (ថ្លៃលក់ទាបបំផុត) ៤៥០① | ៦.៤០០ | |
| | : | |

ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើ បញ្ជាទិញ(១) និងបញ្ជាលក់(១) ត្រូវបានអនុវត្តមុន ស្របទៅតាមអាទិភាពថ្លៃ។ ហើយក្នុងចំណោមបញ្ជាដែលមានថ្លៃស្មើគ្នា បញ្ជា(២) ដែលទទួលបានមុន ត្រូវបានអនុវត្តមុនបញ្ជា(៣)។

### ២.២.១០ វិធីសាស្ត្រ និងយន្តការនៃការអនុវត្តការជួញដូរ

រាល់ការជួញដូរ ត្រូវអនុវត្តតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ឬ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ។

ឧទាហរណ៍ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | 10,500 | |
| ❶ 300 | 10,400 | ❶ 700 100 |
| ❷ 200 | 10,300 | |
| ❸ 100 | 10,200 | |
| | 10,100 | |
| 600 | សរុប | 700 |

ដល់ម៉ោងជួញដូរ (ម៉ោង ៩:០០ ឬ ១១:៣០)៖ ៦០០x១០,៤០០៛=៦,២៤០,០០០៛

ឧទាហរណ៍ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | 10,500 | |
| ❶ 300 | 10,400 | ❶ 700 100 |
| ❷ 200 | 10,300 | |
| ❸ 100 | 10,200 | |
| | 10,100 | |
| 600 | សរុប | 700 |

ដល់ម៉ោងជួញដូរ (ម៉ោង ៩:០០ ឬ ១១:៣០)៖

១. ២០០x១០,៣០០៛=២,០៦០,០០០៛ (ភ្លាមៗ)

២. ៣០០x១០,៤០០៛=៣,១២០,០០០៛ (ភ្លាមៗ)

៣. ១០០x១០,៤០០៛=១,០៤០,០០០៛ (ភ្លាមៗ)

៦,២២០,០០០៛

## ២.២.១១ ការផ្សាយជាសាធារណៈនូវព័ត៌មានទីផ្សារ

ផ.ក.ម. ផ្តល់ជូននូវទិន្នន័យទីផ្សារដ៏មានប្រសិទ្ធិភាព នៅក្នុងបរិស្ថានមួយដែលផ្អែកលើភាពយុត្តិធម៌ តម្លាភាព ភាពមានសណ្តាប់ធ្នាប់ និងវិធានជាគោល។ វិនិយោគិននិងអ្នកចូលរួមទាំងអស់អាចទទួលបាននូវអត្ថប្រយោជន៍ពីព័ត៌មានទីផ្សារដែលងាយស្រួលយល់និងត្រឹមត្រូវ ដែលបានផ្តល់ឲ្យគ្រប់ភាគីទាំងអស់ក្នុងពេលដំណាលគ្នា។ ក្នុងន័យនេះ ផ.ក.ម. ផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យទីផ្សារដូចខាងក្រោម៖

- ថ្លៃបើក និង ថ្លៃបិទ

- បរិមាណ និង តម្លៃសរុបនៃការជួញដូរ
- ថ្លៃ និង បរិមាណរំពឹងទុក
- ថ្លៃមូលដ្ឋាន
- សន្ទស្សន៍
- ព័ត៌មានដែលមានប្រយោជន៍ដទៃទៀត។

### ២.២.១២ ការត្រួតពិនិត្យ និងឃ្លាំមើលទីផ្សារ

ដើម្បីធានាបាននូវសុច្ចរិតភាពទីផ្សារនិងការការពារវិនិយោគិន ផ.ម.ក.ការឃ្លាំមើលទីផ្សារ ដើម្បីកំណត់អត្តសញ្ញាណមូលបត្រដែលជាប់សង្ស័យថាមានការជួញដូរមិនប្រក្រតី តាមរយៈការតាមដានឥរិយាបថនៃការជួញដូរ បម្រែបម្រួលថ្លៃ ទំហំជួញដូរ កម្រិតនៃទំនាក់ទំនងរវាងថ្លៃនិងការជួញដូរ និងព័ត៌មានលម្អិតនៃពាក្យចចាមអារ៉ាម។បុគ្គលណាដែលត្រូវបានរកឃើញថាបានប្រព្រឹត្តដោយចេតនានូវការជួញដូរផ្ទៃក្នុងឬឧបាយកលទីផ្សារ នឹងត្រូវទទួលទោសចំពោះមុខច្បាប់ និងបទបញ្ញត្តិនានាដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ២.២.១៣ នីតិវិធីនៃការជួញដូរមូលបត្រ

#### ២.២.១៣.១ ការបើកគណនី និងការដាក់បញ្ជា

ដើម្បីអាចធ្វើការជួញដូរនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) វិនិយោគិនទាំងឡាយត្រូវបើកគណនីជួញដូរមួយជាមុនសិន នៅក្រុមហ៊ុនមូលបត្រណាមួយដែលជាសមាជិករបស់ផ.ម.ក.។ មួយថ្ងៃក្រោយមក ទើបវិនិយោគិនអាចបង្គាប់ឲ្យក្រុមហ៊ុនមូលបត្រនោះ (ដែលដើរតួនាទីជាអន្តរការី) ដាក់បញ្ជាមកកាន់ ផ.ម.ក.។ វិនិយោគិនអាចដាក់បញ្ជាបានលុះត្រាមានសាច់ប្រាក់យ៉ាងហោចណាស់មួយរយភាគរយ (សម្រាប់បញ្ជាទិញ) ឬបរិមាណមូលបត្រយ៉ាងហោចណាស់មួយរយភាគរយ (សម្រាប់បញ្ជាលក់)។ នៅពេលបញ្ជាត្រូវបានបញ្ជូន សាច់ប្រាក់និងមូលបត្រទាំងនេះនឹងត្រូវបានបង្កកទុកដោយក្រុមហ៊ុនមូលបត្រ ក្នុងគោលបំណងដើម្បីទុកទូទាត់ ឬបង្កកទុករហូតដល់បញ្ជានោះអស់សុពលភាព។

#### ២.២.១៣.២ ការអនុវត្តន៍ការជួញដូរ និងការជូនដំណឹង

ប្រព័ន្ធជួញដូររបស់ ផ.ម.ក.ធ្វើការផ្គូផ្គង និងអនុវត្តបញ្ជានានាដែលត្រូវបានបញ្ជូនមកដោយយោងទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន ហើយបន្ទាប់មកជូនដំណឹងអំពីលទ្ធផលនៃការជួញដូរនោះទៅកាន់ក្រុមហ៊ុនមូលបត្រជាសមាជិកដែលពាក់ព័ន្ធ និងក្រោយមកក្រុមហ៊ុនមូលបត្រនោះជូនដំណឹងបន្តទៅអតិថិជនរបស់ខ្លួន (ដែលជាវិនិយោគិន)។




(១) វិនិយោគិនបើកគណនីជួញដូរ (គណនីសាច់ប្រាក់និងគណនីមូលបត្រ) នៅក្រុមហ៊ុនមូលបត្រមួយ នៅមួយថ្ងៃមុនថ្ងៃជួញដូរ។

(២) វិនិយោគិនផ្តល់សេចក្តីបង្គាប់ឲ្យដាក់បញ្ជា (ទិញឬលក់) ទៅកាន់ក្រុមហ៊ុនមូលបត្រ ជាលាយលក្ខណ៍អក្សរ ពាក្យសំដី (ថតទុក)

ឬមធ្យោបាយអេឡិចត្រូនិចនានា។

(៣) ក្រុមហ៊ុនមូលបត្រដាក់បញ្ជាទៅតាមការបង្គាប់មកកាន់ **ផ.ម.ក.** ប៉ុន្តែមុននឹងដាក់បញ្ជា ក្រុមហ៊ុនមូលបត្របានបង្កកទុក

រួចហើយនូវសាច់ប្រាក់ឬបរិមាណមូលបត្រយ៉ាងហោចមួយរយភាគរយនៃបញ្ជានីមួយៗ។

(៤) បញ្ជាទាំងឡាយត្រូវបានផ្គូផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។

(៥) **ផ.ម.ក.** ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0។

(៦) ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួន (នៅ T+0)។

(៧) ក្នុងករណីមានកំហុសឆ្គងប្រតិបត្តិការបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ **ផ.ម.ក.**

ដើម្បីកែតម្រូវមុនពេលថ្ងៃត្រង់នៃថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំនុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

(៨) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ ប៉ុន្តែជាក់ស្តែង គឺក្រុមហ៊ុនមូលបត្រប្រើប្រាស់សាច់ប្រាក់ឬ

មូលបត្ររបស់អតិថិជន ដែលបានបង្កកទុកដើម្បីទូទាត់ ដោយសុំឬមិនបាច់សុំការអនុញ្ញាតពីអតិថិជនឡើយ។

(៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមវិនិយោគិននៅ **ផ.ម.ក.**។

# ជំពូកទី៣
# ស្ថានភាពទូទៅរបស់
# ធនាគារកោណាឌីយ៉ា

# ជំពូកទី៣

# ស្ថានភាពទូទៅរបស់ធនាគារកាណាឌីយ៉ា

## ៣.១ ប្រវត្តិនៃធនាគារកាណាឌីយ៉ា[17]

ធនាគារកាណាឌីយ៉ា ក អ.ត្រូវបានបង្កើតឡើងនូវថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩១ ដែលមានឈ្មោះថា "Canadia Gold & Trust Corporation Ltd." ដោយមានការចូលរួមរវាងភាគីកម្ពុជានិងកាណាដា និង ធនាគារជាតិនៃកម្ពុជា។ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារ គឺមានការចូលរួមពីបុគ្គលិកជំនាញៗពីធនាគារជាតិនៃទកម្ពុជា និងម្ចាស់ភាគ ហ៊ុនទាំងសងខាង កម្ពុជា កាណាដា ។

គោលដៅសំខាន់ៗរបស់ធនាគារកាណាឌីយ៉ាគឺសំដៅទៅលើប្រតិបត្តិការមាស ដូចជាការផលិតមាស និងផ្តល់ កំចីដល់ពាណិជ្ជករទាំងឡាយ ។ នៅថ្ងៃ១៩ មេសា ១៩៩៣ ធនាគារត្រូវបានប្តូរទៅជាធនាគារកាណាឌីយ៉ា ដោយទទួលបានសិទ្ធជាធនាគារពាណិជ្ជកម្ម ពីធនាគារជាតិកម្ពុជា និងត្រូវបានចុះក្នុងបញ្ជីក្រសួងពាណិជ្ជកម្ម ។ រហូតមកដល់ថ្ងៃទី១៦ ធ្នូ ២០០៣ ធនាគារត្រូវបានទទួលស្គាល់សារជាថ្មីថា ធនាគារកាណាឌីយ៉ា ក.អ។

ចាប់តាំងពីឆ្នាំ១៩៩៨ ធនាគារបានក្លាយជាធនាគារក្នុងស្រុកដ៏ធំជាងគេ ជាមួយបណ្តាញដ៏ធំជាងគេទូទាំងពិភពលោក ហើយមានការទទួល ស្គាល់យ៉ាងមុតមាំពីសំណាក់ប្រជាជនក្នុងស្រុកក៏ដូចជាក្រៅប្រទេស។ ធនាគារ ផ្តោតទៅលើទីផ្សារភាគហ៊ុនក្នុងការផ្តល់ប្រាក់កំចី ក៏ដូចជាការទទួលប្រាក់បញ្ញើ ។ ធនាគារផ្តល់ជូននូវសេវាកម្ម ហិរញ្ញវត្ថុនៅទីស្នាក់ការកណ្តាល និងគ្រប់ ៥៧ សាខាក្នុងទីក្រុងភ្នំពេញ និងបណ្តាលខេត្តផ្សេងៗ ទៀតក្នុងប្រទេសកម្ពុជា ។

### ៣.១.១ ស្លាកសញ្ញា

ឈ្មោះរបស់ធនាគារបានប្រែក្លាយមកពីប្រជាជន ដែលជាអភិជនមកពីប្រទេសកាណាដា ។

[17] ស្ថានភាពទូទៅធនាគារកាណាឌីយ៉ា https://www.canadiabank.com.kh/kh/about_canadia_kh.aspx ចូលដកស្រង់ថ្ងៃទី ០៧ កក្កដា ឆ្នាំ ២០១៧

### ៣.១.២ ទស្សនៈវិស័យ

កាណាឌីយ៉ានឹងវិវត្តន៍ខ្លួនអោយក្លាយជាធនាគារដែលឈានមុខគេនៅកម្ពុជា។

### ៣.១.៣ បេសកកម្ម

ជាមួយនឹងបទដ្ឋានដ៏ល្អបំផុតក្នុងការផ្តល់សេវាជូនអតិថិជន តាមរយៈបទពិសោធន៍ជាមួយអតិថិជន និងគុណភាពការងារសម្រាប់រយៈពេលវែង ការបំពេញសេវាធនាគារ ដែលមានទំនាក់ទំនងជាមួយអតិថិជនរបស់យើង ។

### ៣.១.៤ ថ្នាក់ដឹកនាំរបស់ធនាគារកាណាឌីយ៉ា[18]

- Mr. Pung Kheav Se, Chairman
- Mrs. Lim Sophany, Non-Executive (resigned on 9 December 2011)
- Mr. PUNG Way, Non-Executive (resigned on 7 November 2011)
- Mr. Lor Chee Leng, Chief Executive Officer (appointed on 7 November 2011)
- Mr. Charles Vann, Executive Vice President
- Mrs. Pung Carolyne, Assistant to Chairman
- Mr. Chen Lee Yiaw Hui, Senior Vice President
- Mr. Jimmy Leow Min Fong, Independent, Non-Executive
- Mr. Gerald Yeo, Independent, Non-Executive
- Mr. Peter Michael Burger, Independent, Non-Executive

### ៣.១.៥ ធនាគារដៃគូ[19]

+ រូបិយវត្ថុ : USD

| ឈ្មោះធនាគារដៃគូ | ប្រទេស |
|---|---|
| **WELLS FARGO BANK, N.A NEWYORK INTERNATIONAL BRANCH**<br>375 Park Avenue, Level A, NY 4080, New York, Ny 10152<br>SWIFT: PNBPUS3NNYC | USA |
| **STANDARD CHARTERED BANK (New York Branch)**<br>One Madison Avenue, New York, NY 10010, USA<br>SWIFT: SCBLUS33<br>ABA: 026002561 | USA |

[18] https://www.canadiabank.com.kh/kh/boarddirectorkh.aspx ចូលដកស្រង់ថ្ងៃទី ០៧ កក្កដា ឆ្នាំ ២០១៧

[19] https://www.canadiabank.com.kh/kh/corresbankkh.aspx ចូលដកស្រង់ថ្ងៃទី ០៧ កក្កដា ឆ្នាំ ២០១៧

| | |
|---|---|
| **SUMITOMO SITSUI BANKING CORPRATION (New York Branch)**<br>277 Park Avenue, New York, NY10172 USA<br>SWIFT: SMBCUS33 | USA |
| **COMMERZBANK AG**<br>Kai Serplatz, 6026 Frankfurt Am Main, GERMANY<br>SWIFT: COBADEFF | GERMANY |
| **CITIC INTERNATIONAL BANK LIMITED**<br>979 King's Road Quarry Bay, HONG KONG<br>SWIFT: KWHKHKHH | HONG KONG |
| **THE NANYANG COMMERCIAL BANK LTD**<br>151 Dex Voeux Road, Central, HONG KONG<br>SWIFT: NYCBHKHH | HONG KONG |
| **STANDARD CHARTERED BANK (Hong Kong)**<br>5/F, 4-4A Des Voeux Road, Central,<br>HONG KONG<br>SWIFT: SCBLHKHH | HONG KONG |
| **BANK OF COMMUNICATION**<br>18/F, No.188, Yin Cheng Zhong Lu, Shanghai, CHINA 200120<br>SWIFT: COMMCNSH | CHINA |
| **GUANGXI BEIBU GULF BANK CO.,LTD**<br>10 QINGXIU ROAD, NANNING CITY, GUANGXI ZHUANG AUTONOMOUS<br>SWIFT: BGBKCNBJ | CHINA |
| **CHANG HWA COMMERCIAL BANK LTD**<br>57, Chung Shan North Road, Sec 2, TaiPei, TAIWAN<br>SWIFT: CCBCTWTP | TAIWAN |
| **UNITED OVERSEAS BANK LIMITED**<br>80 Raffles Place, UOB Plaza, SINGAPORE 048624<br>SWIFT: UOVBSGSG | SINGAPORE |
| **STANDARD CHARTERED BANK (Singapore)** | SINGAPORE |

| | |
|---|---|
| 6 Battery Road, Singapore 49909<br>SWIFT: SCBLSGSG | |
| **BANK OF TOKYO-MITSUBISHI UFJ. LTD**<br>The Head Office, Tokyo, JAPAN<br>SWIFT: BOTKJPJT | JAPAN |
| **MIZUHO BANK, LTD**<br>1-3-3 MARUNOUCHI CHIYODA-KU, TOKYO, JAPN<br>SWIFT: MHCBJPJT | JAPAN |
| **KRUNG THAI BANK PUBLIC COMPANY LTD**<br>35, Sukhumvit Road, Bangkok 10110, THAILAND<br>SWIFT: KRTHTHBK | THAILAND |
| **THANACHART BANK PUBLIC COMPANY LIMITED**<br>444 MBK Tower, 20F Phayathai Road, Wangmai, Phathumwan, Bangkok 10330, THAILAND<br>SWIFT: THBKTHBK | THAILAND |
| **KASIKORNBANK PUBLIC COMPANY LIMITED**<br>16TH FLOOR, 400/22 PHAHON YOTHIN AVENUE, BANKGKOK 10400 THAILAND<br>SWIFT: KASITHBK | THAILAND |
| **VIETCOM BANK**<br>198 Tran Quan Khai, Hoan Kien, Hanoi, VIETNAM<br>SWIFT: BFTVVNVX | VIETNAM |

+ រូបិយវត្ថុ : EUR

| ឈ្មោះធនាគារដៃគូ | ប្រទេស |
|---|---|
| **STANDARD CHARTERED BANK GMBH**<br>60486 Frankfurt, Am Main, GERMANY<br>SWIFT: SCBLDEFX | GERMANY |
| **COMMERZBANK AG** | |

| | |
|---|---|
| Kai serplatz, 60261 Frankfurt Am Main, GERMANY<br>SWIFT: COBADEFF | GERMANY |

+ រូបិយវត្ថុ : JPY

| ឈ្មោះធនាគារដៃគូ | ប្រទេស |
|---|---|
| **BANK OF TOKYO-MITSUBISHI UFJ. LTD**<br>The Head Office, Tokyo, JAPAN<br>SWIFT: BOTKJPJT | JAPAN |
| **STANDARD CHARTERED BANK (Tokyo Branch)**<br>21st floor, Sanno Park Tower, 2-11-1 Nagatacho, Chiyoda-ku, JAPAN<br>SWIFT: SCBLJPJT | JAPAN |
| **MIZUHO BANK, LTD**<br>1-3-3 MARUNOUCHI CHIYODA-KU, TOKYO, JAPN<br>SWIFT: MHCBJPJT | JAPAN |

+ រូបិយវត្ថុ : HKD

| ឈ្មោះធនាគារដៃគូ | ប្រទេស |
|---|---|
| **THE NANYANG COMMERCIAL BANK LTD**<br>151 Dex Voeux Road, Central, HONG KONG<br>SWIFT: NYCBHKHH | HONG KONG |

+ រូបិយវត្ថុ : CNY

| ឈ្មោះធនាគារដៃគូ | ប្រទេស |
|---|---|

| | |
|---|---|
| **BANK OF COMMUNICATION**<br>18/F, No.188, Yin Cheng Zhong Lu, Shanghai, CHINA 200120<br>SWIFT: COMMCNSH | CHINA |
| **GUANGXI BEIBU GULF BANK CO.,LTD**<br>10 QINGXIU ROAD, NANNING CITY, GUANGXI ZHUANG AUTONOMOUS<br>SWIFT: BGBKCNBJ | CHINA |

+ រូបិយវត្ថុ : THB

| ឈ្មោះធនាគារដៃគូ | ប្រទេស |
|---|---|
| **KRUNG THAI BANK PUBLIC COMPANY LTD**<br>35, Sukhumvit Road, Bangkok 10110, THAILAND<br>SWIFT: KRTHTHBK | THAILAND |
| **THANACHART BANK PUBLIC COMPANY LIMITED**<br>444 MBK Tower, 20F Phayathai Road, Wangmai, Phathumwan, Bangkok 10330, THAILAND<br>SWIFT: THBKTHBK | THAILAND |
| **KASIKORNBANK PUBLIC COMPANY LIMITED**<br>16TH FLOOR, 400/22 PHAHON YOTHIN AVENUE, BANKGKOK 10400 THAILAND<br>SWIFT: KASITHBK | THAILAND |

### ៣.២ ផលិតផល និងសេវាកម្ម[20]

ក្រោយពីវិវត្តន៍ខ្លួនក្លាយជាធនាគារពាណិជ្ជ ធនាគារកាណាឌីយ៉ាបានបើកបម្រើសេវាកម្ម ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជន ដូចជា៖

- សេវាកម្មបញ្ញើ សន្សំ
- សេវាកម្មឥណទាន
- សេវាកម្មផ្ទេរប្រាក់ក្នុង និងក្រៅប្រទេស
- សេវាកម្មចាត់ចែងសាច់ប្រាក់ និងសេវាកម្មផ្សេងៗទៀត។

[20] https://www.canadiabank.com.kh/kh/index_kh.aspx ចូលដកស្រង់ថ្ងៃទី ១០ កក្កដា ២០១៧

### ៣.២.១ សេវាកម្មបញ្ញើ សន្សំ[21]

គណនីសំច័យរបស់ធនាគារកាណាឌីយ៉ា មានភាពសាមញ្ញ និងងាយស្រួលក្នុងការបើកនិងគ្រប់គ្រង ។ លក្ខណៈ ពិសេសរបស់គណនីនេះគឺ តម្កល់ទឹកប្រាក់ក្នុងកម្រិតទាប ដែលងាយស្រួលឲ្យលោកអ្នក មានលទ្ធភាពធ្វើការសន្សំទឹកប្រាក់ពីបន្តិចបន្តួចរហូតដល់ទឹកប្រាក់នោះកើនឡើងជាលំដាប់ ។ បន្ថែមពីនេះទៅទៀត លោកអ្នកកាន់តែមាន ភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការធនាគារតាមរយៈម៉ាស៊ីន អេ ធី អឹម ជាង ១១៩ កន្លែងហើយ និងមានបណ្តាញសាខាជាង ៥៧ ទូទាំងប្រទេសកម្ពុជា ។

| រូបិយប័ណ្ណ | ដុល្លាអាមេរិក | ប្រាក់រៀល | បាតថៃ |
|---|---|---|---|
| អត្រាការប្រាក់ប្រចាំឆ្នាំ | ០.៧៥% | ២% | ០.២៥% |

#### ក.លក្ខណៈពិសេសរបស់គណនី

- អាចបើកបានបីរូបិយប័ណ្ណមានដូចជា ប្រាក់រៀល ប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ ។
- រីករាយជាមួយនឹងអត្រាការប្រាក់ខ្ពស់ ។
- ទូទាត់ការប្រាក់ប្រចាំថ្ងៃ និងបូកសរុបការប្រាក់ចូលក្នុងគណនីរបស់លោកអ្នកប្រចាំខែ ។
- ពុំមានកម្រៃសេវាប្រចាំខែលើគណនីសន្សំ ។
- ផ្តល់ជូនកូនសៀវភៅសំច័យដោយឥតគិតថ្លៃ ។
- ងាយស្រួលក្នុងការធ្វើប្រតិបត្តិការគណនី តាមរយៈសេវាធនាគារ តាមប្រព័ន្ធអ៊ីនធឺណេត (Internet Banking) ប្រព័ន្ធទូរស័ព្ទ (Mobile Banking) ម៉ាស៊ីន អេ ធី អឹម ធនាគារកាណាឌីយ៉ា និងបណ្តាញម៉ាស៊ីន អេ ធី អឹម អ៊ី ស៊ី ខេស (Easycash) ដែលមានស្លាកសញ្ញា (៖) ។
- ងាយស្រួលក្នុងការទូទាត់វិក្កយបត្រទឹក ឬ ភ្លើងតាមរយៈ បញ្ជរបេឡា ឬម៉ាស៊ីន អេ ធី អឹម ។

#### ខ.លក្ខខណ្ឌក្នុងការបើកគណនីសន្សំ

- ប្រជាពលរដ្ឋខ្មែរ និងជនបរទេស ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ អាចបើកគណនីនេះបាន ។
- ក្រុមហ៊ុនអាជីវកម្មដែលបានចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់ក្នុងប្រទេសកម្ពុជា អាចបើកគណនីនេះបាន ។

[21] https://www.canadiabank.com.kh/kh/saving_account_kh.aspx ចូលដកស្រង់ថ្ងៃទី ១០ កក្កដា ២០១៧

## ៣.២.២ សេវាកម្មឥណទាន[22]

### ក.ឥណទានខ្នាតតូច និងមធ្យម

ឥណទានខ្នាតតូច និងមធ្យមរបស់ធនាគារកាណាឌីយ៉ា គឺជាដំណោះស្រាយសម្រាប់តម្រូវការដើមទុនរបស់លោកអ្នក ក្នុងការពង្រីកមុខជំនួញ ឬការបញ្ជារទិញបរិក្ខារកិច្ច ឬជាទុនបង្វិលក្នុងអាជីវកម្ម ឬសម្រាប់ជាធនធានក្នុងការអភិវឌ្ឍន៍គម្រោងអាជីវកម្មរយៈពេលវែង ។ ឥណទានខ្នាតតូច និងមធ្យមត្រូវបានផ្តល់ជម្រើសឥណទាន និងសេវាជាច្រើនប្រភេទ ។ ធនាគារកាណាឌីយ៉ាបានគាំទ្រយ៉ាងពេញទំហឹងដល់ សហគ្រាសខ្នាតតូច និងមធ្យមជាមួយទានប្រាក់រៀល និងដុល្លាដែលមានអត្រាការប្រាក់ទាបសមរម្យ និងមានលក្ខខណ្ឌងាយស្រួល ។

**+លក្ខណៈពិសេសនៃឥណទានខ្នាតតូច និងមធ្យម**

- មានភាពងាយស្រួលក្នុងការដាក់ពាក្យកម្ចី
- អត្រាការប្រាក់ទាបសមរម្យ
- ទំហំឥណទានចាប់ពី៥,០០០ដុល្លាអាមេរិករហូតដល់២០០,០០០ដុល្លាអាមេរិកឬសមមូល
- មានផ្តល់ឥណទានជាប្រាក់រៀល ឬដុល្លាអាមេរិក ឬប្រាក់បាតថៃ
- មានផ្តល់ឥណទានជាប្រាក់រៀល ឬដុល្លាអាមេរិក ដែលមានអត្រាការប្រាក់ទាបសមរម្យ
- ទទួលយកប័ណ្ណកម្មសិទ្ធគ្រប់ប្រភេទ (ប្លង់ទន់ ឬប្លង់រឹង)
- កម្ចីមានរយៈពេលវែង និងសោហ៊ុយឥណទានគិតតែម្តងក្នុងមួយកិច្ចសន្យា
- វិធីសងត្រលប់មកវិញមានច្រើនជម្រើសតាមតម្រូវការអតិថិជន
- មានផ្តល់ជូនសេវាទូទាត់កម្ចីបង់ផ្តាច់ទៅស្ថាប័នហិរញ្ញវត្ថុផ្សេងដោយមិនគិតកម្រៃសេវា
- អតិថិជនដែលបានប្រើប្រាស់ឥណទាននៅធនាគារកាណាឌីយ៉ាអាចបង់ប្រាក់ឥណទានប្រចាំខែបានតាមបណ្តាសាខាខេត្ត-ក្រុងទូទាំងប្រទេសដោយមិនគិតកម្រៃសេវាបង់ប្រាក់
- មានឱកាសប្រើប្រាស់ផលិតផល និងសេវាកម្មផ្សេងៗរបស់ធនាគារ និងមានសេវាហិរញ្ញប្បទានពាណិជ្ជកម្ម
- ងាយស្រួលក្នុងការទំនាក់ទំនង តាមបណ្តាសាខាទាំង ៥៧ ទីតាំងនៅគ្រប់ខេត្ត-ក្រុងទូទាំងប្រទេស

[22] https://www.canadiabank.com.kh/kh/sme_loan_kh.aspx ចូលដកស្រង់ថ្ងៃទី ១០ កក្កដា ២០១៧

### ខ.ឥណទានសាជីវកម្ម[23]

ផលិតផលឥណទានសាជីវកម្ម គឺជាឥណទានដែលផ្តល់ជូនសម្រាប់ រូបវន្តបុគ្គល និងនិតិបុគ្គល ប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម, ផលិតផលឥណទានសាជីវកម្មមានប្រភេទដូចជា៖

➢**ឥណទានវិបារូបន៍**

ឥណទានវិបារូបន៍ ត្រូវបានបង្កើតឡើងដោយមានរយៈពេលរហូតដល់ ១២ខែ ដើម្បីផ្តល់ហិរញ្ញប្បទានជាទុនបង្វិល រយៈពេលខ្លី និងចំណាយលើប្រតិបត្តិការ ដែលអ្នកខ្ចីមិនអាចបំពេញតាមតម្រូវការសាច់ប្រាក់ប្រចាំថ្ងៃរបស់ពួកគេបាន ។

➢**ឥណទានសម្រាប់ទុនបង្វិល**

ឥណទានសម្រាប់ទុនបង្វិល គឺជាឥណទានរយៈពេលខ្លីដែលផ្តល់ជូននៅចំនួនកំរិតឥណទានជាក់លាក់មួយដែលអាចប្រើប្រាស់បានមានរយៈពេលរហូតដល់ ១២ខែ ។ ឥណទាននេះសម្រាប់ប្រើប្រាស់ ជាទុនបង្វិលដែលលំហូរសាច់ប្រាក់ត្រូវបង់នៅចុងគ្រា នៃសាច់ប្រាក់ដែលបានបំលែងក្នុងវដ្ត ៣ខែ ។៦-

➢**ឥណទានមានកាលកំណត់ (រយៈពេលខ្លី)**

ឥណទានមានកាលកំណត់ គឺជាឥណទានដែលមានរយៈពេលខ្លីរហូតដល់ ២៤ខែ ហើយឥណទាននេះប្រើប្រាស់ក្នុងគោលបំណង ធ្វើជាទុនបង្វិលក្នុងអាជីវកម្ម ហើយប្រាក់ដើមតម្រូវអោយសងត្រលប់នៅចុងគ្រា ។

➢**ឥណទានមានកាលកំណត់ (រយៈពេលវែង)**

គឺជាឥណទានរយៈពេលវែងរហូតដល់ ១២០ខែ ដែលមានរយៈពេលអនុគ្រោះរហូតដល់ ១២ខែ សម្រាប់ប្រើប្រាស់ក្នុងគោលបំណងវិនិយោគលើគ្រឿងចក្រ ឬ ពាណិជ្ជកម្មផ្សេងៗទៀតដែលពាក់ព័ន្ធ ។ តម្រូវឲ្យបង់រលោះប្រាក់ដើម និងការប្រាក់ប្រចាំខែ ។

➢**ឥណទានដាក់សាច់ប្រាក់**

គឺជាឥណទានដែលផ្តល់ជូននូវសាច់ប្រាក់ងាយស្រួល ដោយពុំមានប៉ះពាល់ដល់ចំណូលនៃប្រាក់សន្សំឡើយ ចំណែកទ្រព្យដាក់បញ្ចាំ គឺជាប្រាក់សន្សំមានកាលកំណត់ ប៉ុន្តែនៅតែអាចទទួលបានការប្រាក់ដដែល ។

[23] https://www.canadiabank.com.kh/kh/corperate_loan_kh.aspx ចូលដកស្រង់ថ្ងៃទី ១០ កក្កដា ២០១៧

# ជំពូកទី៤
# ដំណើរការនៃការផាត់ទាត់
# និងទូទាត់មូលបត្រ

# ជំពូកទី៤

# ដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រ

## ៤.១ និយមន័យនៃប្រព័ន្ធផាត់ទាត់ និងទូទាត់[24]

តាមនិយមន័យដែលកំណត់នៅក្នុង វិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ផ្សារមូលបត្រកម្ពុជា ប្រព័ន្ធផាត់ទាត់និងទូទាត់ (Clearing and Settlement Facility) សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគី ធ្វើប្រតិបត្តិការជួញដូរមូលបត្រ បំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកបានដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការអោយបានច្បាស់លាស់ និងធានាអោយមានការទូទាត់ថ្លៃទិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅអោយអ្នកទិញ។

ប្រព័ន្ធផាត់ទាត់ និងទូទាត់រួមមាន៖

+ប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (Securities Clearing and Settlement Facility) សំដៅដល់ប្រព័ន្ធផាត់ទាត់និងទូទាត់ ដើម្បីធ្វើការផ្លាស់ប្តូរកម្មសិទ្ធលើមូលបត្ររវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

+ប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់ (Cash Clearing and Settlement Facility) សំដៅដល់ប្រព័ន្ធផាត់ទាត់និងទូទាត់ ដើម្បីធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

## ៤.២ តួអង្គសំខាន់ៗ និងតួនាទីរបស់តួអង្គក្នុងដំណើរការផាត់ទាត់ និងទូទាត់

នៅក្នុងប្រតិបត្តិការនៃការផាត់ទាត់ និងទូទាត់មូលបត្រមានតួអង្គមួយចំនួនដែលចូលរួមពាក់ព័ន្ធដូចជាសាធារណៈជនទាំងរូបវន្តបុគ្គល និងនីតិបុគ្គល។ចំណែកតួអង្គដែលសំខាន់ និងដើរតួនាទីយ៉ាងសកម្មនៅក្នុងយន្តការនៃការផាត់ទាត់ និងទូទាត់មូលបត្ររួមមាន៖

- ❋ ប្រតិបត្តិករទីផ្សារមូលបត្រ
- ❋ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ
- ❋ ប្រតិបត្តិកររក្សាទុកមូលបត្រ
- ❋ ក្រុមហ៊ុនមូលបត្រ
- ❋ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- ❋ ធនាគារជាតិនៃកម្ពុជា។

[24] ដកស្រង់ពីរបាយការណ៍កម្មសិក្សា, យន្តការនៃការផាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ និស្សិត ហ៊ាង បុទម្យ, ហង់ ពិសី (២០១៤) ទំព័រ ២៨ ដល់ ៣៥

**៤.២.១ ប្រតិបត្តិករទីផ្សារមូលបត្រ**

ប្រតិបត្តិករទីផ្សារមូលបត្រ សំដៅទៅដល់បុគ្គលដែលធ្វើប្រតិបត្តិការទីផ្សារមូលបត្រដូចជាការផ្តល់នូវសេវាសម្រាប់សម្រួលដល់អ្នកចូលរួមក្នុងទីផ្សារ (ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ)ដើម្បីធ្វើសកម្មភាពជួញដូរមូលបត្រ ឬដើម្បីអោយអ្នកចូលរួមក្នុងទីផ្សារអាចទទួលបាននូវការបន្សុំលើប្រតិបត្តិការបញ្ជាទិញ ឬលក់មូលបត្ររបស់ខ្លួនតាមរយៈទីកន្លែង ប្រព័ន្ធ ឬមធ្យោបាយសម្រាប់ជួញដូរមូលបត្រជារូបវន្ត ឬអេឡិចត្រូនិច។

**៤.២.២ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រសំដៅដល់បុគ្គលដែលធ្វើប្រតិបត្តិការប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងមានកាតព្វកិច្ចមួយចំនួនដូចជា៖

១.ធ្វើប្រតិបត្តិការរបស់ខ្លួនអោយដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

២.ត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នរាល់ហានីភ័យដែលកើតឡើងពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ។

៣.បំពេញអោយអស់ពីសមត្ថភាពនូវកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់ អនុក្រឹត្យ ប្រកាសស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ និងបទបញ្ញត្តិនានាដោយមិនត្រូវប្រព្រឹត្តអ្វីដែលផ្ទុយពីផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍វិនិយោគិន។

៤.អនុវត្តអោយបានខ្ជាប់ខ្ជួននូវវិធានប្រតិបត្តិការប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងបទប្បញ្ញត្តិជាធរមានដែលកំណត់ដោយ គ.ម.ក ធនាគារជាតិនៃកម្ពុជា និងក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៥.ផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់នូវប្រព័ន្ធប្រតិបត្តិការរបស់ខ្លួន ព្រមទាំងប្រាកដថាសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារគោរពតាមវិធានប្រតិបត្តិការ ដើម្បីធានាអោយបាននូវសុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការ និងការពារផលប្រយោជន៍វិនិយោគិន។

៦.ត្រូវផ្តល់របាយការណ៍ដែលធ្វើសវនកម្ម ដោយក្រុមហ៊ុនសវនកម្មធ្វើអាជីវកម្មស្របច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងទទួលស្គាល់ដោយអគ្គនាយក គ.ម.ក។

៧.ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍ផ្សេងៗទៀត តាមការកំណត់របស់គណៈកម្មការមូលបត្រកម្ពុជា[25]។

[25] ប្រការ(១៥,១៧ និង ១៨) នៃប្រកាសស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

### ៤.២.៣ ប្រតិបត្តិកររក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រ សំដៅដល់បុគ្គលមួយយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀត ដែលជាអតិថិជនរបស់ខ្លួនថាផ្តល់សេវាកម្មដូចខាងក្រោមនេះទោះបីជាអតិថិជននោះធ្វើសកម្មភាព ក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ៖

ក.កាន់កាប់ ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀតក្នុងនាម អតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

ខ.ទទួលរក្សាទុកនូវមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ទោះបីមានរូបភាពជាវិញ្ញាបនប័ត្រកម្មសិទ្ធិ ឬជាទម្រង់អរូបីក្តី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ក្នុងនាម អតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

គ.ផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងៗទៀតដែលទាក់ទិននឹងការផ្តល់សេវាកម្ម ដូចមានចែងក្នុងកថាខណ្ឌ (ក) និង (ខ)។

ស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ក្រុមហ៊ុនដែលទទួល បានការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងជាប្រតិបត្តិកររក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា សព្វថ្ងៃគឺមានតែក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជាមួយប៉ុណ្ណោះ។

### ៤.២.៤ ក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនមូលបត្រសំដៅដល់ក្រុមហ៊ុន ឬក្រុមហ៊ុនសហកម្មសិទ្ធិ ដែលទទួលបានអាជ្ញាប័ណ្ណដើម្បីធ្វើអាជីវកម្មមូលបត្រ ដោយស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រ មហាជន។ក្រុមហ៊ុនមូលបត្រមានបួនប្រភេទគឺ ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនពាណិជ្ជករ មូលបត្រ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគ។

### ៤.២.៥ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ សំដៅទៅដល់ធនាគារពាណិជ្ជដែលទទួល បានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមច្បាប់ ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងទទួលបានជាមុននូវលិខិត "មិន ជំទាស់" ពីធនាគារជាតិនៃកម្ពុជា ព្រមទាំងបានការទទួលស្គាល់ពី គ.ម.ក ដូចមានចែងនៅក្នុង ប្រកាស ស្តីពី ការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រមានកាតព្វកិច្ចដូចខាងក្រោម៖

-ធ្វើការគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធ និងមូលបត្ររបស់អតិថិជនខ្លួន និងធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ នៅក្នុងទីផ្សារមូលបត្រប្រកបដោយភាពត្រឹមត្រូវ និងតាមកាលកំណត់។

-ធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាព។

-បំពេញប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រអោយដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ។

-ត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់នូវរាល់ហានីភ័យដែលកើតឡើងពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ។

-គោរពយ៉ាងខ្ជាប់ខ្ជួនទៅតាមលក្ខខណ្ឌតម្រូវស្តីពីធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងបច្ចេកវិទ្យា សម្រាប់ធានាប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ អោយដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

-គោរពតាមវិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងវិធានពាក់ព័ន្ធផ្សេងៗទៀត។

-ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់សេវារបស់ខ្លួន ដើម្បីធានាអោយបាននូវសុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការ។

-ផ្តល់ពត៌មានក្នុងករណីទូទាត់សាច់ប្រាក់មិនបានសម្រេច។

-អភិបាល និងបុគ្គលិកគ្រប់រូបរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈដែលខ្លួនទទួលបាន ក្នុងការបំពេញភារកិច្ច លើកលែងតែក្នុងករណីៈ

- ច្បាប់អនុញ្ញាត
- មានការបង្គាប់ពីតុលាការ
- ស្នើរឡើងដោយអគ្គនាយកនៃ គ.ម.ក ក្នុងគោលបំណងអនុវត្តការងារ។

-បំពេញកាតព្វកិច្ចផ្តល់របាយការណ៍និងពត៌មាននានា និងកាតព្វកិច្ចដទៃទៀតអោយបានត្រឹមត្រូវដូចមានចែងនៅក្នុងច្បាប់ អនុក្រឹត្យ ប្រកាស ស្តីពីការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។

ធានាគារជាតិនៃកម្ពុជា

នៅក្នុងដំណើរការនៃការផាត់ទាត់និងទូទាត់ ធនាគារជាតិនៃកម្ពុជា ឬធនាគារកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាដែលមានមុខងារ និងភារកិច្ចមួយចំនួនដូចខាងក្រោម៖

- បញ្ចូលធានាគារដែលបានដាក់ ពាក្យស្នើរសុំចូលជាសមាជិកសភាផាត់ទាត់ ជាសមាជិកក្នុងករណីដែលធានាគារនោះមានលក្ខណៈសម្បត្តិដូចជា ជាធានាគារដែលទទួលបានអាជ្ញាប័ណ្ណឲ្យប្រកបអាជីវកម្មពីធានាគារជាតិនៃកម្ពុជា មានគណនីចរន្ត និងគណនីប្រាក់បម្រុងកាតព្វកិច្ចនៅធានាគារជាតិនៃកម្ពុជា ព្រមទាំងបង់សោហ៊ុយសេវាតាមការកំណត់របស់ធានាគារជាតិនៃកម្ពុជា។ ក្រៅពីនេះធនាគារនោះក៏ត្រូវមានទីស្នាក់ការធ្វើប្រតិបត្តិការនៅភ្នំពេញដែរ។
- ផ្តល់ការយល់ព្រមជាលាយល័ក្ខណ៍អក្សរជាមុន ដល់ធនាគារដែលមិនមែនជាសមាជិកចំពោះសំណូមពរក្នុងការយកធនាគារជាសមាជិក មកធ្វើជាតំណាងក្នុងសភាផាត់ទាត់ជំនួសខ្លួនក្នុងការផាត់ទាត់ និងទូទាត់មូលប្បទានប័ត្រ។
- ផ្តល់ការយល់ព្រមជាលាយល័ក្ខណ៍អក្សរជាមុន ក្នុងករណីដែលធនាគារចង់ដកខ្លួនចេញពីសមាជិកសភាផាត់ទាត់ និងបានធ្វើការសម្របសម្រួលជាមួយនឹងធនាគារជាសមាជិកមួយទៀតអោយកាន់កាប់មូលប្បទានប័ត្រដើម្បីផាត់ទាត់ជំនួសខ្លួនរួច។
- បើកគណនីផាត់ទាត់ (គឺជាគណនីដែលបើកដោយសមាជិកសភាផាត់ទាត់នីមួយៗនៅធនាគារជាតិនៃកម្ពុជា សម្រាប់ទូទាត់កាតព្វកិច្ចប្រចាំថ្ងៃរបស់ខ្លួននៅសភាផាត់ទាត់) ចំពោះស្ថាប័នរដ្ឋ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
- ជាសមាជិកមួយនៃសភាផាត់ទាត់ដែលអាចទទួល និងប្រគល់មូលប្បទានប័ត្រដូចគ្នានឹងសមាជិកដទៃទៀតដែរ សម្រាប់សងអោយគេ ឬទារយកពីគេ។
- ត្រួតពិនិត្យប្រព័ន្ធទូទាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងកែលម្អប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ។
- ទទួលខុសត្រូវក្នុងការៀបចំរបាយការណ៍ប្រចាំថ្ងៃនូវ ទឹកប្រាក់សរុបនៃមូលប្បទានប័ត្រដែលសភាផាត់ទាត់បានបញ្ជូនទៅ និងទទួលយក ព្រមទាំងគណនាទឹកប្រាក់សុទ្ធដែលត្រូវចុះឥណពន្ធ ឬចុះឥណទានក្នុងគណនីចរន្តរបស់ធនាគារសមាជិកនីមួយៗ។

## ៤.៣ គោលការណ៍ក្នុងការបើកគណនីសម្រាប់ការផាត់ទាត់ និងទូទាត់

ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទូទាត់សាច់ប្រាក់ និងទូទាត់មូលមូលបត្រនៅក្នុងដំណើរការផាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ សមាជិក (សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបាន

អាជ្ញាបណ្ណពី គ.ម.ក ដោយមានសិទ្ធិប្រើប្រាស់ទាំងស្រុងនៅប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ របស់ ផ.ម.ក) នៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រដែលតំរូវអោយបើកគណនី ០២(ពីរ) ប្រភេទ គឺបើកគណនីទូទាត់សំរាប់ការទូទាត់សាច់ប្រាក់ និងគណនីមូលបត្រសំរាប់ការទូទាត់មូលបត្រ។

### ៤.៣.១.ការបើកគណនីសាច់ប្រាក់សំរាប់ការទូទាត់សាច់ប្រាក់[26]

សមាជិកនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវបើកគណនីសាច់ប្រាក់ក្នុងនាមខ្លួនផ្ទាល់ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

បន្ទាប់ពីបានបើកគណនីសាច់ប្រាក់ ឬមានការផ្លាស់ប្តូរគណនីសាច់ប្រាក់ សមាជិកត្រូវរាយការណ៍អំពីឈ្មោះនៃភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួននិងលេខគណនីជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រយ៉ាងហោច ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃចាប់ផ្តើមនៃការជួញដូរ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវបើកគណនីទូទាត់សាច់ប្រាក់នៅភ្នាក់ងារទូទាត់សាចប្រាក់ពាក់ព័ន្ធនឹងមូលបត្រដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់សមាជិកទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវផ្ទេរសាច់ប្រាក់ដែលទទួលបាននេះទៅសមាជិកដែលត្រូវទទួលបានការទូទាត់សាច់ប្រាក់។

### ៤.៣.២ ការបើកគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ[27]

សមាជិកត្រូវបើកគណនីមូលបត្រ ស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវបើកគណនីទូទាត់មូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រដើម្បីកាតព្វកិច្ចទូទាត់មូលបត្រ។

[26] ប្រការ ៧ នៃប្រកាសស្តីពី វិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
[27] ប្រការ ៨ នៃប្រកាសស្តីពី វិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ការទូទាត់មូលបត្រត្រូវធ្វើឡើង តាមរយៈការផ្ទេរក្នុងបញ្ជីពីគណនីមូលបត្ររបស់សមាជិកទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះទៅសមាជិកដែលត្រូវទទួលបានការទូទាត់មូលបត្រ។

## ៤.៤ កាលបរិច្ឆេទផាត់ទាត់និងទូទាត់[28]

កាលបរិច្ឆេទផាត់ទាត់និងទូទាត់មូលបត្រ សំដៅទៅដល់ថ្ងៃដែលបានកំណត់ដោយគណៈកម្មការមូលបត្រកម្ពុជា តម្រូវអោយភាគីដែលចូលរួមពាក់ព័ន្ធ នៅក្នុងដំណើរការនៃការផាត់ទាត់និងទូទាត់បំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់ និង ផាត់ទាត់មូលបត្ររបស់ខ្លួន។ ផ្សារមូលបត្រកម្ពុជាបានកំណត់ថ្ងៃសំខាន់ៗចំនួន០២ (ពីរ) ទៀត មុននឹងដល់ថ្ងៃទូទាត់ គឺថ្ងៃជួញដូរ និង ថ្ងៃផាត់ទាត់។




T+0 គឺជាកំឡុងពេលដែលមានដំណើរការជួញដូរមូលបត្រ ដូច្នេះវិនិយោគអាចធ្វើការដាក់បញ្ជាលទៅក្រុមហ៊ុនមូលបត្រដែលខ្លួនជ្រើសរើសរួចហើយ។ នៅក្នុងថ្ងៃដែលបញ្ជារទិញ ឬ លក់មូលបត្រ វិនិយោគិនអាចដាក់បញ្ជារជួញដូរ ចាប់ពីម៉ោង ៨ព្រឹក រហូតដល់ម៉ោង ១១និង៣០នាទីព្រឹក និងមានការចែកវគ្គជួញដូរជា ០៦ (ប្រាំមួយ) វគ្គ។ ម៉្យាងវិញទៀត វាក៏ជាថ្ងៃដែល ផ.ម.ក ត្រូវជូនដំណឹងអំពីលទ្ធផលនៃការជួញដូរ ទៅកាន់ក្រុមហ៊ុនមូលបត្រដែរ។ ចំណែកក្រុមហ៊ុនមូលបត្រត្រូវបញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួននៅក្នុងថ្ងៃនេះដែរ។

T+1 គឺជារយៈពេលដែលអាចធ្វើការកែតម្រូវនូវកំហុសដែលបានកើតឡើងក្នុងពេលបញ្ជាទិញ ឬ លក់មូលបត្រ។ ក្នុងករណីមានកំហុសឆ្គង ប្រតិបត្តិការបង្កឡើងដោយក្រុមហ៊ុនមូលបត្រៗ នោះត្រូវដាក់ពាក្យស្នើមកកាន់ ផ.ម.ក ដើម្បីកែតម្រូវមុនពេលថ្ងៃត្រង់នៃថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការដែល ផ.ម.ក ត្រូវជូនដំណឹងពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ ហើយក្រុមហ៊ុនមូលបត្រត្រូវបញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗ របស់ខ្លួននឹងត្រូវអនុវត្តម្តងទៀត។

[28] ដកស្រង់ពី http://csx.com.kh/operation/clearing/listPosts.do?MNCD=3030 ថ្ងៃទី ០៧ កក្កដា ២០១៧

T+2 គឺជាថ្ងៃទូទាត់ ដែលត្រូវធ្វើឡើងពីរថ្ងៃនៃថ្ងៃជួញដូរ បន្ទាប់ពីថ្ងៃដែលមូលបត្រត្រូវបានជួញដូរ (លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ គ.ម.ក)។ ថ្ងៃបិទទីផ្សារមិនត្រូវបានរាប់បញ្ចូលក្នុងថ្ងៃអាជីវកម្មទេ។ ពេលវេលានៃការទូទាត់គឺម៉ោង ៨និង៣០នាទីព្រឹក។ នៅថ្ងៃ T+2 សមាជិកត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ ទៅគណនីរបស់ ផ.ម.ក នៅមុនម៉ោង៨និង៣០នាទីព្រឹក នៅកាលបរិច្ឆេទទូទាត់ ហើយ ផ.ម.ក ត្រូវទូទាត់មូលបត្រ និង សាច់ប្រាក់បន្តទៅអោយសមាជិកដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង៨និង៣០នាទីព្រឹក នៅថ្ងៃដដែលនៃកាលបរិច្ឆេទទូទាត់។ បន្ទាប់ពីម៉ោង ១០និង៣០នាទីព្រឹក ក្រុមហ៊ុនមូលបត្រជាសមាជិកត្រូវទូទាត់សាច់ប្រាក់ទៅគណនីអតិថិជនរបស់ខ្លួនអោយចប់សព្វគ្រប់ ក្នុងកាលបរិច្ឆេទទូទាត់ (T+2) ដើម្បីអាចដាក់ប្រាក់ប្រើប្រាស់បាន។

## ៤.៥ អ្នកតំណាងទូទាត់

សមាជិកនីមួយៗ ត្រូវតែងតាំង និង ចុះឈ្មោះអ្នកតំណាងទូទាត់យ៉ាងហោចណាស់ ០១ (មួយ) រូប ដែលត្រូវទទួលការបណ្តុះបណ្តាល ផ.ម.ក និង មានសិទ្ធិធ្វើប្រតិបត្តិការទូទាត់អោយសមាជិកនោះជាមួយ ផ.ម.ក។

អ្នកតំណាងទូទាត់របស់សមាជិកនោះ អាចជាអ្នកតំណាងទីផ្សារ ដែលត្រូវបានតែងតាំងដោយសមាជិកស្រប តាមវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ ផ.ម.ក[29]។

## ៤.៦ យន្តការនៃការផាត់ទាត់និងទូទាត់មូលបត្រ

នៅពេលព័ត៌មានជួញដូរត្រូវបានបញ្ជាក់ដោយអតិថិជននិងបានផ្ទៀងផ្ទាត់ដោយសមាជិកទាំងអស់ដែលតាំងនាមអោយអតិថិជនរបស់ខ្លួនរួចហើយ ក្រុមហ៊ុនមូលបត្រ ត្រូវតំណាងអោយអតិថិជនក្នុងការទូទាត់សាច់ប្រាក់សម្រាប់មូលបត្រដែលបានទិញ ឬ បញ្ជូនមូលបត្រដែលបានលក់ទៅកាន់ ភាគីម្ខាងទៀតដែលជាសមាជិក និង ជាអន្តរការីរបស់អ្នកលក់មូលបត្រ ឬ អ្នកទទួលមូលបត្រដោយប្រើប្រាស់សាច់ប្រាក់ ឬ មូលបត្រ ដែលបានបង្កទុករួចហើយ នៅក្នុងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA)។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលបានទូទាត់ចុងក្រោយដោយសមាជិក ដោយធ្វើការបន្សុទ្ធ ឬ កាត់កងចំនួនមូលបត្រ និង សាច់ប្រាក់ដែលត្រូវទូទាត់ក្នុងកាលបរិច្ឆេទដូចគ្នារបស់សមាជិកនីមួយៗ។

[29] ប្រការ ១៣ នៃប្រកាសស្តីពី វិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវជូនដំណឹងអំពីព័ត៌មានលម្អិត ដូចខាងក្រោមទៅដល់សមាជិកនៅកាលបរិច្ឆេទជាត់ទាត់និងកាលបរិច្ឆេទទូទាត់៖

1. កាលបរិច្ឆេទជាត់ទាត់ និងកាលបរិច្ឆេទទូទាត់។
2. បរិមាណនៃមូលបត្រនីមួយៗដែលត្រូវធ្វើការទូទាត់ដោយសមាជិកផ្ទាល់ ឬ ក្នុងនាមអតិថិជន។
3. ទឹកប្រាក់ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬ ក្នុងនាមអតិថិជន។

### ៤.៦.១ រូបិយប័ណ្ណទូទាត់

ដើម្បីផ្តល់ជម្រើសដល់វិនិយោគិននៅក្នុងការទូទាត់មូលបត្រ ក្រុមហ៊ុនមូលបត្របានបើកគណនី ទូទាត់សាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រជាប្រាក់រៀលផង និងជាប្រាក់ដុល្លារអាមេរិកផង។ ដូចនេះ វិនិយោគិននឹងមានភាពងាយស្រួលនៅក្នុងការទូទាត់សាច់ប្រាក់ទៅតាមបំណងប្រាថ្នារបស់ខ្លួន ប៉ុន្តែការទូទាត់ជាប្រាក់រៀល ឬ ដុល្លារអាមេរិក អនុវត្តទៅបានដរាបណាវិនិយោគិនសាធារណៈ (Public Investors) គោរពតាមនីតិវិធីដូចខាងក្រោម៖

- **ការទូទាត់ជាប្រាក់រៀល**

រាល់ប្រតិបត្តិការទូទាត់សាច់ប្រាក់ ឬ បង់ប្រាក់កម្រៃផ្សេងៗ ដែលធ្វើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងជាប្រាក់រៀល។ ម៉្យាងវិញទៀត ប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យមូលបត្រ បានបង្កើតកម្មវិធីកុំព្យូទ័រជាប្រាក់រៀលតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ មានតែការទូទាត់ជាប្រាក់រៀលតែប៉ុណ្ណោះ ទើបអាចទូទាត់តាមរយៈប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានស្របតាមគោលការណ៍ណែនាំស្តីពីនីតិវិធីនៃការទូទាត់សាច់ប្រាក់ក្នុងទីផ្សារមូលបត្រ។

- **ការទូទាត់ជាប្រាក់ដុល្លារអាមេរិក**

ប្រសិនបើភាគីអ្នកទិញ និង អ្នកលក់មូលបត្រមានការឯកភាពគ្នា ក្នុងការទូទាត់សាច់ប្រាក់ជាប្រាក់ដុល្លារអាមេរិកនោះ ការទូទាត់អាចធ្វើឡើងជាប្រាក់ដុល្លារអាមេរិកបាន លុះត្រាតែភាគីអ្នកទិញរកបាននូវកិច្ចព្រមព្រៀងទូទាត់ ជាដុល្លារអាមេរិកពីក្រុមហ៊ុនមូលបត្រ ដើម្បីអោយក្រុមហ៊ុនមូលបត្រធ្វើការទូទាត់ជាប្រាក់រៀល តាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាសិន។ ប៉ុន្តែបើសិន អ្នកចង់ទូទាត់ជាប្រាក់ដុល្លារអាមេរិក មិនអាចរកកិច្ចព្រមព្រៀងបានទេ ការទូទាត់ជាប្រាក់ដុល្លារអាមេរិកក៏មិនអាចធ្វើឡើងបានដែរ។ ការទូទាត់ជាប្រាក់ដុល្លារអាមេរិកនេះ ត្រូវបានអនុញ្ញាតអោយធ្វើក្នុងរយៈពេល ០៣ឆ្នាំ ដំបូងចាប់ពីផ្សារមូលបត្រកម្ពុជាបានបង្កើតតែប៉ុណ្ណោះ។

### ៤.៦.២ ដំណើរការនៃការផាត់ទាត់និងទូទាត់

ការទូទាត់ គឺជាការបញ្ចប់ប្រតិបត្តិការដែលអ្នកលក់ផ្ទេរមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុ ទៅអោយអ្នកទិញ ចំណែកអ្នកទិញបានផ្ទេរសាច់ប្រាក់ទៅអោយអ្នកលក់វិញ។ ខាងក្រោមនេះ ជាការរៀបរាប់ពី នីតិវិធីនៃប្រតិបត្តិការផាត់ទាត់និងទូទាត់ តាំងពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលចុងក្រោយ៖




(១) . ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវបញ្ជូនព័ត៌មានពីការជួញដូរ ដែលបានបន្សុីរួចរាល់ (Confirmed Trade) ទៅ CSO។

(២). CSO បញ្ជូនព័ត៌មាននៃកាលបរិច្ឆេទផាត់ទាត់និងទូទាត់ បរិមាណសាច់ប្រាក់ និង បរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវធ្វើការទូទាត់ដោយសមាជិកផ្ទាល់ ឬ ក្នុងនាមអតិថិជន ទៅ SF(s)។

(៣). SF(s) ត្រូវដាក់ការបញ្ជារទូទាត់សាច់ប្រាក់ទៅ CSA ដែលពាក់ព័ន្ធ។

(៤). SF(s) ត្រូវដាក់ការបញ្ជារទូទាត់មូលបត្រទៅ CSD។

ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវបញ្ជូនព័ត៌មានជួញដូរដែលបានបន្សុីរួចទៅកាន់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។ បន្ទាប់មក ប្រតិបត្តិប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវធ្វើការបន្សុទ្ធទាំងសាច់ប្រាក់ និង មូលបត្រទៅតាមព័ត៌មានដែលទទួលបាន។

ក្រោយមកទៀត ប្រតិបត្តករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបញ្ជូនព័ត៌មាននៃកាលបរិច្ឆេទផាត់ទាត់និងទូទាត់ ចំនួនសាច់ប្រាក់និងបរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវធ្វើការទូទាត់ដោយសមាជិកផ្ទាល់ ឬ ក្នុងនាមអតិថិជន ទៅកាន់ក្រុមហ៊ុនមូលបត្រ SF(s) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) និងប្រតិបត្តិកររក្សាទុកមូលបត្រ (CSD) ។ បន្ទាប់មកទៀត ក្រុម

ហ៊ុនមូលបត្រត្រូវដាក់បញ្ជារទៅកាន់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដើម្បីធ្វើការទូទាត់សាច់ប្រាក់ ទៅអោយសមាជិកដែលត្រូវទទួលបានសាច់ប្រាក់ ឬ សមាជិកដែលបានលក់មូលបត្រ។ ជាចុងបញ្ចប់ ក្រុមហ៊ុនមូលបត្រត្រូវដាក់បញ្ចូលទៅកាន់ប្រតិបត្តិកររក្សាទុកមូលបត្រដើម្បីធ្វើការផាត់ទាត់មូលបត្រ ទៅកាន់សមាជិកដែលត្រូវទទួលការទូទាត់មូលបត្រ ក្នុងនាមខ្លួនផ្ទាល់ ឬ តាំងនាមអោយអតិថិជន[30]។

### ៤.៦.៣ ការបន្សុទ្ធ ឬ ការកាត់កង (Netting)[31]

បន្ទាប់ពីទទួលបានព័ត៌មាន ដែលបន្សីរួចរាល់ពាក់ព័ន្ធនឹងការជួញដូរពី ប្រតិបត្តិករទីផ្សារមូលបត្ររួចហើយនោះ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវធ្វើការបន្សុទ្ធសាច់ប្រាក់និងបន្សុទ្ធមូលបត្រ ដោយយោងទៅតាមព័ត៌មានដែលទទួលបានពីការជួញដូរមូលបត្រ នៅក្នុងផ្សារមូលបត្រ កម្ពុជា។

#### ៤.៦.៣.១ និយមន័យ

ការបន្សុទ្ធឬការកាត់កង គឺជាដំណើរការនៃការកាត់បន្ថយកាតព្វកិច្ចឥណទាន ឬ ឥណពន្ធរបស់អ្នកជួញដូរពីចំនួនច្រើនទៅចំនួនតិច។ តាមរយៈការបន្សុទ្ធ ផ.ម.ក គណនាទំហំដែលត្រូវទូទាត់ចុងក្រោយ។ បន្ទាប់ពីការបន្សុទ្ធកាតព្វកិច្ចឥណទាន ឬ ឥណពន្ធដើម ត្រូវបានជំនួសដោយកាតព្វកិច្ចឥណទាន ឬ ឥណពន្ធតែមួយ។ ទំហំដែលត្រូវទូទាត់ចុងក្រោយ ត្រូវបានគណនាតាមវិធីសាស្ត្រយ៉ាងច្បាស់លាស់។

#### ៤.៦.៣.២ វិធីសាស្ត្រគណនា

បរិមាណមូលបត្រ និង ចំនួនសាច់ប្រាក់ដែលនឹងត្រូវទូទាត់ត្រូវគណនាស្របតាមវិធីសាស្ត្រនីមួយៗដូចខាងក្រោម៖

- ករណីមូលបត្រ ៖ ទទួលបានដោយធ្វើការបន្សុទ្ធ បរិមាណបានលក់សរុប និង បរិមាណ បានទិញសរុប ចំពោះប្រភេទមូលបត្រមួយ និង ចំពោះសមាជិកនីមួយៗ។
- ករណីសាច់ប្រាក់៖ ទទួលបានដោយធ្វើការផាត់ទាត់តម្លៃបានទិញសរុប និង តម្លៃបានលក់សរុប ចំពោះសមាជិកនីមួយៗ។

[30] ដកស្រង់ពីរបាយការណ៍កម្មសិក្សា, យន្តការនៃការផាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ និស្សិត ហ៊ាង បុទម្យ, ហាង ពិសី (២០១៤) ទំព័រ ៤១ ដល់ ៥១

[31] ដកស្រង់ពី http://csx.com.kh/operation/clearing/listPosts.do?MNCD=3030 ថ្ងៃទី ០៧ កក្កដា ២០១៧

**ឧទាហរណ៍១៖** ក្រុមហ៊ុន XYZ បានធ្វើការជួញដូរមូលបត្រកម្មសិទ្ធិនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃ ១៥ ខែឧសភា ឆ្នាំ២០១៦។ ការអនុវត្តការជួញដូរដូចខាងក្រោម៖

| ប្រភេទបញ្ជារ | ចំនួនភាគហ៊ុន | ថ្លៃជួញដូរ (រៀល) | ម៉ោងជួញដូរ |
|---|---|---|---|
| បញ្ជារទិញ | ១០០ | ៤៨០០ | ៩:៣០ ព្រឹក |
| បញ្ជារលក់ | ២០០ | ៤៩០០ | ៩:៤៥ ព្រឹក |
| បញ្ជាលក់ | ១០០ | ៤៨៥០ | ១០:៣០ ព្រឹក |
| បញ្ជាទិញ | ១០០ | ៤៧៥០ | ១០:៤៥ ព្រឹក |

យោងតាមការអនុវត្តការជួញដូរខាងលើ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រត្រូវការបន្សុទ្ធទាំងសាច់ប្រាក់ និង មូលបត្រជូនដល់ក្រុមហ៊ុន XYZ ដូចតទៅ៖

- ករណីបន្សុទ្ធមូលបត្រ៖ ត្រូវផាត់ទាត់បរិមាណបានលក់សរុប និង បរិមាណបានទិញសរុបចំពោះប្រភេទមូលបត្រមួយ។

  ដូច្នេះបរិមាណមូលបត្រ = (២០០ + ១០០) – (១០០ + ១០០) = ១០០ ភាគហ៊ុន
- ករណីបន្សុទ្ធសាច់ប្រាក់៖ ត្រូវផាត់ទាត់តម្លៃបានទិញសរុប និង តម្លៃបានលក់សរុប។

ចំនួនសាច់ប្រាក់ = (៤៨០,០០០៛ + ៤៧៥,០០០៛) – (៩៨០,០០០៛ + ៤៨៥,០០០៛) = **- ៥១០,០០០៛**

អាស្រ័យតាមការបន្សុទ្ធមូលបត្រ និង បន្សុទ្ធសាច់ប្រាក់ ដោយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ក្រុមហ៊ុន XYZ ត្រូវធ្វើការទូទាត់មូលបត្រចំនួន ១០០ភាគហ៊ុន ទៅអោយសមាជិកដែលត្រូវបានទទួលការទូទាត់ និងទទួលសាច់ប្រាក់ចំនួន ៥១០,០០០ ៛ ពីសមាជិកដែលត្រូវទូទាត់សាច់ប្រាក់អោយនៅកាលបរិច្ឆេទទូទាត់ (T+2) គឺនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦។

### ៤.៦.៤ លក្ខណៈនៃការទូទាត់

ជាទូទៅលក្ខណៈនៃការទូទាត់របស់ ផ.ម.ក ត្រូវបានទូទាត់តាមវិធីសាស្ត្រដូចខាងក្រោម៖

DVP (Delivery versus Payment ៖ ការប្រគល់មូលបត្រទល់នឹងការទូទាត់សាច់ប្រាក់) ជាដំណើរការនៃការប្រគល់មូលបត្រដែលត្រូវបានធ្វើឡើង នៅក្នុងពេលដំណាលគ្នានៃការប្រគល់សាច់ប្រាក់ ដោយផ្អែកលើមូលដ្ឋានបន្សុទ្ធ (ការបន្សុទ្ធមូលបត្រ និង បន្សុទ្ធសាច់ប្រាក់)។ វាត្រូវបានកើតឡើង នៅចុងគ្រានៃវដ្តដំណើរការប្រតិបត្តិការប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។

### ៤.៦.៥ ការទូទាត់សាច់ប្រាក់

ការទូទាត់សាច់ប្រាក់ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការជួញដូរមូលបត្រកម្មសិទ្ធិ។ ដូចនេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់វិនិយោគិន ក្នុងការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និង បំបាត់នូវកំហុសឆ្គង ដែលអាចកើតមានឡើងជាយថាហេតុ នៅកំឡុងពេលប្រតិបត្តិការផាត់ទាត់ និង ទូទាត់មូលបត្រ ផ្សារមូលបត្រកម្ពុជាបានបែងចែកការទូទាត់សាច់ប្រាក់ជា ០២ (ពីរ) របៀបគឺ ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយនិងការទូទាត់សាច់ប្រាក់ជាអន្តរធនាគារ។

#### ៤.៦.៥.១ ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ

ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ សំដៅដល់ការទូទាត់សាច់ប្រាក់ដែលធ្វើឡើង ចំពោះសមាជិកទាំងអ្នកត្រូវធ្វើការទូទាត់ និង អ្នកដែលត្រូវទទួលបានការទូទាត់ ទៅតាមរយៈការ ជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ ពាក់ព័ន្ធនឹងមូលបត្រនៅធនាគារដូចគ្នា។ ដូចនេះ សមាជិកទាំងសងខាងគឺសមាជិកខាងអ្នកទិញ និងសមាជិកខាងអ្នកលក់ ត្រូវធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ទៅតាមរបៀប ដូចខាងក្រោម៖




ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ

(១). មុនដល់កាលបរិច្ឆេទទូទាត់ (T+2) ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ (CSO) ចាំបាច់ត្រូវបញ្ជូនព័ត៌មាននៃការបន្សុទ្ធសាច់ប្រាក់ និង បន្សុទ្ធមូលបត្រដែលត្រូវទូទាត់ទៅកាន់ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA)។ បន្ទាប់ពីទទួលបានព័ត៌មានលម្អិតពាក់ព័ន្ធ នឹងការទូទាត់ដូចជា កាលបរិច្ឆេទទូទាត់ ចំនួនសាច់ប្រាក់ និង បរិមាណមូលបត្រត្រូវទូទាត់ ដែល

ទទួលបានតាមរយៈការបន្សុទ្ធសាច់ប្រាក់ដែលធ្វើឡើងដោយ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងព័ត៌មានផ្សេងទៀតៗដែលពាក់ព័ន្ធ។ នៅមុនម៉ោង៨និង៣០នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+2) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់អតិថិជន (CMA) ក្នុងនាមជាអ្នកទិញទៅកាន់គណនីទូទាត់សាច់ប្រាក់របស់អតិថិជនក្នុងនាមជាអ្នកទិញដូចគ្នា ដែលបើកក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ។ បន្ទាប់មកត្រូវផ្ទេរសាច់ប្រាក់ដែលត្រូវទូទាត់ពី គណនីទូទាត់សាច់ប្រាក់ក្នុងនាមអ្នកទិញបន្តទៅ គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រអោយរួចរាល់យ៉ាងយូរបំផុតត្រឹមម៉ោង៨និង៣០នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+2)។ បន្ទាប់ពីម៉ោង៨និង៣០នាទីព្រឹក នៅថ្ងៃដដែលនៃកាលបរិច្ឆេទទូទាត់ (T+2) ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រត្រូវបង្វែរជាសាច់ប្រាក់បន្ត ទៅក្នុងគណនីទូទាត់សាច់ប្រាក់របស់អតិថិជន ក្នុងនាមជាអ្នកលក់ដែលបានបើកគណនី ក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ នៅភ្នាក់ទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) យ៉ាងយូរត្រឹមម៉ោង១០និង៣០នាទីព្រឹកនៃកាលបរិច្ឆេទទូទាត់ (T+2)។ បន្ទាប់ពីម៉ោង១០និង៣០នាទីព្រឹកនៃកាលបរិច្ឆេទទូទាត់ (T+2) ក្រុមហ៊ុនមូលបត្រត្រូវផ្ទេរសាច់ប្រាក់ចូលទៅក្នុងគណនីអតិថិជនរបស់ខ្លួនដែលបានបើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រក្នុងនាមជាអ្នកលក់។

(២). បន្ទាប់ពីការទូទាត់បានបំពេញចប់សព្វគ្រប់អស់ហើយនោះ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹងដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ អំពីការទូទាត់សាច់ប្រាក់ដែលបានអនុវត្តរួចរាល់។ បន្ទាប់ពីការផ្ទេរសាច់ប្រាក់រួចរាល់ហើយ ក្រុមហ៊ុនមូលបត្រត្រូវពិនិត្យសមតុល្យសាច់ប្រាក់ក្នុងគណនីអតិថិជន នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ថាតើវាពិតជាត្រឹមត្រូវជាមួយការទូទាត់សាច់ប្រាក់នោះដែរឬទេ។

**ឧទាហរណ៍ទី២៖** យោងតាមឧទាហរណ៍ទី១ខាងលើ ប្រសិនបើក្រុមហ៊ុន XYZ បានជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ នៅក្នុងធនាគារតែមួយ ដែលដូចគ្នាជាមួយនឹងអ្នកដែលត្រូវទទួលការទូទាត់សាច់ប្រាក់អោយនោះ ប្រតិបត្តិការក្នុងការទូទាត់សាច់ប្រាក់ ក្នុងធនាគារដូចគ្នាត្រូវបានអនុវត្តទៅតាមយន្តការដូចខាងក្រោម៖

នៅមុនម៉ោង៨និង៣០នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+2) គឺនៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៦ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) ត្រូវធ្វើការផ្ទេរសាច់ប្រាក់ចំនួន ៥១០,០០០៛ ពីគណនីសាច់ប្រាក់អតិថិជន (អ្នកទិញ) ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់អ្នកទិញ រួចបន្តការបង្វែរសាច់ប្រាក់ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់

និងទូទាត់មូលបត្រ។ បន្ទាប់ពីប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រទទួលបានសាច់ប្រាក់ហើយ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវធ្វើការផ្ទេរសាច់ប្រាក់ចូលទៅក្នុងគណនីទូទាត់សាច់ប្រាក់របស់ក្រុមហ៊ុន XYZ និងបញ្ជូនសាច់ប្រាក់បន្តទៀតទៅកាន់គណនីសាច់ប្រាក់អតិថិជនរបស់ក្រុមហ៊ុន XYZ មិនអោយលើសពីម៉ោង១០និង៣០នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+2)។ បន្ទាប់ពីម៉ោង១០និង៣០នាទីព្រឹក ក្រុមហ៊ុនមូលបត្រត្រូវធានាថា ក្រុមហ៊ុន XYZ អាចដកសាច់ប្រាក់របស់ខ្លួនបាន។

បន្ទាប់ពីការផ្ទេរសាច់ប្រាក់ត្រូវបានដំណើរការចប់សព្វគ្រប់ហើយ ក្រុមហ៊ុនមូលបត្រទាំងសងខាងគឺខាងអ្នកដែលត្រូវទូទាត់អោយក្រុមហ៊ុន XYZ ត្រូវត្រួតពិនិត្យក្នុងគណនីអតិថិជនរបស់ខ្លួន ថាពិតជាបានទូទាត់សាច់ប្រាក់ចំនួន ៥១០,០០០៛ ប្រាកដមែន ចំណែកក្រុមហ៊ុនមូលបត្រខាងក្រុមហ៊ុន XYZ ក៏ត្រូវពិនិត្យមើលក្នុងគណនីអតិថិជនរបស់ខ្លួនដែរថាពិតជាបានទទួលសាច់ប្រាក់ចំនួន ៥១០,០០០៛ មែន។

#### ៤.៦.៥.២ ការទូទាត់សាច់ប្រាក់ក្នុងអន្តរធនាគារ

ការទូទាត់សាច់ប្រាក់ក្នុងអន្តរធនាគារ សំដៅដល់ការទូទាត់សាច់ប្រាក់ ដែលធ្វើឡើងចំពោះសមាជិក (អ្នកទិញ) ដែលបានបើកគណនីទូទាត់សាច់ប្រាក់ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រនៅក្នុងធនាគារមួយ (CSA1) និងសមាជិក (អ្នកលក់) ដែលបានបើកគណនីទូទាត់សាច់ប្រាក់នៅភ្នាក់ទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ក្នុងធនាគារមួយផ្សេងទៀត (CSA2)។ ការទូទាត់សាច់ប្រាក់ក្នុងអន្តរធនាគារ ត្រូវធ្វើឡើងដោយមានការឆ្លងកាត់សភាផាត់ទាត់របស់ធនាគារជាតិនៃកម្ពុជា។

នៅក្នុងការទូទាត់សាច់ប្រាក់នៅតាមរយៈធនាគារពីរផ្សេងគ្នា ត្រូវបានអនុវត្តតាមដំណាក់កាលដូចខាងក្រោម៖

(១). ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និង ទូទាត់មូលបត្រ ផ្តល់ការបង្គាប់បញ្ជារទៅលើវិធីសាស្ត្រនៃការទូទាត់ដល់ CSA1 និង CSA2។

(២). ការទូទាត់សាច់ប្រាក់រវាង CSA1និង CSA2 ត្រូវឆ្លងតាមរយៈសភាផាត់ទាត់។

☞ **កំណត់សំគាល់៖**

- **CSA1** : តំណាងអោយធនាគារដែលដើរតួនាទីជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកទិញ។

- CSA2 : តំណាងអោយធនាគារដែលដើរតួនាទីជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកលក់។




**ការទូទាត់សាច់ប្រាក់ក្នុងអន្តរធនាគារ**

នៅក្នុងការទូទាត់សាច់ប្រាក់នៅធនាគារពីរផ្សេងគ្នា ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្តល់ការប្រឹក្សាដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA1) ខាងអ្នកទិញ និង ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA2) ខាងអ្នកលក់ អំពីទម្រង់នៃការផ្ទេរសាច់ប្រាក់រវាងគ្នានឹងគ្នា។ បន្ទាប់មកមុនម៉ោង៨និង៣០នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+2) ភ្នាក់ងារទូទាត់សសាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកទិញ (CSA1) ត្រូវផ្ទេរសាច់ប្រាក់ពីគណនីអតិថិជនរបស់អ្នកទិញ ទៅកាន់គណនីទូទាត់សាច់ប្រាក់ក្នុងនាមអ្នកទិញ តែបើកក្រោមឈ្មោះរបស់

ក្រុមហ៊ុនមូលបត្រ ហើយត្រូវបង្វែរសាច់ប្រាក់បន្តទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ (CSO) ដែលបើកនៅក្នុងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកទិញ (CSA1) យ៉ាងយូរបំផុតត្រឹមម៉ោង៨និង៣០នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់ (T+2)។ ក្រោយមកទៀត CSA1 ត្រូវផ្ទេរសាច់ប្រាក់ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ដែលបើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រខាងអ្នកលក់ CSA2 ឆ្លងតាមរយៈសភាផាត់ទាត់នៃធនាគារជាតិនៃកម្ពុជា។ បន្ទាប់ពីម៉ោង៨និង៣០នាទីព្រឹក នៅថ្ងៃដដែលនៃកាលបរិច្ឆេទទូទាត់ (T+2) ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រត្រូវផ្ទេរសាច់ប្រាក់ទៅគណនីទូទាត់សាច់ប្រាក់របស់អតិថិជនដែលបើកក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA2) យ៉ាងយូរត្រឹមម៉ោង១០និង៣០នាទីព្រឹកនៃកាលបរិច្ឆេទទូទាត់ (T+2)។ បន្ទាប់ពីម៉ោង១០និង៣០នាទីព្រឹកនៃកាលបរិច្ឆេទទូទាត់ (T+2) ក្រុមហ៊ុនមូលបត្រខាងអ្នកលក់ ត្រូវផ្ទេរសាច់ប្រាក់បន្តទៅកាន់គណនីអតិថិជនរបស់អ្នកលក់។

បន្ទាប់ពីបញ្ចប់ប្រតិបត្តិការទូទាត់សាច់ប្រាក់នៅកាលបរិច្ឆេទទូទាត់ (T+2) ក្រុមហ៊ុនមូលបត្រទាំងសងខាង ត្រូវត្រួតពិនិត្យពីសមតុល្យសាច់ប្រាក់ក្នុងគណនីអតិថិជន ថាតើក្នុងគណនីអតិថិជនខាងអ្នកលក់បានទទួលសាច់ប្រាក់ដូចតាមការទូទាត់ដែរឬទេ។ នៅពេលដែលសមតុល្យសាច់ប្រាក់បានគ្រប់ចំនួនហើយ អតិថិជននឹងអាចបើកប្រាក់ដែលខ្លួនបានវិនិយោគភ្លាមៗនៅក្នុងកាលបរិច្ឆេទទូទាត់ (T+2)។

**ឧទាហរណ៍ទី៣៖** យោងតាមឧទាហរណ៍ទី១ ប្រសិនបើក្រុមហ៊ុន XYZ បានជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ នៅក្នុងធនាគារផ្សេងគ្នាពីសមាជិកដែលត្រូវទូទាត់សាច់ប្រាក់អោយនោះ ការទូទាត់សាច់ប្រាក់ គឺមានលក្ខណៈស្រដៀងគ្នានឹងការទូទាត់សាច់ប្រាក់នៅធនាគារតែមួយដែរ ប៉ុន្តែខុសគ្នាត្រង់ថា ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រធ្វើការផ្ទេរសាច់ប្រាក់រហូតដល់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ (CSO)ខាងអ្នកទិញ។ បន្ទាប់មក CSO ខាងអ្នកទិញត្រូវផ្ទេរសាច់ប្រាក់បន្តទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ CSO (ក្រុមហ៊ុន XYZ ) តាមរយៈសភាផាត់ទាត់ធនាគារជាតិនៃកម្ពុជា។ បន្ទាប់ពីនោះត្រូវបង្វែរសាច់ប្រាក់ទៅគណនីទូទាត់សាច់ប្រាក់របស់ក្រុមហ៊ុន XYZ និងជាចុងក្រោយក្រុមហ៊ុនមូលបត្រត្រូវធានាថាក្រុមហ៊ុន XYZ អាចដក់សាច់ប្រាក់របស់ខ្លួនដែលត្រូវទទួលចំនួន ៥១០,០០០៛។ បន្ទាប់ពីការផ្ទេរសាច់ប្រាក់ត្រូវបានចប់សព្វគ្រប់ហើយនោះ ក្រុមហ៊ុនមូលបត្រ

ទាំងខាងអ្នកដែលត្រូវទូទាត់អោយក្រុមហ៊ុន XYZ ត្រូវពិនិត្យមើលក្នុងគណនីអតិថិជនរបស់ខ្លួនថាពិតជាបានទូទាត់សាច់ប្រាក់ ៥១០,០០០៛ ប្រាកដមែន ឯខាងក្រុមហ៊ុន XYZ ក៏ត្រូវពិនិត្យមើលក្នុងគណនីអតិថិជនដូចគ្នាដែរ ថាប្រាកដជាបានទទួលសាច់ប្រាក់ចំនួន ៥១០,០០០៛ មែន។

### ៤.៦.៦ ការទូទាត់មូលបត្រ

ការទូទាត់មូលបត្រ ក៏ជាផ្នែកដ៏សំខាន់ណាស់ដែរ ក្នុងប្រតិបត្តិការជួញដូរមូលបត្រ។ យោងតាមរយៈវិធីសាស្ត្រនៃការទូទាត់គឺ ត្រូវទូទាត់តាម DVP ដែលជាដំណើរការដែលការប្រគល់មូលបត្រ ត្រូវធ្វើឡើងស្របពេលគ្នា នៃការប្រគល់សាច់ប្រាក់ ដូច្នេះក្នុងពេលដែលធ្វើការទូទាត់សាច់ប្រាក់ ក៏ត្រូវទូទាត់មូលបត្រនៅកាលបរិច្ឆេទទូទាត់ (T+2) ដូចគ្នាដែរ។ ការទូទាត់មូលបត្រត្រូវអនុវត្តតាមវិធីដូចខាងក្រោម៖




(១). ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ (CSO) ទទួលខុសត្រូវទាំងការបន្សុទ្ធសាច់ប្រាក់ និងការបន្សុទ្ធមូលបត្រ។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ជូនដំណឹងដល់ប្រតិបត្តិកររក្សាទុកមូលបត្រនិងប្រតិបត្តិករទីផ្សារមូលបត្រ អំពីការទូទាត់សាច់ប្រាក់ត្រូវបានបំពេញរួចរាល់ចប់សព្វគ្រប់អស់ហើយ។ បន្ទាប់មកប្រតិបត្តិកររក្សាទុកមូលបត្រត្រូវផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្រ (SF) ដែលតំណាងអោយអតិថិជន (អ្នកលក់) ទៅកាន់គណនីទូទាត់មូលបត្ររបស់ CSO ដែលបានបើកនៅក្នុងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីធ្វើការផាត់ទាត់មូលបត្រ នៅពេលមានប្រតិបត្តិការជួញដូរមូលបត្រកើតមានឡើង។ ក្រោយមកទៀត ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និង ទូទាត់មូលបត្រ (CSO) ត្រូវធ្វើការផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ខ្លួន ទៅកាន់គណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្រ (SF) ដែលតំណាងអោយអតិថិជន (អ្នកទិញ)។

(២). បន្ទាប់ពីការផ្ទេរមូលបត្រទៅកម្មសិទ្ធិករ ត្រូវបានបំពេញបានត្រឹមត្រូវរួចរាល់អស់ហើយនោះ ប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវជូនដំណឹងទៅកាន់តួអង្គដែលពាក់ព័ន្ធក្នុងការផាត់ទាត់មូលបត្រ ដូចជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ប្រតិបត្តិករទីផ្សារមូលបត្រ និង ក្រុមហ៊ុនមូលបត្រទាំងសងខាង។

## ៤.៧ ការប្រគល់ឯកសារទូទាត់មូលបត្រ[32]

មុននិងក្រោយពេលធ្វើប្រតិបត្តិការផាត់ទាត់និងទូទាត់ ត្រូវមានការប្រគល់ឯកសារទូទាត់ ដើម្បីបញ្ជាក់ពីការទទួលបានព័ត៌មានស្តីពីការផាត់ទាត់និងទូទាត់ និង ព័ត៌មានក្រោយពីបញ្ចប់ការទូទាត់។ ដំណើរការនៃការផ្តល់ឯកសារត្រូវបានអនុវត្តដូចខាងក្រោមនេះ៖

- ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបានផ្តល់នូវឯកសារបង្គាប់ទូទាត់ដែលរួមមានព័ត៌មានលម្អិតលើមូលបត្រ និង សាច់ប្រាក់ដែលត្រូវទូទាត់ជូនដល់សមាជិក ក្រោយការបិទទីផ្សារតាមរយៈប្រព័ន្ធកុំព្យូទ័រ។
- សមាជិកត្រួតពិនិត្យពីបរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ ដែលត្រូវទូទាត់នៅលើឯកសារបង្គាប់ទូទាត់ និង ត្រូវធ្វើការទូទាត់ទៅតាមពេលវេលាកំណត់។
- សមាជិកត្រូវប្រគល់ឯកសារទូទាត់ដែលមានព័ត៌មានលម្អិត និង ពេលវេលានៃការទូទាត់ជាដើមជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រក្រោយពីបញ្ចប់ការទូទាត់។

## ៤.៨ វិធានការបរាជ័យនៃការផាត់ទាត់និងទូទាត់

រាល់ការផាត់ទាត់និងទូទាត់ទាំងអស់ មិនប្រាកដថា ទទួលបានជោគជ័យទាំងអស់នោះទេ។ ពេលខ្លះបរាជ័យក៏អាចកើតឡើង ក្នុងករណីណាមួយដែលធ្វើអោយអ្នកដែលត្រូវទូទាត់មិនអាចធ្វើទៅបានដូចជាអ្នកដែលត្រូវទូទាត់សាច់ប្រាក់មិនអាចទូទាត់បាន ព្រោះនៅពេលដែលដល់កាលបរិច្ឆេទទូទាត់ (T+2) បែរជាខ្វះសាច់ប្រាក់។ ចំណែកអ្នកដែលត្រូវទូទាត់មូលបត្រមិនអាចផ្ទេរទៅបានព្រោះដល់កាលបរិច្ឆេទទូទាត់ (T+2) បែរជាខ្វះមូលបត្រជាដើម។ ខាងក្រោមនេះនឹងបញ្ជាក់អំពីវិធានក្នុងការពិន័យចំពោះការទូទាត់បរាជ័យដូចជា៖

- ករណីដែលសមាជិកណាមួយគ្មានលទ្ធភាពធ្វើការទូទាត់ការជួញដូររបស់ខ្លួនប្រតិបត្តិ

[32] ប្រការ ១១ នៃប្រកាសស្តីពី វិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ អាចលុបចោលនូវការជួញដូរដែលបានប្រតិបត្តិការហើយ ទាំងស្រុង ឬ មួយផ្នែក នៅក្នុង ផ.ម.ក និងព្យួរការជួញដូររបស់សមាជិកនោះ នៅក្នុងរយៈពេល កំណត់ណាមួយ។

- ករណីដែលមានកង្វះខាតសាច់ប្រាក់ក្នុងការទូទាត់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និង ទូទាត់មូលបត្រ ត្រូវធ្វើការទូទាត់ ដោយសុំខ្ចីនូវមូលបត្រប្រភេទដូចគ្នាពីសមាជិកផ្សេងៗទៀត។ ប្រសិនបើការសុំខ្ចី និង ការអោយខ្ចីមិនអាចធ្វើទៅបាន ការទូទាត់នឹងត្រូវលុបចោល។ ប្រសិនបើ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ មិនអាចរិះរកមធ្យោបាយដើម្បីធ្វើការទូទាត់បានតាម រយៈការប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីធានការទូទាត់ ឬ ការសុំខ្ចីនូវមូលបត្រប្រភេទដូចគ្នាពី សមាជិកផ្សេងទៀត ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ អាចចាត់វិធានការដូចជា លុប ចោលនូវការជួញដូរដែលបានប្រតិបត្តិការហើយទាំងស្រុង ឬ មួយផ្នែក នៅក្នុងផ្សារមូលបត្រកម្ពុជា និង ព្យួរការជួញដូររបស់សមាជិកនោះនៅក្នុងរយៈពេលកំណត់ណាមួយ។

## ៤.៩ កម្រៃសេវាផាត់ទាត់និងទូទាត់

នៅក្នុងយន្តការនៃការផាត់ទាត់និងទូទាត់មូលបត្រកម្មសិទ្ធិ វិនិយោគិនត្រូវបង់នូវកម្រៃសេវា ផាត់ទាត់និងទូទាត់មូលបត្រ ទៅតាមនីតិវិធីខាងក្រោម៖

- **ថ្លៃសេវាផាត់ទាត់និងទូទាត់មូលបត្រ**[33]

សមាជិកត្រូវបង់កម្រៃសេវាផាត់ទាត់និងទូទាត់មូលបត្រ ជូនចំពោះប្រតិបត្តិករប្រព័ន្ធផាត់ ទាត់និងទូទាត់មូលបត្រទៅតាមអត្រានិងពេលវេលាដូចខាងក្រោម៖

(១). កម្រៃសេវាសម្រាប់សេវាផាត់ទាត់និងទូទាត់ ត្រូវយកលើតម្លៃជួញដូរ ដែលត្រូវបាន ទូទាត់ (ទឹកប្រាក់កម្រៃសេវាត្រូវកាត់កៀសមកត្រឹមមួយខ្ទង់) តាមអត្រា ៥/១០,០០០ (ប្រាំភាគមួយ ម៉ឺន) ឬ ០.០៥% (សូន្យក្បៀសសូន្យប្រាំភាគរយ)។

(២). អ្នកបង់កម្រៃសេវាគឺក្រុមហ៊ុនមូលបត្រដែលជាសមាជិកនៃប្រតិបត្តិករផាត់ទាត់និង ទូទាត់មូលបត្រ។

[33] ប្រកាសលេខ០០៣/១៧ គ.ម.ក ប្រ.ក ចុះថ្ងៃទី ០៩មករា ឆ្នាំ២០១៧ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

(៣). ពេលវេលានៃការបង់កម្រៃសេវាគឺនៅម៉ោង៨និង៣០នាទីព្រឹក នៃកាលបរិច្ឆេទទូទាត់។ ចំពោះការផ្ទេរមូលបត្រពីគណនីមួយទៅគណនីមួយផ្សេងទៀត ការបង់នូវកម្រៃសេវានេះយកខុសពីការបង់កម្រៃសេវាក្នុងការផាត់ទាត់និងទូទាត់មូលបត្រ។

ថ្លៃសេវាសម្រាប់ផាត់ទាត់ និងទូទាត់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី១ ចំណុចទី១ ខាងលើត្រូវកាត់បន្ថយចំនួន ៥០% មកត្រឹមអត្រា ២.៥/១០,០០០ (ពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ ០.០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ) អនុវត្តរហូតដល់មានការជូនដំណឹងជាថ្មី។

- **កម្រៃសេវានៃការផ្ទេរមូលបត្ររវាងគណនី (Book-entry Fee)**

(១). អត្រាប្រាក់កម្រៃនៃការផ្ទេរមូលបត្ររវាងគណនី ត្រូវគណនាលើមូលដ្ឋាន ទឹកប្រាក់នៃការជួញដូរដែលត្រូវបានទូទាត់តាមអត្រា ១០/១០,០០០ (ដប់ភាគមួយម៉ឺន) ចំពោះមូលបត្រកម្មសិទ្ធិហើយទឹកប្រាក់កម្រៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។

(២). អ្នកត្រូវបង់ប្រាក់គឺជាក្រុមហ៊ុនមូលបត្រដែលជាសមាជិក។

(៣). ពេលវេលានៃការបង់កម្រៃសេវាក្នុងការផ្ទេរមូលបត្រគឺនៅម៉ោង៨និង៣០នាទីព្រឹកនៃកាលបរិច្ឆេទទូទាត់។

## ៤.១០ ដំណើរការនៃការដាក់ និងដកសាច់ប្រាក់ជួញដូរមូលបត្រ[34]

### ៤.១០.១ ការដាក់សាច់ប្រាក់សម្រាប់ការជួញដូរ

វិនិយោគិនអាចធ្វើការជ្រើសរើសយកនូវវិធីសាស្ត្រណាមួយខាងក្រោមក្នុងការដាក់សាច់ប្រាក់:

- ការដាក់សាច់ប្រាក់ដោយផ្ទាល់ក្នុងប្រទេស
- ផ្ទេរសាច់ប្រាក់ពីគណនីធនាគារក្នុងប្រទេស
- ផ្ទេរសាច់ប្រាក់ពីក្រៅប្រទេសតាមរយ:គណនីធនាគារ
- ផ្ទេរសាច់ប្រាក់ពីក្រៅប្រទេសដោយផ្ទាល់ទៅក្នុងគណនីជួញដូរ

វិនិយោគិនអាចដាក់ប្រាក់ចូលក្នុងគណនីជួញដូររបស់ពួកគាត់នៅកន្លែងភ្នាក់ងារផ្តល់សេវាកម្មរបស់ធនាគារកាណាឌីយ៉ា ឬក៏តាមគ្រប់សាខារបស់ធនាគារកាណាឌីយ៉ាណាមួយ ដោយគ្រាន់តែផ្តល់នូវពត៌មានច្បាស់លាស់ដូចខាងក្រោម:

[34] ដំណើរការនៃការដាក់ និងដកសាច់ប្រាក់ជួញដូរ http://www.canasecurities.com.kh/kh/121/cash-deposit-withdrawal-instruction?m_id=124 ចូលដកស្រង់ថ្ងៃទី ០៧ កក្កដា ឆ្នាំ ២០១៧។

**ក.ការដាក់សាច់ប្រាក់ដោយផ្ទាល់ក្នុងប្រទេស**

ឈ្មោះក្រុមហ៊ុនមូលបត្រ/លេខកូដ: ABC Securities Plc

លេខអត្តសញ្ញាណវិនិយោគិន: xxxxxxxxxxxx

លេខគណនីជួញដូរ: xxxxxx

ឈ្មោះគណនីជួញដូរ: ……………………………

ទូរស័ព្ទសំរាប់ទំនាក់ទំនង: ……………………………

**ខ.ផ្ទេរសាច់ប្រាក់ពីគណនីធនាគារក្នុងប្រទេស**

វិនិយោគិនអាចផ្ទេរសាច់ប្រាក់ពីគណនីសន្សំរបស់ពួកគាត់ទៅគណនីជួញដូរនៅកន្លែងភ្នាក់ងារផ្តល់សេវាកម្មរបស់ធនាគារកាណាឌីយ៉ាដោយផ្តល់ពត៌មានច្បាស់លាស់ដូចខាងក្រោម:

ឈ្មោះគណនីធនាគារ: ........................................

លេខគណនីធនាគារ: x xxxxxxxxxxxxx

ឈ្មោះក្រុមហ៊ុនមូលបត្រ/លេខកូដ: ABC Securities Plc

ឈ្មោះគណនីជួញដូរ: ……………………………........

លេខអត្តសញ្ញាណវិនិយោគិន: x xxxxxxxxxxx

លេខគណនីជួញដូរ:x xxxxx

**គ.ផ្ទេរសាច់ប្រាក់ពីក្រៅប្រទេសតាមរយៈគណនីធនាគារ**

វិនិយោគិនអាចធ្វើការផ្ទេរសាច់ប្រាក់ពីក្រៅប្រទេសចូលក្នុងគណនីជួញដូរតាមរយៈធនាគារក្នុងស្រុករបស់ពួកគាត់ដោយត្រូវធ្វើតាមជំហានដូចខាងក្រោម:

**ជំហានទី1**:ផ្ទេរសាច់ប្រាក់ពីក្រៅប្រទេសមកកាន់ធនាគារក្នុងស្រុក

ពត៌មានសំខាន់ៗមួយចំនួនសំរាប់ការផ្ទេរ:

លេខSWIFTរបស់ធនាគារ:CADIKHPP

អាស័យដ្ឋាន: ធនាគារកាណាឌីយ៉ា

អាគារ315, ផ្លូវអង្គឌួង(កាច់ជ្រុងមហាវិថីព្រះមុនីវង្ស),ភ្នំពេញ, កម្ពុជា

**អតិថិជនដែលជាអ្នកទទួលផល:**

ឈ្មោះគណនី: ........................................

លេខគណនីធនាគារ: x xxxxxxxxxxxx

**ជំហានទី2**:ក្នុងការផ្ទេរពីគណនីធនាគារទៅកាន់គណនីជួញដូរ សូមអនុវត្តដូចរបៀបដែលបានបង្ហាញខាងលើ"ផ្ទេរសាច់ប្រាក់ពីគណនីធនាគារក្នុងប្រទេស"ក្នុងករណីដែលសាច់ប្រាក់ត្រូវបានទូទាត់និងដាក់ក្នុងគណនីធនាគាររួចរាល់។

លេខSWIFTរបស់ធនាគារ:CADIKHPP

អាស័យដ្ឋាន: ធនាគារកាណាឌីយ៉ា

អាគារ315, ផ្លូវអង្គឌួង(កាច់ជ្រុងមហាវិថីព្រះមុនីវង្ស),ភ្នំពេញ, កម្ពុជា

**អតិថិជនដែលជាអ្នកទទួលផល:**

ឈ្មោះគណនី: CANA SEC.(CASH COLLECTION)

លេខគណនី: 00100001568308

**គ.ផ្ទេរសាច់ប្រាក់ពីក្រៅប្រទេសដោយផ្ទាល់ទៅក្នុងគណនីជួញដូរ**

**ពត៌មានក្នុងការផ្ទេរប្រាក់:**

ឈ្មោះគណនីជួញដូរ: …………………………….

លេខគណនីជួញដូរ: x xxxxx

ឈ្មោះក្រុមហ៊ុនមូលបត្រ/លេខកូដ៖ Cana Securities Ltd/CNS



ឧទាហរណ៍៖ការដាក់សាច់ប្រាក់ជួញដូរមូលបត្ររវាងក្រុមហ៊ុនភ្នំពេញស៊ីឃ្យូរីធី ភីអិលស៊ី(PPS) និង ធនាគារកាណាឌីយ៉ា(CNB)




## លិខិតគម្រូដាក់សាច់ប្រាក់ជួញដូរចូលក្នុងគណនីក្រុមហ៊ុនPPSនៅCNB


"寒币"存款确认单 （证券结算帐户专用）
"RIEL CURRENCY"DEPOSIT ACKNOWLEDGEMENT SLIP
加 華 銀 行
CANADIA BANKPLC.
日期 DATE: 27/04/2012

证券公司名称 NAME OF SECURITIES FIRM: Phnom Penh Securities PLC.
投资者身份证号 INVESTOR ID NO.:
投资者名称 INVESTOR NAME: Rich Man
证券公司代号 SECURITIES FIRM CODE: 01001
证券客户账号 SECURITIES TRADING A/C NO.: 001**1

☑ 以现金 IN CASH
☐ 以帐户转帐 BY A/C TRANSFER — 名称 NAME: — 帐号 NO.:
☐ 其他银行支票 OTHER BANK CHEQUE — 银行名称 BANK NAME: — 支票号码 CHEQUE NO.:

存入证券公司"客户款项帐户"
CREDIT TO SECURITYES FIRM "CLIENT MONEY A/C"
帐户名 A/C NAME: Phnom Penh Securities PLC
帐号 A/C NO.: 001-0001-568189

寒币 RIEL: Ten million one hundred sixty thousand KHR only — RIEL 10,160,000

客户签字和/或盖章
SIGNATURE &/OR STAMP OF INVESTOR

AUTHORIZED SIGNATURE — VERIFIED — TELLER

## លិខិតគម្រូផ្ទេរប្រាក់ជួញដូរពីធនាគារក្រៅប្រទេសចូលក្នុងគណនីក្រុមហ៊ុនPPSនៅCNB


第一商業銀行
FIRST COMMERCIAL BANK
第一聯：申請書
匯出匯款申請書
Outward Remittance Application Form
受理單位代號：金達分行
申請日期： Date 年 Y 月 M 日 D

| | |
|---|---|
| 申請人 (Applicant) 中英文全名: applicant's name | Rich Man |
| 地址及電話: address and telephone no. | No. 12, Chungzen Rd., New Taipei City, Taiwan |
| 統一編號: enterprise registration/resident identification card/passport no. | A123987654 |
| 出生年月日: date of birth | 1980/11/16 |
| 受款人 (Remittee) 全名: remittee's name | Phnom Penh Securities PLC |
| 地址: remittee's address | No. 32, Monivong Blvd., Phnom Penh, Cambodia |
| 帳號: account no. | 001-0003-568189 |
| 往來銀行及地址: remittee bank's name and address | Canadia Bank PLC, Canadia Tower, No. 315, Ang Duong St., Phnom Penh, Cambodia |
| 匯款用途及附言 (用英文填寫): remittance's usage | Investor ID / Trading A/C / Investor name — Rich Man |
| 匯款金額合計: total remittance amount | USD |

申請人簽章 applicant's signature/seal
受款地區國別: country of remittance's destination — Cambodia
匯款性質: type of remittance — 進口貨品價款 import proceeds
國外受款身分別: remittee's status — 政府 government / 公營事業 government-owned enterprise / 民間 others
匯款方式 (transfer method): 電匯(W) telex transfer 金額 amount; 信匯(Z/W) mail transfer 金額 amount; 票匯(Y) demand draft 金額 amount
手續費 service's rate
郵電費 telex/mail fees
付款行：
劃帳行：
匯款分類及名稱及編號：
總繳總額 total payment amount
編號：
受理單位 主管 經辦

### ៤.១០.២ ការដកសាច់ប្រាក់ជួញដូរ

វិនិយោគិនអាចជ្រើសរើសវិធីសាស្ត្រណាមួយខាងក្រោម ក្នុងការដកប្រាក់ពីគណនីជួញដូរ:

- ការដកសាច់ប្រាក់ដោយផ្ទាល់នៅក្នុងប្រទេស
- ការដកសាច់ប្រាក់ដោយផ្ទេរតាមគណនីធនាគារក្នុងប្រទេស
- ការផ្ទេរសាច់ប្រាក់ទៅគណនីធនាគារក្រៅប្រទេសដោយផ្ទេរតាមគណនីធនាគារក្នុងប្រទេស
- ការផ្ទេរសាច់ប្រាក់ទៅធនាគារក្រៅប្រទេសដោយផ្ទាល់តាមរយៈការដកសាច់ប្រាក់សុទ្ធ

#### ក.ការដកសាច់ប្រាក់ដោយផ្ទាល់នៅក្នុងប្រទេស

វិនិយោគិនអាចធ្វើការស្នើសុំដកសាច់ប្រាក់ពីគណនីជួញដូររបស់ពួកគេដោយធ្វើតាមជំហានដូចខាងក្រោម៖

**ជំហានទី 1**: ស្នើសុំដកសាច់ប្រាក់នៅក្រុមហ៊ុនកាណាស៊ីយូរីធី

ឈ្មោះគណនីជួញដូរ: ....................................

លេខគណនីជួញដូរ: x xxxxx

លេខអត្តសញ្ញាណវិនិយោគិន: x xxxxxxxxxxx

ចំនួនប្រាក់ដែលដកជាប្រាក់រៀល: .............(៛)

**ជំហានទី 2**:ការដកសាច់ប្រាក់ធ្វើឡើងនៅធនាគារកាណាឌីយ៉ា

ពត៌មាន ដែលត្រូវផ្តល់ឲ្យភ្នាក់ងាររបស់ធនាគារ

ឈ្មោះគណនីជួញដូរ : .............................

លេខគណនីជួញដូរ : x xxxxx

លេខអត្តសញ្ញាណវិនិយោគិន: x xxxxxxxxxxx

ចំនួនសាច់ប្រាក់ដែលដកជាប្រាក់រៀល: ...............(៛)

*ឯកសារដែលត្រូវការ៖អត្តសញ្ញាណប័ណ្ណ/ លិខិតឆ្លងដែនរបស់អតិថិជន

**ខ.ការដកសាច់ប្រាក់ដោយផ្ទេរតាមគណនីធនាគារក្នុងប្រទេស**

វិនិយោគិនអាចធ្វើការស្នើសុំផ្ទេរសាច់ប្រាក់ពីគណនីជួញដូរទៅក្នុងគណនីធនាគារក្នុងប្រទេសបានដោយអនុវត្តន៍តាមជំហានខាងក្រោម៖

**ជំហានទី 1**៖ ស្នើសុំដកសាច់ប្រាក់នៅក្រុមហ៊ុនកាណាស៊ីយូរីធី

ឈ្មោះគណនីជួញដូរ: .......................................

លេខគណនីជួញដូរ: x xxxxx

លេខអត្តសញ្ញាណវិនិយោគិន: x xxxxxxxxxxxxx

ចំនួនសាច់ប្រាក់ដែលដកជាប្រាក់រៀល: ...........(៛)

លេខគណនីធនាគារ: x xxxxx xxxxxx xx

* ឯកសារដែលត្រូវការ៖ សៀវភៅធនាគារ

**ជំហានទី 2**៖ ការផ្ទេរសាច់ប្រាក់នៅធនាគារកាណាឌីយ៉ា

ពត៌មានដែលត្រូវផ្តល់ឲ្យភ្នាក់ងារធនាគារ

ឈ្មោះគណនីជួញដូរ: .......................................

លេខគណនីជួញដូរ: x xxxxx

លេខអត្តសញ្ញាណវិនិយោគិន: x xxxxxxxxxxxxx

ចំនួនសាច់ប្រាក់ដែលដកជាប្រាក់រៀល: ...........(៛)

ឈ្មោះគណនីធនាគារ: .....................................

លេខគណនីធនាគារ: x xxxxx xxxxxx xx

ចំណាំ:ប្រតិបត្តិការនេះក៏អាចធ្វើឡើងដោយក្រុមហ៊ុនកាណាស៊ីយូរីធី

**គ.ការផ្ទេរសាច់ប្រាក់ទៅគណនីធនាគារក្រៅប្រទេសដោយផ្ទេរតាមគណនីធនាគារក្នុងប្រទេស**

វិនិយោគិនអាចដកសាច់ប្រាក់ ដោយស្នើសុំឲ្យភ្នាក់ងារធនាគារកាណាឌីយ៉ាធ្វើការផ្ទេរសាច់ប្រាក់ពីគណនីធនាគារក្នុងប្រទេសចូលទៅគណនីធនាគាររបស់គាត់នៅក្រៅប្រទេសដោយធ្វើតាមជំហានដូចខាងក្រោម:

**ជំហានទី1**:អនុវត្តតាមជម្រើសខាងលើ"ការដកសាច់ប្រាក់ដោយផ្ទេរតាមគណនីធនាគារក្នុងប្រទេស"។

**ជំហានទី 2**:ស្នើសុំផ្ទេរសាច់ប្រាក់នៅធនាគារកាណាឌីយ៉ាក្នុងប្រទេស

បន្ទាប់ពីដកសាច់ប្រាក់ពីគណនីជួញដូររួច វិនិយោគិនអាចស្នើរឲ្យធនាគារផ្ទេរសាច់ប្រាក់ចូលទៅក្នុងគណនីរបស់ពួកគេនៅក្រៅប្រទេសបានដោយអនុវត្តន៍តាមវិធីខាងក្រោមៈ

លេខកូដSWIFTធនាគារក្រៅប្រទេស: ……………

ឈ្មោះធនាគារ : ……………………………….

អាស័យដ្ឋានធនាគារ: ……………………………….

ឈ្មោះគណនី : ……………………………….

លេខគណនី : ……………………………….

**ឃ.ការផ្ទេរសាច់ប្រាក់ទៅធនាគារក្រៅប្រទេសដោយផ្ទាល់តាមរយៈការដកសាច់ប្រាក់សុទ្ធ**

វិនិយោគិនអាចដកសាច់ប្រាក់ពីគណនីជួញដូរ និងផ្ទេរទៅកាន់គណនីធនាគារក្រៅប្រទេសបានដោយអនុវត្តតាមជំហានខាងក្រោមៈ

**ជំហានទី1**:អនុវត្តតាមជម្រើសខាងលើ"ការដកសាច់ប្រាក់ដោយផ្ទាល់ក្នុងប្រទេស"

**ជំហានទី 2**:ស្នើសុំផ្ទេរសាច់ប្រាក់នៅធនាគារកាណាឌីយ៉ាទៅគណនីធនាគារក្រៅប្រទេសដោយផ្តល់នូវពត៌មានយ៉ាងច្បាស់ដូចខាងក្រោម:

លេខកូដSWIFTធនាគារក្រៅប្រទេស: ……………

ឈ្មោះធនាគារ : ……………………………….

អាស័យដ្ឋានធនាគារ : ……………………………….

ឈ្មោះគណនី : ………………………………..

លេខគណនី : ………………………………..




ឧទាហរណ៍៖ការដកប្រាក់ជួញដូរមូលបត្ររវាងក្រុមហ៊ុនភ្នំពេញស៊ីឃ្យូរីធី ភីអិលស៊ី(PPS) និង ធនាគារកាណាឌីយ៉ា(CNB)



## លិខិតគម្រូនៃការដកសាច់ប្រាក់នៅធនាគារកាណាឌីយ៉ាចេញដោយក្រុមហ៊ុនភ្នំពេញស៊ីឃ្យូរីធី




## លិខិតគម្រូនៃការដកសាច់ប្រាក់តាមរយៈការផ្ទេរទៅធនាគារកាណាឌីយ៉ា



# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយយ៉ាងក្បោះក្បាយខាងលើនេះ បានសបញ្ជាក់អោយឃើញថា ប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រពិតជាបានផ្តល់អត្ថប្រយោជន៍យ៉ាងខ្លាំងចំពោះវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ពីព្រោះថាប្រព័ន្ធនេះជាដំណើរការដ៏សំខាន់ក្នុងការជួញដូរមូលបត្រ ហើយការជួញដូរមូលបត្រក៏មិនអាចបញ្ចប់ទៅបានដោយគ្មានប្រព័ន្ធមួយនេះដែរ។បន្ថែមពីនេះការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះក៏បានលើកបង្ហាញពីប្រតិបត្តិការផ្សេងៗក្នុងវិស័យមូលបត្រផងដែរដូចជា៖

នៅក្នុងជំពូកទី១ ដែលជាដំណាក់កាលបង្ហាញដំបូងនៃអត្ថបទសារណា បានលើកបង្ហាញអោយសិស្ស និស្សិតបានដឹងអំពីអ្វីទៅដែលយើងហៅថាមូលបត្រ ហើយវាមានប៉ុន្មានប្រភេទ ហើយគុណប្រយោជន៍ដែលវិនិយោគិនទទួលបានពីវាមានអ្វីខ្លះ។

ចំណុចសំខាន់បន្ទាប់ត្រូវបានលើកឡើងនៅក្នុងជំពូកទី២ ដែលបង្ហាញអំពីប្រតិបត្តិការនៃការជួញដូរមូលបត្រ និងនីតិវិធីខ្លះៗ មុននឹងអាចឈានដល់ការជួញដូរមូលបត្របាន។វាគឺជាគ្រឿងបណ្តុះគំនិតដ៏សំខាន់សម្រាប់សិស្ស និស្សិត វិនិយោគិនដែលចង់ដឹងថាខ្លួនឯងត្រូវធ្វើអ្វីខ្លះមុននឹងអាចធ្វើការជួញដូរមូលបត្របាន។

ចំណែកចំណុចស្នូល ឬយើងអាចនិយាយបានថាជាតួឯកនៃប្រធានបទគឺត្រូវបានលើកយកមកបង្ហាញនៅក្នុងជំពូកទី៣ និងទី៤ ដែលយើងបង្ហាញពីវិធាននៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា និងបានបន្ស៊ីទៅនឹងភាពជាក់ស្តែងនៃការទូទាត់សាច់ប្រាក់ទាក់ទងនឹងវិស័យមូលបត្រនេះតាមរយៈប្រតិបត្តិការរបស់ធនាគារកាណាឌីយ៉ាដែលវិនិយោគិនអាចសម្រេចចិត្តជ្រើសរើសវិធីសាស្ត្រណាមួយក្នុងចំណោមវិធីសាស្ត្រជាច្រើនដែលបានលើកមកបង្ហាញក្នុងការទូទាត់សាច់ប្រាក់ប្រកបដោយភាពងាយស្រួល និងការលើកឧទាហរណ៍បន្ថែមជាមួយក្រុមហ៊ុនភ្នំពេញស៊ីយ៉ូវីធី ភីអិលស៊ីដែលជាក្រុមហ៊ុនបោះផ្សាយមូលបត្រក្នុងប្រទេសកម្ពុជា។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា តាមរយៈចំណេះដឹង និងពត៌មានដែលយើងខ្ញុំខិតខំស្រាវជ្រាវលើប្រធានបទស្តីពី "**ដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រ**" និងអាចផ្តល់ជាគន្លឹះ និងចំណេះដឹងបន្ថែមសម្រាប់សិស្សនិស្សិតជំនាន់ក្រោយ និងអាចយកប្រធានបទនេះធ្វើជាស្ពានឈានបន្តទៅរកការស្រាវជ្រាវបន្ថែមទៀតអោយកាន់តែមានភាពស៊ីជម្រៅ និងច្បាស់លាស់ជាងនេះមួយកម្រិតទៀត។

## ២.អនុសាសន៍

ដើម្បីរួមចំណែកក្នុងការធ្វើអោយដំណើរការផាត់ទាត់ និងទូទាត់មូលបត្រមានភាពភាពងាយស្រួល និងទទួលបានភាពជោគជ័យ យើងខ្ញុំសូមចូលរួមនូវមតិមួយចំនួនខាងក្រោម៖

- គួររៀបរៀង ឬធ្វើការបកស្រាយច្បាប់ បទបញ្ញត្តិ អនុក្រឹត្យ និងគោលការណ៍ណែនាំផ្សេងៗ ទៅជាសៀវភៅណែនាំលំអិតស្តីពីដំណើការផាត់ទាត់ និងទូទាត់មូលបត្រអោយប្រជាពលរដ្ឋ សិស្សានុសិស្ស វិនិយោគិនងាយស្រួលក្នុងការស្វែងយល់ ចៀសវាងការភ័ន្តច្រលំ។
- គួរបង្កើនការធ្វើសិក្ខាសាលាជាសាធារណៈលើផ្នែកនេះអោយកាន់តែទូលំទូលាយ។
- គួរគប្បីបង្កើតប្រព័ន្ធពត៌មាននៅលើបណ្តាញអ៊ីនធឺណេតអោយកាន់តែទូលំទូលាយជាងនេះ។

# ឯកសារយោង

# ឯកសារយោង


## ច្បាប់ និងបទបញ្ញត្តិផ្សេងៗទាក់ទងនឹងវិស័យមូលបត្រ

១) ប្រកាសលេខ០០៣/១៧ គ.ម.ក ប្រ.ក ចុះថ្ងៃទី ០៩មករា ឆ្នាំ២០១៧ ស្តីពីវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា លើការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

២) ប្រកាសស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

## សៀវភៅ និងអត្ថបទសិក្សាផ្សេងៗ

៣) សាស្ត្រាចារ្យ ឈាង ហ៊ុយ (២០១៥-២០១៦), មូលដ្ឋានគ្រឹះនៃការវិនិយោគ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

៤) និស្សិត ហ៊ាង បុទម្យ និងហង់ ពិសី (២០១៤), "យន្តការនៃការផាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ", សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

៥) និស្សិត គន្ធ សម្បត្តិ និងអ៊ឹង ឆាយហួត (២០១៤), "ការគ្រប់គ្រងហានិភ័យលើការវិនិយោគមូលបត្រ", សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យសាស្ត្រសេដ្ឋកិច្ច។

## ឯកសារជាភាសាបរទេស

៦) Fundamentals of Investing, 9th Edition by LAWRENCE J. GITMAN and MICHAEL JOEHNK, San Diego State University and Arizona State University.

## គេហទំព័រអ៊ីនធឺណេត

៧) និយមន័យនៃមូលបត្រ www.thestreet.com/topic/47042/securities.html និង www.thebalance.com/securities-definition-and-effect-on-the-u-s-economy-3305961 ចូលដកស្រង់ថ្ងៃទី ២៦ មេសា ឆ្នាំ ២០១៧។

៨) http://www.investopedia.com/terms/c/commonstock.asp ដកស្រង់ថ្ងៃទី ៣០ មេសា ២០១៧។

៩) https://www.mtholyoke.edu/courses/sgabriel/securities1/stock/stockprofits.htm ដកស្រង់ថ្ងៃទី ០២ ឧសភា ២០១៧។

១០) http://www.investopedia.com/terms/m/marketcapitalization.asp ដកស្រង់ថ្ងៃទី ០២ ឧសភា ២០១៧។

១១) https://www.accountingcoach.com/stockholders-equity/explanation/2 ថ្ងៃទី ០២ ឧសភា ២០១៧។

១២) http://www.investopedia.com/terms/s/stocksplit.asp ដកស្រង់ថ្ងៃទី ០២ ឧសភា ២០១៧។

១៣) https://www.accountingcoach.com/blog/what-is-preferred-stock ដកស្រង់ថ្ងៃទី ០៣ ឧសភា ២០១៧។

១៤) http://www.investopedia.com/terms/b/bond.asp ដកស្រង់ថ្ងៃទី ០៣ ឧសភា ២០១៧។

១៥) http://thismatter.com/money/stocks/settlement-and-clearing.htm ចូលដកស្រង់ថ្ងៃទី ២០ មិថុនា ឆ្នាំ ២០១៧។

១៦) ប្រវត្តិទីផ្សារមូលបត្រកម្ពុជា http://csx.com.kh/kh/about/profile.jsp?MNCD=10301 ចូលដកស្រង់ថ្ងៃទី ០១ ឧសភា ឆ្នាំ ២០១៧។

១៧) ប្រតិបត្តិការទីផ្សារមូលបត្រ http://csx.com.kh/operation/market/listPosts.do?MNCD=3020 ចូលដកស្រង់ថ្ងៃទី ១២ ឧសភា ឆ្នាំ ២០១៧។

១៨) ស្ថានភាពទូទៅធនាគារកាណាឌីយ៉ា,ចូលដកស្រង់ថ្ងៃទី ០៧ កក្កដា ឆ្នាំ ២០១៧
https://www.canadiabank.com.kh/kh/about_canadia_kh.aspx
https://www.canadiabank.com.kh/kh/board_director_kh.aspx
https://www.canadiabank.com.kh/kh/compliance_kh.aspx
https://www.canadiabank.com.kh/kh/corresbankkh.aspx

១៩) https://www.canadiabank.com.kh/kh/index_kh.aspx ចូលដកស្រង់ថ្ងៃទី ១០ កក្កដា ២០១៧។

២០) https://www.canadiabank.com.kh/kh/saving_account_kh.aspx ចូលដកស្រង់ថ្ងៃទី ១០ កក្កដា ២០១៧។

២១) https://www.canadiabank.com.kh/kh/sme_loan_kh.aspx ចូលដកស្រង់ថ្ងៃទី ១០ កក្កដា ២០១៧។

២២) https://www.canadiabank.com.kh/kh/corperate_loan_kh.aspx ចូលដកស្រង់ថ្ងៃទី ១០ កក្កដា ២០១៧។

២៣) ការជាត់ទាត់ និងទូទាត់មូលបត្រ http://csx.com.kh/operation/clearing/listPosts.do?MNCD=3030 ថ្ងៃទី ០៧ កក្កដា ២០១៧។

២៤) ដំណើរការនៃការដាក់ និងដកសាច់ប្រាក់ជួញដូរ http://www.canasecurities.com.kh/kh/121/cash-deposit-withdrawal-instruction?m_id=124 ចូលដកស្រង់ថ្ងៃទី ០៧ កក្កដា ឆ្នាំ ២០១៧។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១
# វិធានប្រតិបត្តិការរក្សាទុក
# មូលបត្ររបស់ក្រុមហ៊ុន
# ផ្សារមូលបត្រកម្ពុជា

- ឧបសម្ព័ន្ធប្រកាសលេខ ០០២/១១ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
- ឧបសម្ព័ន្ធប្រកាសលេខ ០០១/១២ ស្អន៤ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឲ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០១/១៣ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០១/១៤ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៤ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០៣/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៥ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០១/១៦ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ១១ ខែមិនា ឆ្នាំ២០១៦ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០៣/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

# វិធានប្រតិបត្តិការរក្សាទុកមូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

គោលបំណងនៃវិធាននេះគឺដើម្បីកំណត់អំពីលក្ខខណ្ឌចាំបាច់នានាសម្រាប់ការរក្សាទុក និងការផ្ទេរមូលបត្រ នៅក្នុងប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ( សរសេរកាត់ថា ផ.ម.ក.) ដែលទទួលបានការអនុញ្ញាតស្របតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុ

ក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

-**សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ដោយមានសិទ្ធិប្រើប្រាស់ទាំងស្រុង នូវប្រព័ន្ធរក្សាទុកមូលបត្ររបស់ **ផ.ម.ក.**។

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនៃសេវារបស់ប្រតិបត្តិកររក្សាទុកមូលបត្ររបស់ **ផ.ម.ក.**។

**ប្រការ ៣.- ម៉ោងអាជីវកម្ម**

ម៉ោងអាជីវកម្មស្របតាមវិធាននេះគឺចាប់ផ្ដើមពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៥:០០ ល្ងាច រៀងរាល់ថ្ងៃធ្វើការ។

**ប្រការ ៤.- ការកំណត់ ឬការលុបចោលនូវមូលបត្រដែលអាចរក្សាទុកបាន**

លើកលែងតែមានការកំណត់បន្ថែមផ្សេងពីនេះដោយ **គ.ម.ក.** មូលបត្រដែលអាចរក្សាទុកបាននៅប្រតិបត្តិកររក្សាទុកមូលបត្រ មានដូចខាងក្រោម :

១- មូលបត្រដែលបានចុះបញ្ជីនៅប្រតិបត្តិករទីផ្សារមូលបត្ររបស់ **ផ.ម.ក.**។

២- មូលបត្រដែលទើបបោះផ្សាយដោយក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។

៣- មូលបត្រដែលកំពុងស្ថិតក្នុង ឬដែលនឹងចាប់ផ្ដើមនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ។

៤- មូលបត្រដែលរៀបចំចុះបញ្ជីនៅប្រតិបត្តិករទីផ្សារមូលបត្ររបស់ **ផ.ម.ក.**។

**ប្រការ ៥.- ព័ត៌មានពាក់ព័ន្ធនឹងការដាក់ផ្ញើមូលបត្រ**

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវផ្ដល់ព័ត៌មានដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារបញ្ជិកាមូលបត្រ ដូចខាងក្រោម :

១- ប្រភេទមូលបត្រ។

២- ចំនួននៃការបោះផ្សាយ។

៣- ឈ្មោះមូលបត្រ។

៤- អក្សរកូដ។

៥- ចំនួនមូលបត្រសរុប។

៦- កាលបរិច្ឆេទបោះផ្សាយ ។

៧- កាលបរិច្ឆេទចុះបញ្ជី ។

៨- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពលើមូលបត្រ។

## ជំពូកទី ២

## គណនីមូលបត្រ

### ប្រការ ៦.- ការបើកគណនីមូលបត្រ

លើកលែងតែមានការកំណត់បន្ថែមផ្សេងពីនេះដោយ **គ.ម.ក.** បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ មានដូចខាងក្រោម :

១- ក្រុមហ៊ុនមូលបត្រ។

២- ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។

បុគ្គលដូចមានក្នុងកថាខណ្ឌទី១ ខាងលើ ដែលមានបំណងបើកគណនីមូលបត្រត្រូវបំពេញបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

### ប្រការ ៧.- សៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួម

ប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវរក្សាសៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួមនីមួយៗ ដែលត្រូវមានព័ត៌មាន ព្រមទាំងសេចក្តីលម្អិតនៃប្រតិបត្តិការលើមូលបត្រដែលធ្វើដោយសមាជិក និងអ្នកចូលរួម។ លើកលែងតែមានការកំណត់បន្ថែមផ្សេងពីនេះដោយ **គ.ម.ក** ព័ត៌មានលម្អិតរួមមានដូចខាងក្រោម :

១- ឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលស្នើបើកគណនី។

២- ប្រភេទ និងបរិមាណនៃមូលបត្រដែលរក្សាទុក និងឈ្មោះនៃក្រុមហ៊ុនបោះផ្សាយ។

៣- ហេតុផលនៃឥណទាន ឬឥណពន្ធនៃមូលបត្រដែលរក្សាទុក។

៤- ឈ្មោះ និងអាសយដ្ឋាននៃអ្នកទទួលបញ្ចាំក្នុងករណីដែលមូលបត្ររក្សាទុក ជាកម្មវត្ថុនៃការបញ្ចាំ។

៥- ក្នុងករណីមូលបត្រដែលបានដាក់ផ្ញើជាកម្មវត្ថុនៃការដាក់កំហិតលក់ត្រូវមានកំណត់សម្គាល់អំពីការណ៍នេះនិងកាលបរិច្ឆេទនៃការចេញសេចក្ដីសម្រេចរបស់តុលាការអំពីការរឹបអូស ឬការសម្រេចផ្សេងទៀត។

ការកាន់កាប់មូលបត្រផ្ទាល់របស់សមាជិកត្រូវកត់ត្រាដាច់ដោយឡែកពីមូលបត្រដែលជាកម្មសិទ្ធិរបស់អតិថិជន។

សៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួមត្រូវរក្សាទុកសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ។

ក្នុងករណីដែលសមាជិក ឬក្រុមហ៊ុនបោះផ្សាយមានបំណងកែប្រែឈ្មោះ អាសយដ្ឋាន លេខចុះបញ្ជីពាណិជ្ជកម្ម ឬការបោះពុម្ពត្រាសម្គាល់ សមាជិកឬក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងដល់ប្រតិបត្តិកររក្សាទុកមូលបត្រ នូវការកែប្រែទាំងនោះ ដោយបំពេញបែបបទស្នើសុំឱ្យបានត្រឹមត្រូវ។

## ប្រការ ៨.- សៀវភៅគណនីមូលបត្ររបស់អតិថិជន

សមាជិកដែលដាក់ផ្ញើមូលបត្ររបស់អតិថិជន នៅប្រតិបត្តិកររក្សាទុកមូលបត្រ ដោយមានការឯកភាពរបស់អតិថិជន ត្រូវរក្សាទុកនូវ "សៀវភៅគណនីអតិថិជន" ដែលមានព័ត៌មានលម្អិតដូចខាងក្រោម÷

១- ឈ្មោះ និងអាសយដ្ឋានរបស់អតិថិជន។

២- ប្រភេទ និងបរិមាណនៃមូលបត្រដែលរក្សាទុក និងឈ្មោះនៃក្រុមហ៊ុនបោះផ្សាយ។

៣- ព័ត៌មាននៃប្រតិបត្តិការលើមូលបត្រ។

៤- ព័ត៌មានអំពីអតិថិជននីមួយៗ ដែលត្រូវបានរក្សាទុកនៅក្នុងសៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួម។

សៀវភៅគណនីមូលបត្ររបស់អតិថិជនត្រូវរក្សាទុកសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ។

## ប្រការ ៩.- កាលបរិច្ឆេទសុពលភាពនៃការដាក់ផ្ញើ

ការដាក់ផ្ញើ ការដក ឬការបង្វិលទៅវិញ និងការផ្ទេរមូលបត្ររវាងគណនី ដែលធ្វើឡើងស្របតាមវិធាននេះ ត្រូវមានសុពលភាពចាប់ពីពេលដែលព័ត៌មានពាក់ព័ន្ធ ត្រូវបានកត់ត្រាទុកនៅក្នុងសៀវភៅគណនីមូលបត្ររបស់សមាជិកនិងអ្នកចូលរួម។

## ប្រការ ១០.- ការបិទគណនីមូលបត្រ

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ **គ.ម.ក.** ប្រតិបត្តិកររក្សាទុកមូលបត្រ អាចបិទគណនីមូលបត្ររបស់សមាជិក ឬអ្នកចូលរួមក្នុងករណីណាមួយដូចខាងក្រោម÷

១- សមាជិក ឬអ្នកចូលរួមស្នើសុំបិទគណនីមូលបត្រ។

២- សមាជិក ឬអ្នកចូលរួមមិនបានប្រើប្រាស់គណនីរបស់ខ្លួនក្នុងរយៈពេល ០២ (ពីរ) ឆ្នាំ។

មុននឹងបិទគណនីមូលបត្ររបស់សមាជិក ឬអ្នកចូលរួម ប្រតិបត្តិកររក្សាទុកមូលបត្រត្រូវផ្តល់ជូននូវសមតុល្យនៃការដាក់ផ្ញើនៅក្នុងគណនីមូលបត្រដែលត្រូវបិទទៅសមាជិក ឬអ្នកចូលរួមដែលពាក់ព័ន្ធ។

## ជំពូកទី ៣
## បទប្បញ្ញត្តិបន្ថែម

### ប្រការ ១១.- អ្នកតំណាងរក្សាទុកមូលបត្រ

សមាជិកនីមួយៗ ត្រូវតែងតាំង និងចុះឈ្មោះអ្នកតំណាងរក្សាទុកមូលបត្ររបស់ខ្លួនយ៉ាងហោចណាស់ចំនួន ០១ (មួយ) រូប ដែលត្រូវទទួលការបណ្តុះបណ្តាលពី **ផ.ម.ក.** និងដែលត្រូវមានសិទ្ធិធ្វើប្រតិបត្តិការរក្សាទុកមូលបត្រឱ្យសមាជិកនោះ។

អ្នកតំណាងរក្សាទុកមូលបត្ររបស់សមាជិកនេះ អាចជាអ្នកតំណាងទូទាត់ដែលត្រូវបានតែងតាំងដោយសមាជិកស្របតាមវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ របស់ **ផ.ម.ក.**។

### ប្រការ ១២.- ការជូនដំណឹងអំពីសមតុល្យ

ប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវជូនដំណឹងដល់សមាជិក និងអ្នកចូលរួមអំពីសមតុល្យនៃគណនីមូលបត្រ ដែលបានដាក់ផ្ញើនៅរៀងរាល់ចុងខែនីមួយៗ។ ការជូនដំណឹងអំពីសមតុល្យគណនីនេះអាចត្រូវបានជំនួសដោយការដាក់ជូននូវសេចក្តីចម្លងនៃសៀវភៅគណនីមូលបត្ររបស់សមាជិក ឬរបស់អ្នកចូលរួម។

### ប្រការ ១៣ ថ្មី (ថ្នាំ).- ថ្លៃសេវាប្រតិបត្តិការរក្សាទុកមូលបត្រ

សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ប្រាក់ថ្លៃសេវារក្សាទុកមូលបត្រ ប្រាក់ថ្លៃសេវាផ្ទេររវាងគណនីមូលបត្រនិងប្រាក់ថ្លៃសេវាផ្សេងទៀតសម្រាប់សេវាដែលបានទទួលស្របតាមប្រការនេះ។

សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ប្រាក់ថ្លៃសេវាជូន **ផ.ម.ក.** ដូចខាងក្រោម ÷

១-ថ្លៃសេវារក្សាទុកមូលបត្រ : ជាថ្លៃសម្រាប់ការដាក់ផ្ញើមូលបត្រដែលស្ថិតក្នុងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ (IPO)។ ប្រាក់ថ្លៃសេវារក្សាទុកមូលបត្រប្រចាំខែត្រូវបង់នៅថ្ងៃទី ១០ នៃខែបន្ទាប់ពីខែដែលប្រាក់ថ្លៃនោះបានកើតឡើងតាមលក្ខខណ្ឌដូចខាងក្រោម :

ក-អត្រា២០ (ម្ភៃ) រៀលលើមូលដ្ឋាននៃទឹកប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល។

ក្នុងករណីនេះ ថ្លៃសេវាត្រូវកំណត់យកលើមូលដ្ឋានសមតុល្យប្រចាំថ្ងៃ ដែលបង្ហាញជូននៅក្នុងសៀវភៅគណនីមូលបត្រ។ ថ្លៃនេះមិនត្រូវលើសពី១២០.០០០ (មួយរយម្ភៃពាន់) រៀលក្នុងមួយថ្ងៃឡើយ។

ខ-អ្នកត្រូវបង់ប្រាក់ជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។

២-ថ្លៃសេវាផ្ទេរមូលបត្ររវាងគណនី (Book Entry Fee) :

ក-អត្រាប្រាក់ថ្លៃនៃការផ្ទេរមូលបត្ររវាងគណនី ត្រូវគណនាលើមូលដ្ឋានទឹកប្រាក់នៃការជួញដូរ ដែលបានទូទាត់ តាមអត្រា ១០/១០.០០០ (ដប់ភាគមួយម៉ឺន) ចំពោះមូលបត្រកម្មសិទ្ធិ ហើយទឹកប្រាក់ថ្លៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។

ខ-អ្នកត្រូវបង់ប្រាក់ជាក្រុមហ៊ុនមូលបត្រជាសមាជិក។

គ-ពេលវេលាបង់ប្រាក់នៅម៉ោង ៨ : ៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់។

៣-ថ្លៃប្រតិបត្តិការផ្សេងៗ :

ក-ប្រាក់ថ្លៃនៃការផ្ទេរមូលបត្រដែលមិនត្រូវបានជួញដូរ គឺ១០០.០០០ (មួយរយពាន់) រៀលក្នុងមួយប្រតិបត្តិការ ។ សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ប្រាក់ថ្លៃនេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក**នៅពេលស្នើសុំផ្ទេរមូលបត្រ ។

ខ-ថ្លៃនៃការដកមូលបត្រ គឺ ២០០.០០០ (ពីររយពាន់) រៀលក្នុងមួយប្រតិបត្តិការ ។ សមាជិក និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវបង់ប្រាក់ថ្លៃនេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** នៅពេលស្នើសុំដកមូលបត្រ ។

អត្រាថ្លៃសេវានៃការផ្ទេរមូលបត្ររវាងគណនីដូចមានចែងក្នុងកថាខណ្ឌទី២ ចំណុចទី២ “ក” ខាងលើ ត្រូវកាត់បន្ថយចំនួន ៥០% មកត្រឹមអត្រា ៥/១០.០០០ (ប្រាំភាគមួយម៉ឺន) ឬ០,០៥% (សូន្យក្បៀសសូន្យប្រាំភាគរយ) ចំពោះមូលបត្រកម្មសិទ្ធិ ហើយប្រាក់ថ្លៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស អនុវត្តរហូតដល់មានការជូនដំណឹងជាថ្មី។

* * * * *

# ឧបសម្ព័ន្ធទី២
# វិធានប្រតិបត្តិការផាត់
# ទាត់ និងទូទាត់មូលបត្រ
# របស់ក្រុមហ៊ុនផ្សារ
# មូលបត្រកម្ពុជា

- ឧបសម្ព័ន្ធប្រកាសលេខ ០០៥/១១ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ
- ឧបសម្ព័ន្ធប្រកាសលេខ ០០១/១២ ស្អនខ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឲ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០១/១៣ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០១/១៤ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៤ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០៥/១៤ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០៣/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៤ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០១/១៦ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ១១ ខែមិនា ឆ្នាំ២០១៦ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឧបសម្ព័ន្ធប្រកាសលេខ ០០៣/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការកែប្រែថ្លៃសេវាក្នុងវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

# វិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

គោលបំណងនៃវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រនេះគឺដើម្បីកំណត់នូវគោលការណ៍នានាដែលចាំបាច់សម្រាប់ការផាត់ទាត់និងទូទាត់មូលបត្រ នៅក្នុងប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូល

បត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ដែលទទួលបានការអនុញ្ញាតស្របតាមច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

-**សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ដោយមានសិទ្ធិប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្ររបស់ **ផ.ម.ក.**។

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនៃសេវារបស់ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្ររបស់ **ផ.ម.ក.**។

-**ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ** សំដៅដល់ធនាគារពាណិជ្ជដែលបានការទទួលស្គាល់ពី **គ.ម.ក.** ដូចមានចែងក្នុងប្រកាសស្ដីពីការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

### ប្រការ ៣.- ប្រតិបត្តិការជាត់ទាត់និងទូទាត់

ការជួញដូរមូលបត្រចុះបញ្ជី ត្រូវតែប្រតិបត្តិតាមការទូទាត់ធម្មតា។ ការទូទាត់ធម្មតា គឺជាការទូទាត់ដែលត្រូវធ្វើឡើងពីរថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+2)។

## ជំពូកទី ២
## ការទូទាត់រវាងប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសមាជិក

### ប្រការ ៤.- ភាតព្វកិច្ចទូទាត់របស់សមាជិក

សមាជិកនៃប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវធ្វើការទូទាត់លើប្រតិបត្តិការដែលបានជួញដូរ ឱ្យបាននៅកាលបរិច្ឆេទទូទាត់។

សមាជិកនៃប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ មិនអាចប្រគល់ភារកិច្ចទូទាត់ប្រតិបត្តិការរបស់ខ្លួនទៅឱ្យសមាជិកដទៃទៀតឡើយ។

### ប្រការ ៥.- កាលបរិច្ឆេទជាត់ទាត់និងទូទាត់រវាងសមាជិក

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ **គ.ម.ក.** ការទូទាត់ត្រូវធ្វើឡើងពីរថ្ងៃនៃថ្ងៃជួញដូរ បន្ទាប់ពីថ្ងៃដែលមូលបត្រនោះត្រូវបានជួញដូរ (T+2)។ ថ្ងៃបិទទីផ្សារមិនត្រូវបានរាប់បញ្ចូលក្នុងចំនួនថ្ងៃអាជីវកម្មទេ។

**ប្រការ ៦.- ការជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

សមាជិកត្រូវជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** សម្រាប់បំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

**ប្រការ ៧.- ការបើកគណនីទូទាត់សម្រាប់ការទូទាត់សាច់ប្រាក់**

សមាជិកនៃប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវបើកគណនីសាច់ប្រាក់ក្នុងនាមខ្លួនផ្ទាល់ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដូចមានចែងក្នុងប្រការ ៦ នៃវិធាននេះ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

បន្ទាប់ពីបានបើកគណនីសាច់ប្រាក់ ឬមានការផ្លាស់ប្តូរគណនីសាច់ប្រាក់ សមាជិកត្រូវរាយការណ៍អំពីឈ្មោះនៃភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន និងលេខគណនី ជូនដល់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ យ៉ាងហោចណាស់ ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ មុនថ្ងៃចាប់ផ្តើមការជួញដូរ។

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវបើកគណនីទូទាត់សាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់សមាជិកទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ។ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្ទេរសាច់ប្រាក់ដែលទទួលបាននេះ ទៅសមាជិកដែលត្រូវទទួលបានការទូទាត់សាច់-ប្រាក់។

**ប្រការ ៨.- ការបើកគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ**

សមាជិកត្រូវបើកគណនីមូលបត្រ ស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវបើកគណនីទូទាត់មូលបត្រ នៅប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ការទូទាត់មូលបត្រត្រូវធ្វើឡើង តាមរយៈការផ្ទេរក្នុងបញ្ជី (Book-Entry Transfer) ពីគណនីមូលបត្ររបស់សមាជិក ទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ។ ប្រតិបត្តិករ

ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះ ទៅសមាជិកដែលត្រូវទទួលបានការទូទាត់មូលបត្រ។

**ប្រការ ៩ (ថ្មី).- ការតម្កល់ធានាការជួញដូរ**

មុនអនុវត្តបញ្ជាសម្រាប់គណនីអតិថិជន ឬសម្រាប់គណនីផ្ទាល់ខ្លួន សមាជិកត្រូវពិនិត្យការតម្កល់ធានាការជួញដូរមូលបត្រឱ្យបានត្រឹមត្រូវ ដូចតទៅ÷

១- សម្រាប់ការបញ្ជាទិញ ត្រូវមានការតម្កល់ធានាការជួញដូរយ៉ាងតិច ១០០% (មួយរយភាគរយ) ជាសាច់ប្រាក់ ឬ/និង សាច់ប្រាក់ត្រូវទទួលបានពីការបញ្ជារលក់ដែលបានផ្គូរផ្គងដោយជោគជ័យ។

២- សម្រាប់ការបញ្ជាលក់ ត្រូវមានការតម្កល់ធានាការជួញដូរយ៉ាងតិច ១០០% (មួយរយភាគរយ) ជាមូលបត្រ ឬ/និង មូលបត្រដូចគ្នាត្រូវទទួលបានពីការបញ្ជារទិញដែលបានផ្គូរផ្គងដោយជោគជ័យ។

សមាជិកត្រូវធានាឱ្យបានថា ការតម្កល់ធានាការជួញដូរត្រូវបានរក្សាទុក ឬបង្កកសម្រាប់ការទូទាត់ ឬរហូតដល់ការបញ្ជានោះអស់សុពលភាព។

**ប្រការ ១០.- នីតិវិធីនៃប្រតិបត្តិការជាត់ទាត់និងទូទាត់**

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ចុងក្រោយដោយសមាជិក ដោយធ្វើការបន្សុទ្ធ ឬកាត់កង (Netting) ចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ក្នុងថ្ងៃដូចគ្នា របស់សមាជិកនីមួយៗ។

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវជូនដំណឹងអំពីព័ត៌មានដូចខាងក្រោមដល់សមាជិកនៅកាលបរិច្ឆេទជាត់ទាត់ និងកាលបរិច្ឆេទទូទាត់÷

១- កាលបរិច្ឆេទជាត់ទាត់ និងកាលបរិច្ឆេទទូទាត់។

២- បរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជន។

៣- ទឹកប្រាក់ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជន។

បរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ដែលនឹងត្រូវទូទាត់ ត្រូវគណនាស្របតាមវិធីសាស្ត្រនីមួយៗដូចខាងក្រោម÷

១- ចំពោះមូលបត្រ: ត្រូវបានគណនាដោយធ្វើការជាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ សម្រាប់សមាជិកដែលពាក់ព័ន្ធ។

២- ចំពោះសាច់ប្រាក់ : ត្រូវបានគណនាដោយធ្វើការជាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សរុប សម្រាប់សមាជិកនីមួយៗដែលពាក់ព័ន្ធ។

សមាជិកត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ ទៅគណនីរបស់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ នៅមុនម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់ (Settlement Date) ហើយប្រតិបត្តិ

ករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវធ្វើការទូទាត់មូលបត្រនិងសាច់ប្រាក់បន្តទៅឱ្យសមាជិកដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ ព្រឹក នៅថ្ងៃដដែលនៅកាលបរិច្ឆេទទូទាត់។

**ប្រការ ១១.- ការប្រគល់ឯកសារទូទាត់**

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្តល់នូវឯកសារបង្កាប់ទូទាត់ ដែលរួមមានព័ត៌មានលម្អិតលើមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ជូនដល់សមាជិក ក្រោយការបិទទីផ្សារ តាមរយៈប្រព័ន្ធកុំព្យូទ័រ។

សមាជិកត្រូវពិនិត្យអំពីមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ នៅលើឯកសារបង្កាប់ទូទាត់ និងត្រូវធ្វើការទូទាត់ទៅតាមពេលវេលាកំណត់។

សមាជិកត្រូវប្រគល់ឯកសារទូទាត់ដែលមានព័ត៌មានលម្អិត និងពេលវេលានៃការទូទាត់ជាដើម ជូនដល់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ក្រោយពីការទូទាត់។

**ប្រការ ១២.- វិធានការវិន័យចំពោះការបរាជ័យនៃការទូទាត់**

ក្នុងករណីដែលសមាជិកណាមួយគ្មានលទ្ធភាពធ្វើការទូទាត់ការជួញដូររបស់ខ្លួន ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រអាចលុបចោលនូវការជួញដូរដែលបានប្រតិបត្តិហើយទាំងស្រុង ឬមួយផ្នែកនៅក្នុង **ផ.ម.ក.** ឬ/និង ព្យួរការជួញដូររបស់សមាជិកនោះក្នុងរយៈពេលកំណត់មួយ។

ក្នុងករណីដែលមានកង្វះខាតសាច់ប្រាក់ក្នុងការទូទាត់ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រអាចប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីធានាការទូទាត់ លើកលែងតែមានការកំណត់ផ្សេងទៀត។

ក្នុងករណីដែលមានកង្វះខាតមូលបត្រសម្រាប់ទូទាត់ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រត្រូវធ្វើការទូទាត់ ដោយសុំខ្ចីនូវមូលបត្រប្រភេទដូចគ្នាពីសមាជិកផ្សេងទៀត។ ប្រសិនបើការសុំខ្ចី និងការឱ្យខ្ចីមិនអាចធ្វើទៅបាន ការទូទាត់នឹងត្រូវលុបចោល។

ប្រសិនបើ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ មិនអាចរកមធ្យោបាយដើម្បីធ្វើការទូទាត់ដូចមានចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រអាចចាត់វិធានការ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

**ប្រការ ១៣.- អ្នកតំណាងទូទាត់**

សមាជិកនីមួយៗត្រូវតែងតាំង និងចុះឈ្មោះអ្នកតំណាងទូទាត់យ៉ាងហោចណាស់ ០១ (មួយ) រូប ដែលត្រូវទទួលការបណ្តុះបណ្តាលពី **ផ.ម.ក.** និងដែលមានសិទ្ធិធ្វើប្រតិបត្តិការទូទាត់ឱ្យសមាជិកនោះ ជាមួយ **ផ.ម.ក.**។

អ្នកតំណាងទូទាត់របស់សមាជិកនោះ អាចជាអ្នកតំណាងទីផ្សារដែលត្រូវបានតែងតាំងដោយសមាជិក ស្របតាមវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ **ផ.ម.ក.**។

## ជំពូកទី ៣

## ថ្លៃសេវាជាត់ទាត់និងទូទាត់

**ប្រការ ១៤ថ្មី (ថ្មី).- ថ្លៃសេវាជាត់ទាត់និងទូទាត់មូលបត្រ**

សមាជិកត្រូវបង់ថ្លៃសេវាជាត់ទាត់និងទូទាត់ ជូនប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រតាមអត្រា និងពេលវេលាដូចខាងក្រោម÷

១-ថ្លៃសេវាសម្រាប់សេវាជាត់ទាត់និងទូទាត់មូលបត្រ ត្រូវយកលើតម្លៃជួញដូរដែលត្រូវបានទូទាត់ (ប្រាក់សេវាត្រូវកាត់ក្បៀសបកត្រឹមមួយខ្ទង់) តាមអត្រា៥/១០.០០០ (ប្រាំភាគមួយម៉ឺន) ឬ០,០៥% (សូន្យក្បៀសសូន្យប្រាំភាគរយ)។

២-អ្នកបង់ថ្លៃសេវាគឺ ក្រុមហ៊ុនមូលបត្រដែលជាសមាជិកនៃប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ។

៣-ពេលវេលានៃការបង់ថ្លៃសេវាគឺនៅ ម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

ថ្លៃសេវាសម្រាប់ជាត់ទាត់ និងទូទាត់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី១ ចំនុចទី១ ខាងលើ ត្រូវកាត់បន្ថយចំនួន ៥០% មកត្រឹមអត្រា ២,៥/១០.០០០ (ពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ) អនុវត្តរហូតដល់មានការជូនដំណឹងជាថ្មី។

* * *